**ក្រសួងអប់រំ យុវជន និងកីឡា**

**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**

**National Institute of Education**

# និក្ខេបបទ

# ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ

STUDENT'S PERCEPTION ON LEARNING AND TEACHING ENGLISH IN HIGH SCHOOL IN PHNOM PENH

ដោយ/By

**អ៊ិន ផល្លាក់ / ORN PHALLEAK**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី១០**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

ក្រសួងអប់រំ យុវជន និងកីឡា

**Ministry of Education Youth and Sport**

វិទ្យាស្ថានជាតិអប់រំ

**National Institute of Education**


# និក្ខេបបទ

# ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ

# STUDENTS' PERCEPTION ON LEARNING AND TEACHING ENGLISH IN HIGH SCHOOL IN PHNOM PENH


ដោយ/By

**អ៊ន ផល្លាក់ / ORN PHALLEAK**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី១០

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣


សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត សោន វណ្ណៈ

សាស្ត្រាចារ្យដឹកនាំរង ៖ លោក ម៉ូ ម៉ុន្តន

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ។ សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះសុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់។

និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃសុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០២៣

**ហត្ថលេខាបេក្ខជន**



**អ៊ិន ផល្លាក់**

# លិខិតបញ្ជាក់

**បណ្ឌិត** **សោន វណ្ណះ** ជាសាស្ត្រាចារ្យដឹកនាំ

**លោក** **ម៉ូ ម៉ុន្តន** ជាសាស្ត្រាដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អ៊ិន ផល្លាក់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃសុក្រ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០២៣

.....................................

**បណ្ឌិត សោន វណ្ណះ**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

.........................................

**លោក ម៉ូ ម៉ុន្តន**

គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ: ៤៧៣ អយក.ខុទ**

**(ការសម្ងាត់)**

**លិខិតឧទ្ទេសនាម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំផ្លូវកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី ឡៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ៊ិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ៤៥០១ អយក.ខទន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត ប៊ូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ឹម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- អគ្គនាយកដ្ឋានរ.ហ៊ុ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **បណ្ឌិត សោន វណ្ណៈ** ដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទ ពន្យល់ណែនាំលើខ្លឹមសាររួម បង្ហាញនូវផែនទីគំនិត គន្លឹះសំខាន់ៗ និងចំណេះដឹងល្អៗ ព្រមទាំងបទពិសោធន៍នានា ដើម្បីជំរុញលទ្ធផលនៃការសរសេរនិក្ខេបបទរបស់ខ្ញុំបាទទទួលបានជោគជ័យ និងធានាបាននូវគុណភាពនៃការបណ្តុះបណ្តាល។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ **លោក ប៉ូ ប៊ុន្នន** ជាគ្រូដឹកនាំរង ដែលតែងតែផ្តល់ចំណេះដឹង ចែករំលែកបទពិសោធន៍ ការគាំទ្រ ការយកចិត្តទុកដាក់ និងការលើកទឹកចិត្តជាច្រើនដល់ខ្ញុំបាទ រហូតដល់សម្រេចបានជាលទ្ធផលល្អប្រសើរ។

ខ្ញុំបាទសូមថ្លែងនូវការដឹងគុណ និងសេចក្តីស្រឡាញ់អស់ពីបេះដូង ចំពោះក្រុមគ្រួសារ លោកឪពុក និងអ្នកម្តាយ ពូមីង បងប្អូន មិត្តភ័ក្តិដែលបានផ្តល់ការគាំទ្រ និងលើកទឹកចិត្តរហូតមក ព្រមទាំងផ្តល់ឱកាសឱ្យរូបខ្ញុំបាទបានបន្តការសិក្សារហូតដល់ចប់សព្វគ្រប់ដូចបំណងប្រាថ្នា។

# មាតិកា

**សេចក្តីប្រកាសអះអាងរបស់បេក្ខជន** ........ I

**លិខិតបញ្ជាក់សាស្ត្រាចារ្យដឹកនាំ** ........ II

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ III

**សេចក្តីថ្លែងអំណរគុណ** ........ VII

**មាតិកា** ........ VIII

**បញ្ជីតារាងនិងរូបភាព** ........ XII

**មូលន័យសង្ខេប** ........ XIII

Abstract ........ XV

## ជំពូក១ សេចក្តីផ្តើម

១.១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1

១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 4

១.៣.គោលបំណងនៃការស្រាវជ្រាវ ........ 5

១.៤.សំណួរស្រាវជ្រាវ ........ 5

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ 6

១.៦.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 6

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

## ជំពូក២ ការរំលឹកទ្រឹស្តី

២.១. ការសិក្សាពាក្យគន្លឹះ ........ 9

២.២. ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន......10
២.២.១. ទស្សនទានការដឹកនាំគ្រប់គ្រងសាលារៀន......10
២.២.២- ការទទួលខុសត្រូវរបស់នាយកសាលារៀន......12
២.៣. ការអនុវត្តកម្មវិធីសិក្សា......Error! Bookmark not defined.13
២.៤- គុណភាពគ្រូបង្រៀនសតវត្សទី ២១......16
២.៤.១- លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនសតវត្សទី២១......17
២.៤.២. វិធីសាស្ត្ររបស់គ្រូបង្រៀនសតវត្សទី២១......18
២.៥- បញ្ហាប្រឈមលើការរៀនភាសាអង់គ្លេស......18
២.៥.១- ការរៀន និងបង្រៀនភាសាអង់គ្លេសក្នុងថ្នាក់......20
២.៥.២- ឥរិយាបថ ចំពោះការសិក្សាភាសារបស់សិស្ស......20
២.៥.៣- ការលើកទឹកចិត្ត និង ការសិក្សាភាសា......23
២.៦- មូលហេតុនៃភាពកម្សោយក្នុងការរៀនភាសាអង់គ្លេស......24
២.៦.១- ការលើកទឹកចិត្តសម្រាប់ការរៀនភាសាអង់គ្លេស......26
២.៧- យុទ្ធសាស្ត្ររៀនភាសាអង់គ្លេស......26

## ជំពូក៣ វិធីសាស្ត្រស្រាវជ្រាវ

៣.១. គម្រោងវិភាគ......29
៣.២. ការប្រមូលទិន្នន័យ......29
៣.៣. ឧបករណ៍ស្រាវជ្រាវ......30

៣.៣.១. កម្រិតចង្កុលបង្ហាញ......30

៣.៣.២. កម្រងសំណួរ......31

៣.៤. ការជ្រើសរើសភាគសំណាក......34

៣.៥. ការវិភាគទិន្នន័យ......35

## ជំពូក៤ លទ្ធផលនៃការស្រាវជ្រាវ

៤.១.ព័ត៌មានទូទៅរបស់អ្នកចូលរួម......37

៤.១.១.ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលា......37

៤.១.២.ព័ត៌មានទូទៅរបស់គ្រូបង្រៀន......38

៤.១.៣.ព័ត៌មានទូទៅរបស់សិស្ស......38

៤.២.ការយល់ឃើញរបស់សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រងលើការរៀន និងបង្រៀនភាសាអង់គ្លេស...39

៤.២.១. យោបល់សិស្សលើការរៀន និងបង្រៀនភាសាអង់គ្លេស ៣៩......39

៤.២.២ ការឆ្លើយតបរបស់គ្រូបង្រៀន លើការរៀន និងបង្រៀនភាសាអង់គ្លេស......51

៤.២.៣ ការឆ្លើយតបរបស់គណៈគ្រប់គ្រង លើការពង្រឹងការបង្រៀន និងរៀន មុខវិជ្ជាភាសាអង់គ្លេស...55

៤.៣. លទ្ធផលសរុបនៃការឆ្លើយតបរបស់សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រង......58

៤.៤. ការពិភាក្សា......60

៤.៤.១. ស្ថានភាពនៃការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស......60

៤.៤.២ ការពិភាក្សាលើការពង្រឹងលើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស......62

# ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១. សេចក្តីសន្និដ្ឋាន....................66

៥.២. សំណូមពរ....................69

ឯកសារយោង

ឧបសម្ព័ន្ធ ក

ឧបសម្ព័ន្ធ ខ

ឧបសម្ព័ន្ធ គ

ឧបសម្ព័ន្ធ ឃ

# បញ្ជីតារាងនិងរូបភាព


តារាង 3.1៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ ............................................34

ក្រាបទី១៖ ការឃើញរបស់សិស្សលើសៀវភៅសិក្សាគោល ............................................................40

ក្រាបទី២៖ ការឃើញរបស់សិស្សលើសកម្មភាពនានារបស់គ្រូ ........................................................41

ក្រាបទី៣៖ ការយល់ឃើញរបស់សិស្សលើការគោរពពេលវេលារបស់គ្រូ ...........................................43

ក្រាបទី៤៖ ការយល់ឃើញរបស់សិស្សលើសៀវភៅសិក្សាគោលធៀបនឹងសមត្ថភាពរបស់គាត់ ................44

ក្រាបទី៥៖ ការយល់ឃើញរបស់សិស្សលើម៉ោងសិក្សាក្នុងមួយសប្តាហ៍ ............................................46

ក្រាបទី៦៖ ការយល់ឃើញរបស់សិស្សលើគ្រូបង្រៀនភាសាអង់គ្លេស.................................................48

ក្រាបទី៧៖ ការយល់ឃើញរបស់សិស្សលើការគ្រប់គ្រង និងដឹកនាំរបស់សាលា ....................................50

តារាង 4.1 ៖ ក. ការអនុវត្តកម្មវិធីសិក្សា..................................................................................51

តារាង 4.2៖ ខ. ដំណើរការបង្រៀន .........................................................................................52

តារាង 4.3៖ គ.ទំនាក់ទំនងគ្រូ-សិស្ស........................................................................................53

តារាង 4.4៖ ឃ. ការប្រើប្រាស់សម្ភារៈឧបទ្ទេស..........................................................................54

តារាង 4.5៖ ទិន្នន័យសរុបរបស់គ្រូបង្រៀន ...............................................................................54

តារាង 4.6៖ ក. ការរៀបចំផែនការពង្រឹងកម្មវិធីភាសាអង់គ្លេស .....................................................55

តារាង 4.7៖ ខ. ការកសាងសមត្ថភាពគ្រូ ....................................................................................56

តារាង 4.8៖ គ. ការកសាងសមត្ថភាពសិស្ស.................................................................................57

តារាង 4.9៖ ឃ. ការត្រួតពិនិត្យផ្ទៃក្នុង.......................................................................................57

តារាង 4.10៖ ទិន្នន័យសរុបរបស់គណៈគ្រប់គ្រង .........................................................................58

តារាង 4.11៖ មធ្យមពិន្ទុរួមរបស់គ្រូបង្រៀន គណៈគ្រប់គ្រង និង សិស្ស.........................................59

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ**" មានគោលបំណងសិក្សាស្វែងយល់ពីការយល់ឃើញរបស់សិស្សលើការរៀនភាសាអង់គ្លេស និងការបង្រៀនរបស់លោកគ្រូអ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេស ការចូលរួមរបស់គណៈគ្រប់គ្រងលើការពង្រឹងការរៀននិងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។

វិធីសាស្រ្តស្រាវជ្រាវ គឺអនុវត្តតាមបរិមាណវិស័យ និងគុណវិស័យ។ ការប្រមូលទិន្នន័យតាមរយៈកម្រងសំណួរ ធ្វើឡើងនៅវិទ្យាល័យចំនួន០៩នៅរាជធានីភ្នំពេញ ដែលមានអ្នកផ្តល់ចម្លើយជា គណៈគ្រប់គ្រងសាលាចំនួន២០នាក់ លោកគ្រូ-អ្នកគ្រូបង្រៀនភាសាអង់គ្លេសចំនួន២៨នាក់ និងសិស្សានុសិស្សចំនួន៥២៩នាក់។ ទិន្នន័យត្រូវបានបញ្ចូលទៅក្នុងកម្មវិធី Ms Excel និង SPSS ដើម្បីរកប្រេកង់ តម្លៃមធ្យម និងគំលាតស្តង់ដា។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញមានស្ថានភាពដូចតទៅះ គ្រូបង្រៀនមិនមានសម្ភារៈឧបទ្ទេសបង្រៀនគ្រប់គ្រាន់ពេលបង្រៀនធ្វើឱ្យសិស្សពិបាកយល់លើខ្លឹមសារមេរៀន សាលាខ្វះបន្ទប់អនុវត្តភាសាអង់គ្លេសដែលធ្វើឱ្យសិស្សគ្មានឱកាសអភិវឌ្ឍន៍ជំនាញ និងសិស្សខ្លួនឯងមិនយកចិត្តទុកដាក់រៀនសូត្រ ដែលកត្តាទាំងអស់នេះហើយជាមូលហេតុធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមិនល្អ(ប្រឡងធ្លាក់ច្រើន)។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវបានបង្ហាញថា ដើម្បីធានាបាននូវគុណភាពសិក្សារបស់សិស្សត្រូវតែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធមានដូចជា ភាគីគណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សខ្លួនឯង។ គណៈគ្រប់គ្រងជាអ្នកជួយគាំទ្រដល់ការបង្រៀន និងរៀន ពិសេសគណៈគ្រប់គ្រងជាអ្នកមានទំនាក់ទំនង

ផ្ទាល់ជាមួយថ្នាក់ដឹកនាំអប់រំក្នុងមូលដ្ឋាន ថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។ បើគណៈគ្រប់គ្រងល្អ គ្រូបង្រៀននឹងពេញចិត្តបំពេញការងារប្រកបដោយទំនួលខុសត្រូវ ប្រកបដោយមនសិកាដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សល្អផងដែរ។ គ្រូបង្រៀន ជាអ្នកអនុវត្តន៍កម្មវិធីសិក្សាដោយផ្ទាល់ ជាអ្នកតម្រង់ទិស អ្នកប្រឹក្សាយោបល់ជាស្ពានសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនាពេលអនាគត និងជាអ្នកនៅជាមួយសិស្សជាប្រចាំ។ មានតែគ្រូបង្រៀនទេដែលដឹងថាសិស្សរបស់គាត់សិក្សាយ៉ាងដូចម្ដេច។ បន្ថែមពីនេះទៅទៀត ការចូលរួមសហការរបស់សិស្សក៏សំខាន់ណាស់ដែរ ព្រោះបើទោះបីជាគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាបានបំពេញតួនាទីបានល្អប្រសើរក្ដី តែសិស្សានុសិស្សមិនចូលរួមសហការនោះ គឺពិតជារាំងស្ទះដល់លទ្ធផលសិក្សាដូចគ្នា។

ឆ្លងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថាដំណោះស្រាយដែលអាចជួយជំរុញឱ្យការរៀននិងបង្រៀនភាសាអង់គ្លេស បានល្អប្រសើរឡើងវិញ ចាំបាច់ជាងគេបំផុត គឺកត្តាគ្រូបង្រៀន ដែលជាអ្នកអនុវត្តកម្មវិធីសិក្សា និងជាអ្នកជំរុញលើកទឹកចិត្តក្នុងការរៀនសូត្រ។ កត្តាផ្សេងៗទៀតក៏ជះឥទ្ធិពលជាវិជ្ជមានដល់ការរៀន និងបង្រៀនភាសាអង់គ្លេសផងដែរដូចជា៖ ការផ្គត់ផ្គង់សៀវភៅសិក្សាគោល ការរៀបចំបន្ទប់អនុវត្តន៍ភាសាអង់គ្លេស ការជំរុញដំណើរការស្រាវជ្រាវ និងស្វ័យសិក្សា។ល។ ផ្អែកលើទឡ្ហីករណ៍ដែលបានលើកឡើងខាងលើនេះ សបញ្ជាក់ឱ្យឃើញថាការអនុវត្តតាមដំណោះស្រាយ ដែលបានរកឃើញគឺពិតជាអាចជួយឱ្យសិស្សទទួលបានលទ្ធផលល្អក្នុងការសិក្សា។ តាមរយៈដំណោះស្រាយទាំងអស់ដែលបានរកឃើញខាងលើ ពិតជាបានឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវក្នុងការស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញសិស្សបន្តខិតខំរៀនសូត្រ។

# Abstract

The research on the topic of "Students' Perceptions on Learning and Teaching English at High School Level in Phnom Penh" aims to study and understand the students' perspectives on teaching and learning of English subjects, and the participation of the school management in strengthening the learning and teaching English in upper secondary levels in Phnom Penh.

Three types of quantitative and qualitative questionnaires were constructed for the 529 students, 28 teachers of English, and 20 school administrators. Ms Excel and SPSS application were used and descriptive statistics were interpreted for the frequency, mean values, and standard deviations.

The findings show that students' perspectives of learning and teaching English at the upper secondary level in Phnom Penh are as follows: Teachers do not have enough teaching aids making it difficult for students to understand the content of the lessons, lack of English practice room, which makes students have no opportunity to develop skills, and students themselves do not pay attention to learning, all of which are the reasons for poor learning outcomes.

However, research has shown that in order to ensure the quality of students' learning outcomes, all stakeholders must be involved, including school management, teachers and students themselves. School managements play important roles in the support of teaching and learning, especially with direct contact with local, national educational entities and development partners. If the management is qualified with their tasks, the teachers will be satisfied to work responsibly and willingly, which leads to good academic results. Teachers are the direct implementers of the curriculum, orienters, advisors, bridges for future professional development, and taking care of students regularly. Only a teacher knows his students well. In addition, the participation of students is also crucial, because although teachers and school directors have done a good job, but students do not cooperate is really hindering the same academic results.

Based on the results of this study, the researchers can conclude that the solution that can help improve the learning and teaching of English is the teacher who implements the curriculum and encourages for learning. Other factors also have a positive effect on learning and teaching English, such as: supply of textbooks and its quality, English lab equipment, promoting the research process and self-study, etc. Based on the above arguments, it is clear that applying the solutions found can really help students achieve good academic results. Through all the solutions found above really respond to the purpose of the research to find effective solutions to motivate students to continue to study hard.

# ជំពូក១

# សេចក្តីផ្តើម

# ជំពូក ១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហា នៃការស្រាវជ្រាវ

ការប្រាស្រ័យទាក់ទងគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងពីជាតិសាសន៍មួយទៅជាតិសាសន៍មួយទៀត គឺមានសារៈសំខាន់ណាស់តាំងពីអតីតកាល ពេលបច្ចុប្បន្ន និងនាពេលអនាគត តាមរយៈការបង្ហាញជាកាយវិការ ពាក្យសម្តី និងពិសេសនោះ គឺភាសា។ មនុស្សជាតិចែករំលែកពីរឿងរ៉ាវ បទពិសោធន៍ ឬសកម្មភាពនានាពីអតីតកាល ហើយផ្ទេរប្រកពទាំងនោះពីជំនាន់មួយទៅជំនាន់មួយ ហើយរឹតតែធ្វើឱ្យក្មេងជំនាន់ក្រោយកាន់តែរកឃើញនូវអ្វីៗដែលថ្មី និងមានបច្ចេកវិទ្យាកាន់តែជឿនលឿនឡើងៗគឺតាមរយៈការប្រើប្រាស់ភាសានេះឯង។ បើយើងក្រឡេកមើលនិន្នាការពិភពលោក មានការប្រើប្រាស់ភាសាក្នុងការប្រាស្រ័យទាក់ទងគ្នាតាមជាតិសាសន៍នីមួយៗ ជាច្រើនបែបសណ្ឋាន ដូចជាភាសាខ្មែរ បារាំង ចិន និងភាសាអង់គ្លេសជាដើម។

តួយ៉ាងនៅប្រទេសកម្ពុជាក្នុងអំឡុងពេលប្រមាណជាជាងម្ភៃឆ្នាំចុងក្រោយនេះ ការសិក្សារៀនសូត្រភាសាបរទេសក៏ត្រូវបានកំពុងតែពេញនិយមជាខ្លាំងសម្រាប់អ្នកជំនួញ អ្នកបច្ចេកទេស អ្នកការទូត និស្សិតនិងសិស្សានុសិស្សស្ទើរគ្រប់កម្រិតថ្នាក់តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា។ ទាំងអស់នេះគឺពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អភិវឌ្ឍន៍ និងផលិតធនធានមនុស្សក្នុងការរួមចំណែកជាមួយរដ្ឋាភិបាលក្នុងកិច្ចការកសាងប្រទេសជាតិដើម្បីឱ្យសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលនយោបាយជាតិនានាផងដែរ។ ដោយមើលឃើញពីសក្តានុពលនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវចក្ខុវិស័យកំណែទម្រង់វិស័យអប់រំ ដែលមានសសរស្តម្ភប្រាំជាមូលដ្ឋាន(ក្រសួងអប់រំ យុវជន និងកីឡា (២០១៩ក)។

តាមរយៈកំណែទម្រង់នេះ វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ពិសេសក្នុងអំឡុងពេលប្រមាណជិត១០ឆ្នាំចុងក្រោយ លើការពង្រឹងការប្រឡងគ្រប់ប្រភេទ។ ជាឧទាហរណ៍ ការប្រឡង

គ្រូបង្រៀនគ្រប់កម្រិត និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានផ្លាស់ប្ដូរឥរិយាបទ មិនត្រឹមតែបុគ្គលិកអប់រំប៉ុណ្ណោះទេ ថែមទាំងនិស្សិត និងសិស្ស (និយាយឱ្យចំបេក្ខជនប្រឡង) ស្ទើរតែទាំងស្រុង ដោយការប្រែក្លាយពីការលួចកែពិន្ទុសិស្ស ជួយសរសេរចម្លើយឱ្យសិស្ស ការគាបសង្កត់សិស្សយកលុយក្នុងអំឡុងពេលប្រឡង ការឱ្យលួចចម្លងឯកសារ ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចក្នុងការប្រឡង ការសូកប៉ាន់គ្រូក្នុងពេលប្រឡង ការផ្លាស់ប្ដូរកិច្ចការ និងកែលទ្ធផលប្រឡង ឱ្យទៅការងាកមករកការខិតខំរៀនសូត្រដោយខ្លួនឯង និងចាប់ផ្ដើមកាន់សៀវភៅឡើងវិញគ្រប់ៗគ្នា ស្ថិតនៅក្រោមពាក្យស្លោកមួយឃ្លារបស់រដ្ឋមន្ត្រីក្រសួងអប់រំបានលើកឡើងថា "អ្នកចេះ គឺជាប់" ។

ជាមួយគ្នានេះដែរ តាមរយៈការពង្រឹងការប្រឡងគ្រប់ប្រភេទនេះ វាពិតជាបានឆ្លុះបញ្ចាំងពីការធានាគុណភាពអប់រំនៅកម្ពុជាដែលឆ្លើយតបទៅនឹងសសរស្ដម្ភទាំង៥ របស់ក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល បរិស្ថានសិក្សា (៣) ការដាក់ឱ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃសិក្សា ដូចជាការប្រឡង វង្វាយតម្លៃថ្នាក់តំបន់ ថ្នាក់ជាតិ និងអន្តរជាតិ (៥) កំណែទម្រង់ឧត្តមសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣)។

ដោយមើលឃើញពីវិសាលភាពនៃការរីកដុះដាលលើការប្រើប្រាស់ភាសាបរទេស ពិសេសភាសាអង់គ្លេស ក្នុងការទំនាក់ទំនងជាមួយអន្តរជាតិ និងទីផ្សារការងារ ក្រសួងអប់រំក៏បានសម្រេចដាក់មុខវិជ្ជាភាសាអង់គ្លេសក្នុង កម្មវិធីសិក្សារបស់រដ្ឋ ដើម្បីបើកនូវទំព័រប្រវត្តិសាស្ត្រលើភាសាបរទេសមួយនេះនៅចុងសតវត្សទី២០។ ដោយផ្អែកលើតម្រូវការរបស់អ្នកសិក្សា ក្រសួងអប់រំបានសម្រេចបន្ថែមមុខវិជ្ជាភាសាអង់គ្លេស ជាមុខវិជ្ជាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០០៦។ ទោះជាយ៉ាងណាក្ដី ការដាក់ភាសាអង់គ្លេសសម្រាប់ការប្រឡងនេះគឺគ្រាន់តែជាមុខវិជ្ជាបន្ថែមពិន្ទុតែប៉ុណ្ណោះ មានន័យថាសិស្សមិនត្រូវបានដកពិន្ទុពីមុខវិជ្ជានេះឡើយ បើទោះបីជាសិស្សធ្វើបាន ឬមិនបានក្ដី ។ ចាប់តាំងពីពេលនោះមកភាសាអង់គ្លេស បានក្លាយ

ជាភាសាដ៏សំខាន់សម្រាប់គ្រូបង្រៀនមុខវិជ្ជានេះ។ យ៉ាងណាមិញ បើយើងក្រលេកមើលលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន អត្រាសិស្សដែលប្រឡងជាប់មានការកើនឡើងជាលំដាប់។ ជាលទ្ធផលក្នុងឆ្នាំ២០១៤ ប្រឡងពីរលើកមានចំនួន ៤២ភាគរយ ឆ្នាំ២០១៥មានចំនួន ៥៥,៨៨ ភាគរយ ឆ្នាំ២០១៦ មានចំនួន ៦២,១៨ ភាគរយ ឆ្នាំ២០១៧ មានចំនួន៦៣,៨៤ភាគរយ ឆ្នាំ ២០១៨ មានចំនួន ៦៧,០៧ ភាគរយ ឆ្នាំ២០១៩ មានចំនួន ៦៨,៥៩ភាគរយ ឆ្នាំ២០២០ មានចំនួន១០០ ភាគរយ(សិស្សជាប់ស្វ័យប្រវត្តដោយមិនបាច់ប្រឡង) ឆ្នាំ២០២១ មានចំនួន៦៥,៦៥ ឆ្នាំ២០២២ មានចំនួន៧២,៣៣ ។ ការកើនឡើងនូវអត្រាសិស្ស ប្រឡងជាប់នេះ ជាផលវិជ្ជមានមួយដែលឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់ភាពអប់រំ ប្រកបដោយប្រសិទ្ធភាព។ តែផ្ទុយទៅវិញ ទោះបីអត្រាសិស្សប្រឡងជាប់មានការកើនឡើង គេនៅតែសង្កេតឃើញថាអត្រាជាប់តាមមុខវិជ្ជានីមួយៗនៅមិនទាន់ល្អនៅឡើយ ដោយមុខវិជ្ជាខ្លះសិស្សបានពិន្ទុល្អប្រសើរ ខ្លះទៀតធ្វើបានពិន្ទុល្អ ខ្លះទៀតធ្វើបានមធ្យម និងខ្លះទៀតនៅខ្សោយនៅឡើយ។

ក្នុងចំណោមមុខវិជ្ជាប្រឡងទាំងអស់នោះ មុខវិជ្ជាដែលសិស្សនៅតែទទួលបានអត្រាទាបជាងគេបំផុតគឺភាសាអង់គ្លេស។ បើយោងតាមលទ្ធផលប្រឡងតាមឆ្នាំនីមួយៗ(២០១៤-២០២២)អត្រាប្រឡងជាប់លើមុខវិជ្ជាភាសាអង់គ្លេសមានភាគរយប្រឡងជាប់ទាបជាងគេបំផុត បើប្រៀបធៀបទៅមុខវិជ្ជាផ្សេងទៀតដូចជា៖ មុខវិជ្ជា អក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ជាដើម ។ ក្នុងនោះដែរតាមរយៈការបញ្ជាក់របស់គណៈគ្រប់គ្រងលើស្ថិតិប្រឡងជាប់តាមមុខវិជ្ជានៅតាមវិទ្យាល័យទាំងប្រាំបួន ក្នុងរាជធានីភ្នំពេញបានឱ្យដឹងថាអត្រាប្រឡងជាប់លើមុខវិជ្ជាភាសាអង់គ្លេសគឺពិតជាមានកម្រិតពិតមែន មិនមែនតែមួយឆ្នាំ ឬពីរឆ្នាំនេះទេ។ គណៈគ្រប់គ្រងបានបន្ថែមថាបើការសង្កេតរបស់គាត់ឃើញថាសិស្សរៀនគួរ ច្រើនលើមុខវិជ្ជាភាសាអង់គ្លេសច្រើនជាងមុខវិជ្ជាផ្សេងៗ តែផ្ទុយទៅវិញបែរជាលទ្ធផលប្រឡងទទួលបានទាបទៅវិញ។ ហេតុនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកប្រធានបទ "ការយល់ឃើញរបស់សិស្ស

ក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ" មកសរសេរដើម្បីស្វែងយល់ និងកំណត់បានពីកម្រិតអនុវត្តទាំងឡាយ ដើម្បីមានមូលដ្ឋានក្នុងការកែលម្អ និងក៏សម្រាប់ទុកឱ្យអ្នកស្រាវជ្រាវជំនាន់ក្រោយបានសិក្សាបន្ត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈលទ្ធផលប្រឡងកន្លងមក យើងសង្កេតឃើញថា ថ្នាក់ក្រសួង ពិសេសលោកគ្រូ អ្នកគ្រូដែលបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ហាក់នៅមិនទាន់ពេញចិត្តនៅឡើយទេ។ នេះជាហេតុដែលធ្វើឱ្យក្រសួងអប់រំបានដាក់ចេញនូវវិធានការជាច្រើនឈានដល់ការសម្រេចដាក់បញ្ចូលកម្មវិធីសិក្សាភាសាអង់គ្លេសចាប់ពីកម្រិតបឋមសិក្សាមកដើម្បីពង្រឹងចំណេះដឹងបន្ថែមទៀតទៅលើមុខវិជ្ជាភាសាអង់គ្លេសនៅកម្ពុជា។ ទោះជាយ៉ាងណាក្តី ការប្រឡងលើមុខវិជ្ជាមួយនេះមិនមែនមានតែសិស្សនៅប្រទេសកម្ពុជា ប៉ុណ្ណោះទេដែលទទួលបានលទ្ធផលមិនសូវល្អ មានសិស្សនៅតំបន់អាស៊ានមួយចំនួនក៏ទទួលបានលទ្ធផលស្រដៀងគ្នានេះដែរ។ តាមរយៈការសិក្សាជាក់ស្តែងនៅសង្គមកម្ពុជា បើយើងក្រឡេកមើលសំទុះនៃការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេស យើងអាចកត់សម្គាល់ឃើញបានថា ភាសាអង់គ្លេសជាមុខវិជ្ជាមួយដែលមានសិស្សចូលចិត្តរៀនច្រើនជាងគេក្នុងចំណោមមុខវិជ្ជាភាសាបរទេសដទៃទៀតទាំងនៅសាលារៀនសាធារណៈ និងនៅសាលារៀនឯកជន។ ជាការពិតបើការនិយមចូលចិត្តរៀនច្រើនបែបនេះ ច្បាស់ណាស់លទ្ធផលនៃការសិក្សាក៏ពិតជាប្រសើរជាក់ជាមិនខាន។ តែផ្ទុយទៅវិញ លទ្ធផលដែលទទួលបានមកវិញនៅតែមានកម្រិតមិនគួរឱ្យជឿទាល់តែសោះ។ ទាំងនេះហើយទើបធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវ ចង់ស្វែងរកឫសគល់ឱ្យកាន់តែស៊ីជម្រៅដើម្បីកែលម្អលទ្ធផលសិក្សាភាសាអង់គ្លេស ដែលអាចធ្វើឱ្យសិស្សចាប់យកអាជីពធ្វើការងារខ្លួនឱ្យមានការលូតលាស់ និងរីកធំធាត់បាននាពេលអនាគត។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

បន្ទាប់ពីក្រសួងធ្វើកំណែទម្រង់លើវិស័យអប់រំដោយផ្អែកលើសសរស្តម្ភទាំងប្រាំ ជាលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានផ្លាស់ប្តូរមករកគុណភាពមួយដែលមិនត្រឹមតែប្រមុខថ្នាក់ ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លោកគ្រូ-អ្នកគ្រូ និងអាណាព្យាបាលប៉ុណ្ណោះទេ ថែមទាំងគ្រប់ភាគីពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍក៏បានទទួលស្គាល់ពីលទ្ធផល និងគុណភាពរបស់សិស្សដែលបានប្រឡងជាប់។ ទោះជាយ៉ាងណាក៏ដោយ ក៏លទ្ធផលតាមមុខវិជ្ជាប្រឡងមួយចំនួនបានល្អ និងមួយចំនួននៅមានកម្រិតនៅឡើយ។ ដោយឡែកចំពោះមុខវិជ្ជាភាសាអង់គ្លេសសង្កេតឃើញថា លទ្ធផលប្រឡងជាប់នៅតែជាបញ្ហាប្រឈមសម្រាប់សិស្សទាំងអស់នៅឡើយ។ ដោយឈរលើឆន្ទៈ និងទំនួលខុសត្រូវលើជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ទើបខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ដោយផ្តោតលើគោលបំណងសំខាន់ៗបីគឺ៖

១. ស្វែងយល់ពីការយល់ឃើញរបស់សិស្សលើការបង្រៀនរបស់លោកគ្រូអ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។

២. ស្វែងយល់ពីឥរិយាបទគ្រូលើការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។

៣. ស្វែងយល់ពីការចូលរួមរបស់គណៈគ្រប់គ្រងលើការពង្រឹងការរៀននិងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ អ្នកស្រាវជ្រាវចង់ស្វែងយល់អំពីការរៀន និងបង្រៀនភាសាអង់គ្លេស នៅកម្រិតមធ្យមសិក្សាទុតិយភូមិដោយឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

១. តាមការយល់ឃើញរបស់សិស្ស តើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញមានលក្ខណៈបែបណាដែរ?

២. តើតួនាទីគ្រូលើការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញមានអ្វីខ្លះ?

៣.តើការចូលរួមរបស់គណៈគ្រប់គ្រងលើការពង្រឹងការរៀននិងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញមានសភាពបែបណាដែរ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ដើម្បីកំណត់បានពីស្ថានភាពរៀន និងបង្រៀនភាសាអង់គ្លេសសិស្សមធ្យមសិក្សាទុតិយភូមិ និងដំណោះស្រាយឱ្យមានប្រសិទ្ធភាពក្នុងការជំរុញឱ្យលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លើមុខវិជ្ជាភាសាអង់គ្លេសឱ្យកាន់តែល្អ។ ទើបការសិក្សាស្រាវជ្រាវមួយនេះ នឹងក្លាយជាសូចនាករដ៏សំខាន់សម្រាប់ជួយជ្រោមជ្រែងដល់អ្នកដែលមានអាជីពជាគ្រូបង្រៀនភាសាអង់គ្លេស ដើម្បីធ្វើឱ្យគាត់មានភាពងាយស្រួលក្នុងការបង្រៀន និងជួយសម្រួលដល់ការតម្រង់ទិសសិស្សឱ្យឆាប់ចាប់បាននូវចំណេះដឹងផ្នែកភាសាអង់គ្លេសយ៉ាងពិតប្រាកដ និងមានប្រសិទ្ធភាព ដើម្បីឈានទៅរកការទទួលបានលទ្ធផលដ៏ល្អប្រសើរក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។

## ១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីការយល់ឃើញរបស់សិស្សលើការរៀន និងបង្រៀនភាសាអង់គ្លេសគ្របដណ្តប់នៅតាមវិទ្យាល័យចំនួន០៩នៅរាជធានីភ្នំពេញក្នុងឆ្នាំសិក្សា២០២២-២០២៣។ សំណាកដែលបានជ្រើសរើសមានដូចតទៅ៖ គ្រូបង្រៀនភាសាអង់គ្លេសចំនួន២៨នាក់ គណៈគ្រប់គ្រងសាលា២០នាក់ និងសិស្សានុសិស្សចំនួន៥២៩នាក់។ ដោយផ្អែកលើសំណាកដែលបានកំណត់នេះ អ្នកស្រាវជ្រាវបានផលិតកម្រងសំណួរបិទ និង សំណួរបើក សម្រាប់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា ទាំង

អស់។ ក្នុងកម្រងសំណួរទាំងនោះត្រូវបានបែងចែកពីរផ្នែកសំខាន់ៗគឺ ៖ ផ្នែកទី១ ៖ ព័ត៌មានផ្ទាល់ខ្លួនរបស់ជាតុសំណាក ផ្នែកទី២ ទិន្នន័យស្រាវជ្រាវ។ មូលហេតុដែលអ្នកស្រាវជ្រាវ សម្រេចយកសំណាកទាំង៣តួអង្គនេះព្រោះអ្នកសិក្សាស្រាវជ្រាវចង់សិក្សាស្វែងយល់ទស្សនៈយល់ឃើញ របស់ជាតុសំណាកដែលអាចប្រើប្រាស់បានជាជាតុចូលក្នុងការកសាងផែនការដើម្បីជម្រុញឱ្យលទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសបានកាន់តែប្រសើរឡើង។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៥ជំពូក៖

ជំពូកទី១៖ សេចក្តីផ្តើម ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២៖ រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានសិក្សាលើនិយមន័យពាក្យគន្លឹះសិក្សា ទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ... ឯកសារគតិយុត្តិនានា និងអត្ថបទស្រាវជ្រាវដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ។

ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនិងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម។

ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវលទ្ធផលនៃការស្រាវជ្រាវ តាមរយៈកម្រងសំណួរ និងការពិភាក្សាលើលទ្ធផល។

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ ធ្វើសេចក្តីសន្និដ្ឋាន ឆ្លើយតបទៅលើសំនួរស្រាវជ្រាវដោយបង្ហាញលទ្ធផលតាមរយៈទិន្នន័យដែលបានពីកម្រងសំណួរ និងការសង្ខេបខ្លឹមសារពិភាក្សាតាមរយៈការឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាននិងចំណុចត្រូវកែលម្អ។ លើកសំណូមពរតាមរយៈប្រធានបទសិក្សា ដល់ភាគី

ពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវបន្តនៅថ្ងៃអនាគត ដើម្បីពង្រីកវិសាលភាពនៃលទ្ធផលលើប្រធានបទដែលបានលើកយកមកសិក្សាស្រាវជ្រាវរួច។

# ជំពូក២
# ការរំលឹកទ្រឹស្តី

# ជំពូក ២
# ការរំលឹកទ្រឹស្តី

នៅក្នុងការសិក្សាការយល់ឃើញរបស់សិស្សលើការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានសិក្សាឯកសារពាក់ព័ន្ធនឹងប្រធានបទ រួមមានគុណលក្ខណៈគណៈគ្រប់គ្រងក្នុងការពង្រឹងលើការរៀននិងបង្រៀនភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សា ការពង្រឹងលើកម្មវិធីសិក្សាភាសាអង់គ្លេស ស្ថានភាពនៃការប្រើវិធីសាស្ត្របង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងពិសេសជាងនោះទៀតគឺកត្តាឥរិយាបទសិស្សក្នុងការរៀនភាសាអង់គ្លេសផ្ទាល់តែម្តង។

## ២.១ ការសិក្សាពាក្យគន្លឹះ

ការរៀន៖ គឺជាទង្វើនៃការទទួលបានអ្វីមួយថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធ និងការសំយោគព័ត៌មានប្រភេទផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំ ចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។ ការសិក្សា គឺជាសកម្មភាពរបស់សិស្សម្នាក់ៗដែលចង់បានចំណេះដឹងសម្រាប់យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឲ្យកាន់តែមានភាពប្រសើរឡើង ពោលគឺធ្វើឲ្យមានការផ្លាស់ប្តូរជីវិតរស់នៅទាំងឥរិយាបទ ស្មារតី បញ្ញា សតិសម្បជញ្ញៈ។

ការបង្រៀន៖ ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តសិស្សឲ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ដល់សិស្សគ្រប់រូប។ សកម្មភាពនៃការបង្រៀនរួមមាន ការពន្យល់ ការចោទជាបញ្ហា ការសួររកហេតុនិងផល ការលើកទឹកចិត្ត ការតាមដានសាវតាររបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចិត្តគរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដទៃទៀតចាំបាច់ត្រូវតែបន្តការស្រាវជ្រាវរកអ្វីដែលថ្មី អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងការបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំ

បច្ចេកទេស, ២០១៥) ។ Modern Concept បានលើកឡើងថា ការបង្រៀនគឺជាបុព្វហេតុដែលជំរុញឲ្យសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះដឹង បទពិសោធន៍ និងមធ្យោបាយសម្រាប់ការរស់នៅរបស់ខ្លួនជាមួយសង្គមឲ្យបានសមស្របទៅតាមបំណងប្រាថ្នាដែលពួកគេចង់បានផងដែរ។ ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការបង្រៀនគឺសិស្សនិងអ្វីដែលពួកគេត្រូវរៀន។ (Dr.A.H.Sequeira, 2002)។

ការរៀន៖ គឺជាកិច្ចការរបស់គ្រូក្នុងការប្រើប្រាស់ចំណេះដឹងរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់សិស្សឲ្យមានភាពល្អប្រសើរ (Thomas Green)។ ការបង្រៀន គឺជាសកម្មភាពនៃការចែករំលែក ការអប់រំដល់អ្នកសិក្សាក្នុងថ្នាក់រៀនមួយ (Traditional Teaching) ។ ការបង្រៀន គឺជាការយកចិត្តដាក់ទៅលើសកម្មភាពរបស់សិស្សរួមមាន សកម្មភាពលេង និងការបង្កើតថ្មី ឬរបកគំហើញ (Paul H.Hirst, 2004)។

Hang-Chuon, (2020) បានលើកឡើងថាការបង្រៀនគឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យពួកគេចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រទំនើប ដូចជាសហការ...។ មិនតែប៉ុណ្ណោះ ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សា ។ ម្យ៉ាងទៀតការបង្រៀនត្រូវផ្សារភ្ជាប់នឹងបរិស្ថានជុំវិញ តាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេស រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព ។

## ២.២ តួនាទីអ្នកដឹកនាំ លើការរៀន និងបង្រៀន

### ២.២.១ ទស្សនទានការដឹកនាំគ្រប់គ្រងសាលារៀន

ការអនុវត្តន៍ការដឹកនាំ និងគ្រប់គ្រងសាលារៀនតែងតែទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខុសៗគ្នានៅតាមប្រទេស និងទីកន្លែងផ្សេងៗគ្នា។ មូលហេតុទាំងនេះ អាចស្តែងចេញពីកត្តាជាច្រើន ដូចជាធនធាន

ដែលមានរយៈពេលអនុវត្តន៍ និងកត្តាវប្បធម៌នៅកន្លែងនោះ។ តាមរយៈនេះហើយដែលធ្វើអោយយើងមើលឃើញថាលទ្ធផលនៃការរៀន និងបង្រៀនតាមសាលានីមួយៗទទួលបានផ្សេងៗគ្នានៅតាមកន្លែង និងបរិបទផ្សេងៗគ្នា។ ការកើនឡើងនៃសិទ្ធិស្វ័យភាពគ្រប់គ្រង និងការទទួលខុសត្រូវរបស់សាលារៀនកាន់តែមានទំហំធំ ក៏អាចមានឥទ្ធិពលអវិជ្ជមានមួយចំនួនផងដែរ។ ដូច្នេះហើយ អ្នកដឹកនាំសាលារៀនក្នុងសតវត្សន៍ទី២១នេះត្រូវមានគំរូដឹកនាំមួយដែលអាចចែកចាយក៏ដូចជាបង្កើតអ្នកដឹកនាំជំនាន់ក្រោយ ដើម្បីឲ្យមានការទទួលខុសត្រូវរួម និងអភិវឌ្ឍន៍សមត្ថភាព (Beatriz, Deborah & Hunter, 2008)។

ការសិក្សាយ៉ាងច្បាស់លាស់មួយបានរកឃើញថា មានចំណុចនៃការដឹកនាំសាលារៀន ដែលមានប្រសិទ្ធភាពចំនួនប្រាំពីរដែលត្រូវបានអនុវត្ត ហើយមានទំនាក់ទំនងនឹងការរៀនសូត្ររបស់ក្មេង (Leithwood, Harris & Hopkins, 2008)។ គុណសម្បត្តិទាំងប្រាំពីរនោះរួមមាន៖ (១)ការដឹកនាំអាចមានឥទ្ធិពលលើការរៀនសូត្ររបស់សិស្ស ប៉ុន្តែការបង្រៀនក្នុងថ្នាក់ គឺកាន់តែជាចំណុចសំខាន់។ (២)ស្ទើតែគ្រប់អ្នកដឹកនាំទាំងអស់យ៉ាងហោចណាស់ អនុវត្តនូវការដឹកនាំមូលដ្ឋានក្នុងដំណើរការគ្រប់គ្រងសាលារៀន។ (៣)ការអនុវត្តន៍មូលដ្ឋានគ្រឹះការដឹកនាំទៀតសោត គឺអាស្រ័យសំខាន់ទៅលើបរិបទជាក់ស្តែងដែលអ្នកដឹកនាំកំពុងធ្វើការ មិនមែនតាមរយៈការទន្ទេញចងចាំក្បួនខ្នាតនៃការដឹកនាំនោះឡើយ។ (៤)នាយកសាលារៀននីមួយៗពង្រឹងគុណភាពការរៀន និងបង្រៀនដោយប្រយោល និងមានប្រសិទ្ធភាពបំផុតតាមរយៈការលើកទឹកចិត្តបុគ្គលិកបង្កើតអោយមានការប្តេជ្ញាចិត្ត និងបរិយាកាសការងារល្អ។ (៥)ការដឹកនាំសាលាមានឥទ្ធិពលខ្លាំងបំផុតចំពោះសាលារៀន និងការរៀនសូត្ររបស់សិស្ស ពេលដែលមានបែងចែកការដឹកនាំទៅដល់គ្រប់អ្នកពាក់ព័ន្ធក្នុងកិច្ចដំណើរការបង្រៀន និងរៀន។ (៦)ទំរង់បែងចែកការដឹកនាំទៅដល់គ្រប់អ្នកពាក់ព័ន្ធក្នុងកិច្ចដំណើរការបង្រៀន និងរៀន តែងតែមានកម្រិតប្រសិទ្ធភាពខុសៗគ្នា។(៧)ចរិកលក្ខណៈបុគ្គលដឹកនាំអាចពន្យល់អំពីកម្រិតប្រែប្រួលនៃប្រសិទ្ធភាពដឹកនាំក្នុងកិច្ចដំណើរការបង្រៀន និងរៀន។

ការអនុវត្តន៍នូវគុណសម្បត្តិការដឹកនាំខាងលើតែងតែមានដំណាក់កាល និងចំណុចសំខាន់ៗដើម្បីឆ្លុះបញ្ចាំងពីភាពជោគជ័យរបស់វា។ ត្រង់ចំណុចគុណសម្បត្តិទី២ និងទី៣ មានការអនុវត្តសកម្មភាពដូចគ្នាដើម្បីទទួលបានលទ្ធផល ដែលក្នុងនោះរួមមាន៖ ការបង្កើតឲ្យមានទស្សនវិស័យ និងទិសដៅ ការស្វែងយល់ពីបុគ្គលិកសិក្សា និងអភិវឌ្ឍន៍សមត្ថភាពពួកគេ ការរៀបចំឡើងវិញនូវការដឹកនាំ និងគ្រប់គ្រងសាលារៀន ព្រមទាំងការគ្រប់គ្រងកម្មវិធីរៀន និងបង្រៀន (Leithwood, Harris & Hopkins, 2008)។ បន្ថែមលើនេះទៀត Leithwood បានបញ្ជាក់យ៉ាងច្បាស់ថា ទំនាក់ទំនងនៃការដឹកនាំ និងគ្រប់គ្រងសាលា នឹងលទ្ធផលរៀនសូត្ររបស់សិស្សវាអាស្រ័យសំខាន់លើការខិតខំប្រឹងប្រែងរបស់គ្រូបង្រៀនផងដែរ។

ការសិក្សា និងស្ទង់មតិមួយនៅសហរដ្ឋអាមេរិកអំពីឥទ្ធិពលនៃការដឹកនាំរបស់នាយកសាលាបានបង្ហាញស្រដៀងទៅនឹងអ្វីដែលបានលើកឡើងខាងលើ ហើយលទ្ធផលនេះប្រហែល ជាមានភាពប្រាកដប្រជាច្រើន ហើយលទ្ធផលបញ្ជាក់យ៉ាងច្បាស់ថា ការដឹកនាំរបស់នាយកសាលា មានឥទ្ធិពលដោយប្រយោលទៅលើលទ្ធផលសិក្សារបស់សិស្ស តាមរយៈការបង្រៀន និងការទុកចិត្តរបស់គ្រូចំពោះការដឹកនាំរបស់នាយកសាលា (Seashore Louis, Dretzke, & Wahlstrom, 2010) តាមរយៈលទ្ធផលនេះ លទ្ធផលសិក្សារបស់សិស្សគឺអាចស្តែងចេញពីទំនាក់ទំនងរវាងនាយកសាលា និងគ្រូបង្រៀនយ៉ាងប្រាកដ ដែលនេះជាលទ្ធផលនៃការអនុវត្តន៍គោលការណ៍ដឹកនាំមួយចំនួនដូចជា៖ ការដឹកនាំបែបចែករំលែក និងផ្តល់យោបល់អោយសហសេវិកអនុវត្តតាម។ ការចែករំលែកបទពិសោធន៍នៃការដឹកនាំ ក៏ដូចជាការបង្រៀនរបស់នាយកសាលានេះ បានបង្កើតអោយមានទំនាក់ទំនង និងវប្បធម៌យោគយល់យ៉ាងល្អប្រសើរ ហើយបង្កើតបានជាបរិយាកាសសម្រាប់ការអប់រំយ៉ាងមានប្រសិទ្ធភាពដល់សិស្សានុសិស្ស (MacNeil, Prater, & Busch, 2009)។ ទាំងនេះបង្ហាញយ៉ាងច្បាស់អំពីឥទ្ធិពលនៃការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាទៅលើលទ្ធផលសិក្សារបស់សិស្ស។

### ២.២.២ ការទទួលខុសត្រូវរបស់នាយកសាលារៀន

ដើម្បីដំណើរការការងាររបស់ខ្លួនបានល្អ នាយកសាលាមានភារកិច្ចទទួលខុសត្រូវលើការងាររដ្ឋបាល ការងារបច្ចេកទេស គរុកោសល្យ និងការងារទំនាក់ទំនង។ ភារកិច្ចទាំងនេះត្រូវបាលគេទទួលស្គាល់ថា មានឥទ្ធិពលខ្លាំងចំពោះប្រសិទ្ធិភាពការបង្រៀនរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សានុសិស្ស។ ក្នុងន័យនេះដែរ ភារកិច្ចសំខាន់ទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងក្នុងការធានានូវភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដែលធ្វើឲ្យគ្រូមានសមត្ថភាពបច្ចេកទេសបង្រៀនបានល្អ ការលើកទឹកចិត្ត និងការប្តេជ្ញាចិត្ត ក៏ដូចជាបរិយាកាសការងារសមស្រប (ចៅ លិន, ២០១១)។

ចៅ លិន, (២០១១) បានបកស្រាយតួនាទីជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡារបស់នាយកសាលាថាជាអ្នកធានាទាក់ទងការងាររវាងសាលារៀន និងថ្នាក់លើ ជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ញាសិក្សា។ នាយកសាលារៀនទទួលខុសត្រូវទាំងស្រុងចំពោះមុខសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើតមានឡើងក្នុងសមត្ថកិច្ចរបស់ខ្លួន។

ក្នុងនាមជាមន្ត្រីរដ្ឋបាលម្នាក់ នាយកជាអ្នកណែនាំអនុវត្តរដ្ឋបាលសិក្សាទាំងអស់ក្នុងសាលារៀនជានាធ្វើឱ្យសម្រេចគោលនយោបាយអប់រំដោយរិះរកគ្រប់មធ្យោបាយ និងវិធានការចាំបាច់ដើម្បីធ្វើឱ្យសកម្មភាពប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ (ចៅ លិន, ២០១១)។

ជាទីប្រឹក្សាគរុកោសល្យម្នាក់ នាយកសាលាមានសិទ្ធអំណាចណែនាំគរុកោសល្យដល់គ្រូក្រោមឱវាទនូវល្បិច និងគន្លឹះល្អៗនៃការបង្រៀន។ នាយកសាលាអាចបំពេញភារកិច្ចនេះបាន លុះត្រាតែជានិច្ចកាលស្វ័យសិក្សា និងអភិវឌ្ឍសម្បទាចិត្តគរុកោសល្យគ្មានឈប់ឈរ។ គ្រូបង្រៀនតែងផ្តល់កិត្តិយស និងគោរពនាយកសាលារៀនណាដែលមានសម្បទាអាចធានាការរៀបចំគរុកោសល្យបានល្អ (ចៅ លិន, ២០១១)។

ជាអធិការអេចិន្ត្រៃយ៍ នាយកសាលាមានសិទ្ធិត្រួតពិនិត្យ និងជួយកែលំអសកម្មភាពបង្រៀន និងរៀន ដោយផ្ទាល់។ នាយកសាលា ជាអ្នកណែនាំបន្តលើការកែលំអ និងវាយតម្លៃលទ្ធផលលើការបង្រៀន ដើម្បីឱ្យបានសម្រេចទៅតាមស្មារតីនៃការណែនាំរបស់អធិការអប់រំ (ចៅ លិន, ២០១១)។

## ២.៣ ការអនុវត្តកម្មវិធីសិក្សា

កម្មវិធីសិក្សាគឺជាផែនការដើម្បីសម្រេចគោលដៅ Ornstein and Hurkins (2018)។ កម្មវិធីសិក្សាគឺជាផែនការសម្រាប់ផ្តល់នូវឱកាសរៀនសូត្រសម្រាប់មនុស្សដែលត្រូវទទួលបានការអប់រំ MIHUI(J. Galen Saylor, William Alexander, and Arthur Lewis)។ កម្មវិធីសិក្សាគឺជាដំណើរការនៃការអភិវឌ្ឍ ដែលមានការកំណត់ពីទស្សនវិជ្ជា ការវាយតម្លៃ សមត្ថភាពសិស្ស ការពិចារណាពីវិធីសាស្ត្រសម្រាប់ធ្វើការណែនាំ យុទ្ធសាស្ត្រសម្រាប់អនុវត្ត ជ្រើសរើសឧបករណ៍សម្រាប់វាយតម្លៃ និងកែលម្អជាបន្តបន្ទាប់(David Pratt Jon Wiles and Joseph Bondi)។

យោងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស(ឆ្នាំ ២០១៥) កម្មវិធីសិក្សាភាសាអង់គ្លេសត្រូវបានបែងចែកយ៉ាងច្បាស់លាស់នៅគ្រប់កម្រិតសិក្សាចាប់ពីថ្នាក់ទី៤ ដល់ថ្នាក់ទី១២។ ផងដែរដោយយោងតាមឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១១ និងទី១២ (ឆ្នាំ ២០១១) ការអនុវត្តម៉ោងបង្រៀនមានចំនួន២ម៉ោងក្នុងមួយសប្តាហ៍ ស្មើនឹង ៧៦ ម៉ោងក្នុងមួយឆ្នាំសិក្សា ដោយគ្របដណ្តប់លើ ១៣ ជំពូក និង ៦៩ មេរៀន។

ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅ សិក្សាគោល គឺជាចំណុចសំខាន់មួយដើម្បីធានាបាននូវគុណភាពនៃការអប់រំ ការសិក្សានៅក្នុងផ្នែកនេះសំដៅទៅលើគុណភាពនៃការអប់រំ ហើយគុណភាពនោះ វាកើតចេញពីការបង្រៀននៅក្នុងថ្នាក់រៀន របស់សិស្ស និងគ្រូប្រកបដោយប្រសិទ្ធភាព។ គុណភាពនៃការអប់រំ គឺជាអ្វីដែលកើតឡើងពីការបង្រៀន មានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀន គ្រូបង្រៀនជួយសិស្សរាល់គ្នាឱ្យដឹង ឬស្គាល់ពីគោលបំណងរបស់ខ្លួន ស្វ័យភាពក្នុងការគិតពិចារណា មានគំនិតចាស់ទុំ សមត្ថភាពគិតបានស៊ីជម្រៅ

មានការខិតខំប្រឹងប្រែង និងដឹងពីតម្លៃនៃការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ គឺជាគោលបំណងសំខាន់បំផុតនៃការអប់រំ ដែលវាជាទិដ្ឋភាពនៃគុណភាពអប់រំ( Reimers, 2020 )។

យោងតាមក្រសួង អ.យ.ក(២០១៨ក) បញ្ហាអវត្តមានខ្ពស់របស់គ្រូបង្រៀន គឺជាបញ្ហាចម្បងមួយនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នោះក៏ជាមូលហេតុនាំឱ្យមានការអនុវត្តកម្មវិធីសិក្សាមិនបានពេញលេញ។

អវត្តមានរបស់គ្រូមានឥទ្ធិពលធំទូលាយ ពិសេសនឹងមានឥទ្ធិពលលើប្រព័ន្ធអប់រំរបស់ប្រទេសទាំងមូល Ameeg ( 2018 )។

របាយការណ៍ ដែលចេញដោយធនាគារពិភពលោកក្នុងឆ្នាំ ២០១៥ អំពីអវត្តមានរបស់គ្រូបង្រៀននៅអាស៊ី បានស្វែងយល់ថាម្ចាស់ជំនួយផ្តល់សម្ភារៈសិក្សា សៀវភៅសិក្សា ដើម្បីកសាងប្រទេសរបស់ពួកគេ ទោះយ៉ាងណាប្រសិនបើគ្រូអវត្តមានពីសាលាជាទៀងទាត់ នោះសិស្សមិនអាចរៀនបានត្រឹមត្រូវទេ... វាជាការខ្ជះខ្ជាយនូវថវិកាយ៉ាងច្រើន។ នៅក្នុងរបាយការណ៍នេះក៏ត្រូវបានអះអាងថាគ្រូបង្រៀននៅកម្រិតវិទ្យាល័យការអវត្តមានរបស់ពួកគេពីប្រព័ន្ធសាលារៀន នឹងប៉ះពាល់ដល់បញ្ហាសំខាន់ៗសម្រាប់ការគ្រប់គ្រងគុណភាពការធ្លាក់ចុះនៃស្មារតីសីលធម៌ និងទំនួលខុសត្រូវក្នុងការអប់រំ។

យោងតាមអនុក្រឹត្យរាជរដ្ឋាភិបាលកម្ពុជា (២០១៧) បានបង្ហាញថា តាមនិយាមគ្រូបង្រៀនម្នាក់ ត្រូវបង្រៀនទ្រឹស្តីប្រចាំសប្តាហ៍ ១៦ម៉ោង សិក្សាក្នុងមួយសប្តាហ៍ និងម៉ោងណែនាំអនុវត្តរៀបចំការងារបង្រៀន ១៨ម៉ោងក្នុងមួយសប្តាហ៍ សម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ។ តាមការរំពឹងទុករបស់អ្នករៀបចំកម្មវិធីសិក្សាចំនួនម៉ោង បង្រៀនតាមទ្រឹស្តី គឺគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សឱ្យទទួលបានលទ្ធផលល្អ ផ្ទុយមកវិញ សាលារៀន និងថ្នាក់រៀនភាគច្រើនត្រូវបានគេសង្កេតឃើញថា មានការបាត់បង់ម៉ោងសិក្សា។ ម៉ោងសិក្សាដែលអនុវត្តជាក់ស្តែង អាចខុសពីម៉ោងរំពឹងទុកដោយមូលហេតុផ្សេងៗដែលមូលហេតុភាគច្រើនរួមមាន ៖ អវត្តមាន សិស្ស ការមករៀនយឺតរបស់សិស្ស និងមូលហេតុជាច្រើនធ្វើឱ្យសាលារៀនបិទទ្វារ ឬកែប្រែកម្មវិធី

បង្រៀន ដែលធ្លាប់បង្រៀនធម្មតា ដោយសារអវត្តមានរបស់គ្រូ គ្រោះធម្មជាតិ។ លើសពីនេះ សូម្បីតែនៅពេលដែលថ្នាក់រៀនបានដំណើរការ សិស្សមានវត្តមាននៅក្នុងថ្នាក់ទៅហើយក្តី ក៏ការបាត់បង់ម៉ោងបង្រៀននៅតែកើត មានជាញឹកញាប់ ដោយសារសិស្សមិនមានវិន័យគ្រូត្រូវចំណាយពេលវេលារក្សាសណ្តាប់ធ្នាប់ ជាងការងារបង្រៀន(ក្រសួង អ.យ.ក ២០១៨ខ)។

ក្នុងការអនុវត្តនៅកម្មវិធីសិក្សានាពេលបច្ចុប្បន្ន ទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនបន្ថែមទៀតទៅលើកម្មវិធីសិក្សា ជំនាញឯកទេស វិធីសាស្ត្របង្រៀន ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការប្រើប្រាស់សម្ភារឧបទេសជំនួយការបង្រៀន Hang-Chuon, (2018)។ ទាំងអស់នេះវាជាសមាសធាតុចាំបាច់ដែលគ្រូបង្រៀនម្នាក់ៗត្រូវតែមាន ដើម្បីបំពេញតម្រូវការឱ្យសិស្សដើម្បីឆ្លើយតបទៅនឹងបរិបទនាពេលបច្ចុប្បន្ន។

កម្មវិធីសិក្សា ដែលមិនបានផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស និងមិនបានផ្តល់ឱ្យសិស្សនូវសមត្ថភាពគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងបន្តការសិក្សារបស់ពួកគេទៅថ្នាក់ឧត្តមសិក្សា។ ការធ្វើកំណែទម្រង់កម្មវិធីសិក្សាសំដៅទៅដល់ការប្រើប្រាស់ ឯកសារកម្មវិធីសិក្សារបស់គ្រូបង្រៀន សាលរៀនឱ្យបានល្អប្រសើរ ដូចជាគោលនយោបាយ ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតសាលារៀន ត្រូវផ្តោតការយកចិត្តទុកដាក់ដល់លទ្ធផលសិក្សារបស់សិស្ស ឯគ្រូបង្រៀនត្រូវមានសមត្ថភាពស្រាវជ្រាវទាំងជំនាញឯកទេស (មុខវិជ្ជាបង្រៀន) និងកែលម្អវិធីសាស្ត្រ និងដំណើរការបង្រៀនឱ្យកាន់តែប្រសើរ Hang-Chuon, (2018)។

## ២.៤ គុណភាពគ្រូបង្រៀនសតវត្សទី ២១

កត្តាគ្រូក្នុងការដឹកនាំសកម្មភាពចូលរួមរៀនសូត្រនៅក្នុងថ្នាក់រៀន ជាកត្តាចាំបាច់ដែលជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្ស មានជាអាទិ៍ដូចជាវិធីសាស្ត្របង្រៀន សម្ភារឧបទេសជំនួយការបង្រៀន ការ

យកចិត្តទុកដាក់លើការរៀនរបស់សិស្សទាំងផ្នែកវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា(ក្រសួង អ.យ.ក ២០១៩)។

អ្វីៗជាច្រើនក្នុងសតវត្សទី២១ កំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីមួយថ្ងៃទៅមួយថ្ងៃទាំងការអភិវឌ្ឍ សេដ្ឋកិច្ច ការធ្វើអាជីវកម្ម កសិកម្ម បច្ចេកវិទ្យា និងការអប់រំ ។ ការអភិវឌ្ឍសមត្ថភាពគឺត្រូវការជាចាំបាច់ ដើម្បីបំពេញតាមតម្រូវការ ពិសេសគ្រូបង្រៀនដែលជាវិស្វករព្រលឹងត្រូវតែខិតខំអភិវឌ្ឍសមត្ថភាពក្នុងការជំរុញលទ្ធផលសិក្សារបស់ឱ្យបានល្អ ជៀសវាងការបង្រៀនសិស្សដោយប្រើប្រាស់វិធីសាស្រ្តបង្រៀនហួសសម័យ "សិស្សសតវត្សទី២១ គ្រូសតវត្សទី២០" ។ ដោយយោងតាម Hafsha Jan (2017) បានលើកឡើងថា "គ្រូបង្រៀននៅសតវត្សរ៍ទី២១ ត្រូវបង្កើតសិស្សសតវត្សទី ២១" ដូចគ្នា។ គ្រូនៅសតវត្សទី ២១ ត្រូវការការច្នៃប្រឌិតខ្ពស់ ដូចជាការរួមបញ្ចូលការបង្រៀនជាមួយបច្ចេកវិទ្យាជាដើម។ លោកបានបន្ថែមថា គុណភាពគ្រូជាអ្នកកំណត់គុណភាពអប់រំនិងផ្សារភ្ជាប់ជាមួយការអភិវឌ្ឍន៍ប្រទេស។

### ២.៤.១ លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនសតវត្សទី២១

គ្រូល្អអាចជំរុញក្តីសង្ឃឹម រំញោចការស្រមើស្រម៉ៃនិងបង្កើតឱ្យមានសេចក្តីស្រឡាញ់ក្នុងការរៀនសូត្រ Hafsha Jan (2017)។ គ្រូបង្រៀនសតវត្សទី២១ ត្រូវគិតគូរពីតម្រូវការរបស់សិស្ស និងរៀបសិស្សឱ្យសមស្របទៅនឹងឧបនិស្ស័យរបស់ពួកគេ។ ការងាររបស់គ្រូត្រូវបានចាត់ទុកថាស្មុគស្មាញនិងទាមទារការបង្កើតជំនាញវិជ្ជាជីវៈដែលមានគុណភាពខ្ពស់និងបញ្ចូលការធ្វើសមាហរណកម្ម បច្ចេកវិទ្យាក្នុងការបង្រៀន។ លក្ខណៈសម្បត្តិ ១៣យ៉ាងរបស់គ្រូបង្រៀនសតវត្សទី២១ មានដូចជា៖(១)ប្រើប្រាស់វិធីសាស្រ្តសិស្សមជ្ឈមណ្ឌល និងស្វែងយល់ពីសិស្ស Learner-centered classroom and Personalized Instructions (២)សិស្សជាផលិតករ Students as Producers (៣)ការរៀបចំផែនការសិក្សា Project-Based Learning (៤)ការសិក្សាពីបច្ចេកវិទ្យាថ្មីៗ Learning new technologies (៥)សាកលភាវូបនីយកម្ម Go Global (៦)ភាពវាងវៃ និង

ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចឆ្លាតវៃ Be smart and use smart phone (៧)បង្កើត Blog (៨)ឌីជីថល Go Digital (៩)កិច្ចសហការ គ្រូ-សិស្ស Collaborate (១០)ប្រើTwitter, Telegram, Messenger chat (១១)មានការភ្ជាប់ទំនាក់ទំនងជាប្រចាំ connect (១២)កសាងគន្លង ឌីជីថល វិជ្ជមាន Build positive Digital Footprint (១៣)ច្នៃប្រឌិត Innovate, Hafsha Jan (2017)។

### ២.៤.២ វិធីសាស្ត្ររបស់គ្រូបង្រៀនសតវត្សទី២១

គ្រូបង្រៀនដែលបានប្រើវិធីសាស្ត្របង្រៀនទទួលបានលទ្ធផលល្អនៅឆ្នាំចាស់ មិនប្រាកដថាទទួលបានជោគជ័យនៅឆ្នាំបន្តបន្ទាប់នោះទេ(ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។ គ្រូបង្រៀនសតវត្សទី២១ ត្រូវបណ្ដុះសិស្សឱ្យមានជំនាញក្នុងការត្រិះរិះពិចារណា និងចេះស្វ័យសិក្សាដោយខ្លួនឯង ជាពិសេសត្រូវបង្រៀនសិស្សឱ្យចេះធ្វើសំយោគ វិនិច្ឆ័យ និងចេះវាយតម្លៃទៅលើកិច្ចការរបស់ខ្លួនប្រកបដោយភាពវៃឆ្លាត និងការបង្កើតថ្មី (វិទ្យាស្ថានជាតិអប់រំ ២០២០)។

គ្រូដែលមានវិធីសាស្ត្រល្អ តែងតែធ្វើឱ្យសិស្សទទួលបាននូវវិជ្ជាទាំងបី គឺវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (វិទ្យាស្ថានជាតិអប់រំ ២០១៩)។ ម៉្យាងទៀតនៅក្នុងសៀវភៅក៏បានបរិយាយផងដែរថាគ្រូបង្រៀនដែលល្អម្នាក់ មិនមែនគ្រាន់តែមានចំណេះដឹងលើជំនាញឯកទេសរបស់ខ្លួននោះទេ ប៉ុន្តែក៏ត្រូវមានវិធីសាស្ត្របង្រៀនល្អ នៅក្នុងការបញ្ជ្រាបចំណេះដឹងរបស់ខ្លួនទៅឱ្យសិស្សប្រកបដោយភាពវៃឆ្លាត។

## ២.៥ បញ្ហាប្រឈមលើការរៀនភាសាអង់គ្លេស

លទ្ធផលសិក្សារបស់សិស្សបានក្លាយជាក្ដីបារម្ភរបស់គ្រូបង្រៀន និង អ្នកឯកទេសអប់រំក្នុងរយៈពេលប្រមាណបីបួនទសវត្សចុងក្រោយ។ តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវលើសិស្សមួយចំនួនតូចនៅ ទីជនបទដែលបង្រៀនដោយគ្រូដដែលៗបានបង្ហាញថា៖ លទ្ធផលនៃការសិក្សារបស់សិស្សនៅជនបទ មានកម្រិតទាបជាងសិស្សនៅទីប្រជុំជន។ បញ្ហានេះបានទទួលការកត់សម្គាល់និងចាប់អារម្មណ៍ជាខ្លាំងនៅដំណាក់កាលចាប់

ផ្តើមនៃសតវត្សទីម្ភៃមួយ ហើយក៏មានការពិនិត្យកត្តាមួយចំនួនដែលជះឥទ្ធិពលដល់កម្រិតនៃការលើកទឹកចិត្ត របស់សិស្ស សាលាត្រៀមក្នុងការប្រើប្រាស់វគ្គសិក្សាភាសាដែលជួយដល់ការសិក្សាភាសារបស់សិស្សតាមកុំព្យូទ័រ(យោង Ramirez,1986; Genc and Aydin, 2011)។ សំណាកនៃការសិក្សាស្រាវជ្រាវដែលជាអ្នកសិក្សាភាសាអង់គ្លេសជាភាសាបរទេសចំនួន ១២៦ នាក់នៅសាលាត្រៀមនៃសាកលវិទ្យាល័យរដ្ឋមួយត្រូវបានគេរកឃើញថាមិនមានភាពខុសគ្នារវាងស្ថិតិប្រជាសាស្ត្រដែលបានជ្រើសរើសដូចជាអាយុរបស់សិស្ស ភេទ ថ្នាក់កាតព្វកិច្ចនិងស្ថានភាពជម្រើស ប្រភេទវិទ្យាល័យកម្រិតការអប់រំរបស់ឪពុកម្តាយ រយៈពេលនៃដំណើរការការសិក្សារបស់សិស្ស ឬក៏ជំនាញការប្រើប្រាស់កុំព្យូទ័រឡើយ។ អថេរតែមួយគត់ដែលត្រូវបានរកឃើញថាមានសារៈសំខាន់តាមស្ថិតិ គឺកម្រិតនៃការរៀនភាសាអង់គ្លេសសម្រាប់អ្នកចូលរួមក្នុងការស្រាវជ្រាវ ។ អ្នកចូលរួមច្រើនជាងពាក់កណ្តាលមានកម្រិតលើកទឹកចិត្តខ្ពស់ល្មម។ បើយោងតាមលោកJurkovic(2010) បានពិនិត្យឃើញថាផលប៉ះពាល់ពីរ លើពិន្ទុនៃលទ្ធផលមុខវិជ្ជាភាសាអង់គ្លេសដែលជាភាសាបរទេសសម្រាប់គោលបំណងជាក់លាក់ក្នុងការអប់រំឧត្តមសិក្សាគឺជំនាញភាសាដែលមានជំនាញនិងភាពញឹកញាប់នៃការប្រើប្រាស់យុទ្ធសាស្ត្ររៀនភាសា។ លទ្ធផលនៃការសិក្សានេះ បង្ហាញពីលទ្ធផលវិជ្ជមានគួរឱ្យកត់សំគាល់តាមស្ថិតិនៃសមត្ថភាពភាសាទូទៅលើពិន្ទុនៃការធ្វើតេស្តលទ្ធផល។ ទោះយ៉ាងណាក្នុងចំណោមការកសាងយុទ្ធសាស្ត្រអ្នកសិក្សាភាសាគឺមានតែមួយគត់ដែលមានឥទ្ធិពលយ៉ាងសំខាន់លើស្ថិតិនៃការធ្វើតេស្តលទ្ធផលគឺយុទ្ធសាស្ត្រទាក់ទងនឹងការយល់ដឹង។ Suh et al (2010) បានស៊ើបអង្កេតអំពីប្រសិទ្ធភាពនៃការលេងហ្គេមតាមអ៊ិនធឺណេតដែលមានអ្នកលេងច្រើន (MMORPG) ដែលមានមូលដ្ឋានលើការលេងបែបភាសាអង់គ្លេស។ លទ្ធផលបានបង្ហាញថានិស្សិតកំពុង សិក្សាភាសាអង់គ្លេសប្រើប្រាស់ល្បែងតាមអ៊ិនធឺណែតបានបង្ហាញពិន្ទុខ្ពស់ក្នុងការស្តាប់ ការអាន និងការសរសេរជាងសិស្សដែលចូលរៀនវគ្គបង្រៀនទល់មុខគ្នា។ វាក៏បានបង្ហាញផងដែរថាចំណេះដឹងមានស្រាប់ជំរុញទឹកចិត្តសម្រាប់ការសិក្សាដែលជាកត្តាជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សាភាសាអង់គ្លេស។ Hungi និងThuku,(2010) បានប្រើប្រាស់នីតិវិធីវិភាគចំរុះ ដើម្បីពិនិត្យលើសិស្សនិងសាលាដែល

បណ្តាលឱ្យមានបម្រែបម្រួលលើលទ្ធផលនៃការអានក្នុងចំណោមសិស្សានុសិស្សកម្រិតបឋមសិក្សាថ្នាក់ទី៦ ដែល មកពីប្រព័ន្ធសាលារៀននៅអាហ្វ្រិកខាងត្បូងចំនួន ១៤ កន្លែង។ កត្តាសំខាន់បំផុតដែលជះឥទ្ធិពលដល់បម្រែបម្រួលនៃលទ្ធផលសិក្សារបស់សិស្សនៅលើប្រព័ន្ធសាលារៀនភាគច្រើនគឺការរៀនត្រួតថ្នាក់ កម្រិតជីវភាពរបស់សិស្ស ការនិយាយភាសាដែលបានបង្រៀននៅផ្ទះ និងអាយុសិស្ស ។ សមធម៌សង្គមទាប ក្នុងសមិទ្ធិផលនៃការអានត្រូវបានគេមើលឃើញជាក់ស្តែងនៅMaurtius, Seychelles និង Tanzania ។ លោក Small (2010) បានរាយការណ៍ថាកុមារដែលឪពុកម្តាយដែលមានការអប់រំល្អ កូនៗរបស់គាត់ធ្វើបានល្អនៅសាលារៀន និងមានឥរិយាបថវិជ្ជមានលើលទ្ធផលសិក្សា។ ជាងនេះទៅទៀត គាត់បានបង្ហាញ ថាកត្តាសំខាន់ពីរដែលជះឥទ្ធិពលដល់ឪពុកម្តាយដែលចូលរួមយ៉ាងសកម្ម គឺពេលវេលារបស់សាលារៀន ឬអន្តរកម្មកំណត់ពេលនិងការប្រាស្រ័យទាក់ទងដោយផ្ទាល់ពីសាលារៀនដូចជាការអញ្ជើញផ្ទាល់ខ្លួនចូលរួមព្រឹត្តិការណ៍នានាជាដើម។ ការសិក្សាក៏កំណត់នូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីបង្កើនការចូលរួមរបស់មាតាបិតាដែលត្រូវអនុវត្តចំពោះសាលារៀននៅទីក្រុងក៏ស្រដៀងគ្នាផងដែរ។ Woo (2009) បានធ្វើការស្រាវជ្រាវលើកត្តាជាច្រើនដែលជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សារបស់សិស្សក្នុងការធ្វើតេស្ត ដែលមានលក្ខណៈស្តង់ដា ដោយស្វែងយល់ពីភាពចម្រូងចម្រាស់ដែលទាក់ទងទៅនឹងឋានានុក្រមនៅក្នុងកម្រិតសិស្ស ថ្នាក់រៀននិងកម្រិតសាលារៀន។ បន្ថែមពីនេះទៅទៀតដោយផ្អែកលើការសិក្សាស្រាវជ្រាវរបស់ Mosha (2014) បានលើកឡើងពីចំនុចសំខាន់បីគឺៈ

### ២.៥.១ ការរៀន និងបង្រៀនភាសាអង់គ្លេសក្នុងថ្នាក់

ដំណើរការរៀន និងបង្រៀនភាសាអង់គ្លេសមានការចូលរួមពីធាតុសំខាន់ពីរគឺ គ្រូបង្រៀន និង សិស្ស។ ហើយអ្នកសិក្សាក៏មិនត្រូវផ្តេកផ្តួលលើគ្រូតែម្នាក់ដែរ។ សិស្សក៏ត្រូវទទួលខុសត្រូវបន្ថែមទៀត ចំពោះដំណើរការសិក្សារបស់ខ្លួន(យោង Quist, 2000)។ ជាឧទាហរណ៍ Vuzo,(2010) បានរកឃើញថា "វាគឺជាការធ្វើអន្តរកម្មរវាង គ្រូនិងសិស្ស ដើម្បីធ្វើការជាមួយគ្នា និងបង្កើតសកម្មភាព និងភាពជាក់ស្តែងដែលទាក់ទងនឹង

ប្រធានបទដែលបានដៅទុក។ ទោះជាយ៉ាងណាក៏ដោយស្ថានភាពបែបនេះមិនត្រូវបាន រកឃើញជាទូទៅទេ នៅតាមអនុវិទ្យាល័យលើមុខវិជ្ជាទាំងអស់ ដោយសារវិធីសាស្រ្តបង្រៀនគ្របដណ្តប់លើដំណើរការបង្រៀននិងរៀនដែលនាំទៅរកផលអវិជ្ជមាន។ Cummings,(2002) ដូចដែលបានដកស្រង់ នៅ Wang,(1994) បាននិយាយថា "នៅពេលខ្ញុំលឺ ខ្ញុំភ្លេច នៅពេលខ្ញុំឃើញខ្ញុំចងចាំ ហើយនៅពេលខ្ញុំធ្វើ ខ្ញុំរៀន" ទំព័រ១១១ ។ Cummings,(2002) បានកត់សម្គាល់ថាការសិក្សាដែលសិស្សបង្កើតឱ្យមានអន្តរកម្ម ធ្វើឱ្យមានការចូលរួមកាន់តែមានប្រសិទ្ធិភាពនៅក្នុងថ្នាក់។ មានន័យថាប្រសិទ្ធភាពនៃការរៀនភាសានិងការបង្រៀននៅក្នុងថ្នាក់រៀននឹងអាស្រ័យលើគ្រូបង្រៀន។ គំនិតនេះស្របគ្នានឹង លទ្ធផលសិក្សាស្រាវជ្រាវរបស់ Quist,(២០០០)បានបង្ហាញថា នៅក្នុងការបង្រៀនប្រកបដោយគុណភាព និងគុណភាពនៃការរៀនសូត្ររបស់សិស្សគឺទាក់ទងយ៉ាងជិតស្និតទៅនឹងចំណេះដឹងនិងការយល់ដឹងរបស់គ្រូមុខវិជ្ជាឯកទេស។ លើសពីនេះទៀតគ្រូភាសាអង់គ្លេសគឺជាអ្នកដើរតួរសំខាន់បំផុតក្នុងវគ្គសិក្សានីមួយៗ។ មានការរំលឹកទ្រឹស្តីមួយទៀតបង្ហាញយ៉ាងច្បាស់ថា គ្រូបង្រៀនគឺជាអ្នកដែលកំណត់សកម្មភាពរៀនរបស់សិស្ស Allen & Valette; (1997) Quist (2000)។ ដោយសារការបង្រៀនគឺការប្រាស្រ័យទាក់ទង គ្រូភាសាអង់គ្លេសត្រូវតែមានសមត្ថភាពទំនាក់ទំនងអតិបរមា។ ផងដែរនោះ គ្រូម្នាក់ៗក៏ត្រូវចេះភាសាខ្លួនឯងដើម្បីឱ្យគាត់អាចធ្វើការសម្រេចចិត្តដែលមានប្រយោជន៍ទាក់ទងនឹងអ្វីដែលគួរត្រូវបានបង្រៀនដល់អ្នកណា និងរបៀបដែលការបង្រៀន គួរតែត្រូវបានអនុវត្តយ៉ាងណា។ យោងតាម Farmer(2003), Moha, 2004) ការស្រាវជ្រាវបង្ហាញយ៉ាងច្បាស់ថាក្នុងចំណោមកត្តាដែលនាំឲ្យទទួលលទ្ធផលមិនល្អរបស់សិស្សគឺជាគុណសម្បត្តិរបស់គ្រូ)។ ជាងនេះទៅទៀតការសិក្សាជាក់ស្តែងបានបង្ហាញថាប្រសិនបើនៅដើមឆ្នាំ សាលាមិនបានផ្តល់មូលដ្ឋានគ្រឹះត្រឹមត្រូវសម្រាប់ការរៀនសូត្រទេ នោះសិស្សក៏មិនអាចទទួលបាន នូវសក្តានុពលពេញលេញទាក់ទងនឹងរបៀបដែលការរៀនសូត្ររបស់គាត់នឹងដំណើរការទៅមុខនោះទេ។ ហើយឥរិយាបទរបស់គាត់មានអត្ថប្រយោជន៍យ៉ាងដូចម្តេចចំពោះជីវិតនិងការរៀនសូត្រពេលអនាគតរបស់គាត់ Quist(2000)។ សម្ភារៈបង្រៀន គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការរៀន

និងបង្រៀនលើគ្រប់មុខវិជ្ជា។ វាបានធ្វើឱ្យការរៀនសូត្រកាន់តែរីករាយដល់សិស្សពីព្រោះពួកគេផ្តល់នូវបទពិសោធន៍ជាក់ស្តែងដែលជំរុញសកម្មភាពខ្លួនឯងនិងការស្រមើស្រមៃរបស់សិស្ស។ ពួកគេក៏ផ្តល់ជាមូលដ្ឋានជាក់ស្តែងសម្រាប់ការគិត និងកាត់បន្ថយការឆ្លើយតបដោយពាក្យគ្មានន័យពីសិស្ស Nyamubi(2003)។ ជាឧទាហរណ៍ Kapoli, (2001) បានកត់សម្គាល់ថាឯកសារដែលមានសមត្ថភាពអាចឱ្យសិស្សអាចស្វែងយល់ភាសាដែលត្រូវបានប្រើក្នុងជីវិតប្រចាំថ្ងៃហើយដែលត្រូវនឹងតម្រូវការនិងផលប្រយោជន៍របស់ពួកគេ។ អង្គការ UNESCO(២០០០) បានរាយការណ៍ថាការផ្តល់សម្ភារៈបង្រៀននិងរៀនជាពិសេសសៀវភៅគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការកែលម្អលទ្ធផលសិក្សា។ ទោះយ៉ាងណាដោយយោងតាមរបាយការណ៍អប់រំពិភពលោក WER ( World Educational Report ១៩៩៨ ) បានបង្ហាញថានៅក្នុងប្រទេសជាច្រើនស្ថានភាពគឺមានភាពលំបាកទាំងសម្ភារៈរូបវ័ន្ត សម្ភារៈបង្រៀន ការរៀន ទំហំថ្នាក់រៀន និងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន ។

## ២.៥.២ ឥរិយាបទ ចំពោះការសិក្សាភាសារបស់សិស្ស

ឥរិយាបទសំដៅទៅលើសំណុំនៃជំនឿដែលអ្នកសិក្សាមាន ចំពោះសមាជិកក្រុមគោលដៅនិងឆ្ពោះ ទៅរកវប្បធម៌ផ្ទាល់ខ្លួនរបស់គាត់( យោងតាមBrown,2000)។ ទស្សនៈចំពោះការសិក្សាភាសាគឺជាគំនិតសំខាន់មួយពីព្រោះវាដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀនសូត្រភាសា។ ឧទាហរណ៍អ្នកស្រាវជ្រាវដែលដឹកនាំដោយលោកGardner, (2001&2002) អំពីឥរិយាបទនិងការលើកទឹកចិត្តបានបង្ហាញពីការទាកទង គ្នាជាមួយនឹងការ អនុវត្តភាសារបស់អ្នកសិក្សាដោយសង្កត់ធ្ងន់លើតួនាទីនៃឥរិយាបទ និងការលើកទឹកចិត្ត ដែលជាកត្តាកំណត់ក្នុងការសិក្សាភាសាបរទេស។ ជាទូទៅវាត្រូវបានគេរកឃើញថាឥរិយាបទវិជ្ជមាន ជួយសម្រួលដល់ដំណើរការនៃការរៀនសូត្រទោះបីជាឥរិយាបទមិនកំណត់អាកប្បកិរិយាក៏ដោយ Khanna & Agnihotri,(1994)។ ក្នុងការអប់រំឥរិយាបទត្រូវបានគេចាត់ទុកថាជាធាតុចូល និងលទ្ធផល។ ឥរិយាបទ មានទំនាក់ទំនងវិជ្ជមានជាមួយនឹងភាពជោគជ័យក្នុងការរៀនសូត្រភាសាអង់គ្លេសជាភាសាទីពីរព្រោះវាជួយសម្រួលដល់ការលើកទឹកចិត្តរបស់អ្នកសិក្សាក្នុងការរៀនភាសា Gardner & Trembly, (1994)។ ពួកគេបានបន្ថែមទៀតថាឥរិយាបទ

បុគ្គលចំពោះភាសាដែលពួកគេរៀនបំពេញតាមតម្រូវការសំខាន់ៗ នៅពេលពួកគេបំពេញមុខងារជាក់លាក់ដូចជាការទទួលបានពិន្ទុខ្ពស់ក្នុងការប្រឡងភាសាជាដើម ។

### ២.៥.៣ ការលើកទឹកចិត្ត និង ការសិក្សាភាសា

ការលើកទឹកចិត្តគឺជាគំនិតដែលត្រូវបានប្រើច្រើនបំផុតសម្រាប់ការបកស្រាយពីភាពបរាជ័យឬភាពជោគជ័យរបស់អ្នកសិក្សា។ ការលើកទឹកចិត្តក៏ត្រូវបានគេចាត់ទុកថាជាកត្តាសំខាន់មួយដែលជះឥទ្ធិពល ដល់ល្បឿននិងចំនួនជោគជ័យនៃអ្នកសិក្សាភាសាបរទេសGardner,(2006)។ ជាឧទាហរណ៍ Gardner, (2006),ទំព័រ២៤១ បានរកឃើញថានិស្សិតដែលមានកម្រិតលើកទឹកចិត្តខ្ពស់នឹងធ្វើបានល្អជាងសិស្ស ដែលមានកម្រិតទាប។ គាត់បានបន្ថែមទៀតថាប្រសិនបើមនុស្សម្នាក់ត្រូវបានលើកទឹកចិត្តគេនឹងមានហេតុផលសម្រាប់ចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធ(ទំព័រ២៤៣)។ នៅក្នុងការអភិវឌ្ឍមួយផ្សេងទៀត Elliot, Kratochel and Cook, (2000) មើលឃើញការលើកទឹកចិត្តសភាពផ្ទៃក្នុងមួយដែលធ្វើឱ្យមានសកម្មភាពរុញច្រានយើងក្នុងទិសដៅជាក់លាក់ ហើយធ្វើឱ្យយើងចូលរួមក្នុងសកម្មភាពដ៏ពិតប្រាកដ។ ពួកគេបានបន្ថែមទៀតថាការរៀនសូត្រនិងការលើកទឹកចិត្តគឺចាំបាច់ដូចគ្នាសម្រាប់ការអនុវត្តហើយពួកគេអាចឱ្យយើងទទួលបានចំណេះដឹងនិងជំនាញថ្មីៗ។ លើសពីនេះទៀតការលើកទឹកចិត្តផ្តល់នូវកម្លាំងរុញច្រាន សម្រាប់ការបង្ហាញនូវអ្វីដែលយើងបានរៀន ហើយមនុស្សដែលមានកម្លាំងចិត្តកាន់តែច្រើន ទទួលបានកម្រិតខ្ពស់។ ប៉ុន្តែដោយយោងតាម Hamer,(2004) បានព្រមានថាការលើកទឹកចិត្តដែលនាំសិស្សឱ្យអនុវត្តន៍ការសិក្សាភាសាអង់គ្លេសនេះក៏អាចជះឥទ្ធិពលពីឥរិយាបទរបស់មនុស្សមួយចំនួនផងដែរ។ នៅក្នុងការបង្រៀន ការលើកទឹកចិត្តគឺជាកត្តាមួយដែលជះឥទ្ធិពលដល់ភាពជោគជ័យឬបរាជ័យក្នុងការរៀនសូត្រភាសា ជាពិសេសភាសាទីពីរឬភាសាបរទេស Gardner, (2006)។ ជាមួយគ្នានេះ Petty,(1998) បានអះអាងថាប្រសិនបើសិស្សមិនចង់រៀនទេ ប្រសិទ្ធភាពនៃការរៀនសូត្ររបស់ពួកគេនឹងមានភាពយឺតយ៉ាវ ហើយក៏មិនទទួលបានអ្វីសោះឡើយ។ ហើយប្រសិនបើអ្នកដឹងពីរបៀបជំរុញទឹកចិត្តសិស្សអ្នកអាចបង្កើនការរៀនសូត្ររបស់ពួកគេ។ ក្រៅពីការលើក

ទឹកចិត្តនិងអាកប្បកិរិយាអ្នកសិក្សាស្រាវជ្រាវបង្ហាញថា បរិយាកាសសិក្សានៅផ្ទះបានរួមចំណែកធ្វើឲ្យសិស្សបំពេញការងារសិក្សានិងចូលរួមសកម្មភាពនៅតាមសាលារៀនមិនសូវបានល្អ Sulciman, (1999) & Mapuri, (1999)។ តាមរយៈលទ្ធផលការសិក្សាស្រាវជ្រាវរបស់ Thongma Souriyavongsa (2013) នៅសាកលវិទ្យាល័យជាតិនៃប្រទេសឡាវ បោះពុម្ពនៅ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ បានកំណត់បញ្ហាសំខាន់ៗ មួយចំនួនទាក់ទងនឹងកត្តាជះឥទ្ធិពលលើការសិក្សាភាសាអង់គ្លេសជាភាសាបរទេស និងភាសាទី២ សម្រាប់សិស្សដែលមានភាសាកំណើតមិនមែនភាសាអង់គ្លេសដូចជាប្រទេសឡាវនេះឯង។ កត្តាទាំងនោះអាចទាញចេញពីសមាសជាតុជាច្រើនរួមមាន ( បញ្ហាបរិស្ថានសង្គម ភាពខុសគ្នានៃវប្បធម៌ ការពង្រីកសេដ្ឋកិច្ចសង្គម -ល-។ បញ្ហាទាំងនេះណ្តាលឱ្យសិស្សមានលទ្ធផលមិនល្អនៅក្នុងការសិក្សាភាសា។ ជាពិសេសនៅក្នុងបណ្តាប្រទេសដែលបាតតារាងមួយចំនួនដូចជា ឡាវ មីយ៉ាន់ម៉ា កម្ពុជា និងវៀតណាមជាដើម។

## ២.៦ មូលហេតុនៃភាពកម្សោយក្នុងការរៀនភាសាអង់គ្លេស

ការសិក្សាភាសាអង់គ្លេសនៅតែជាការលំបាកសម្រាប់សិស្សានុសិស្សដោយកត្តារួមផ្សំជាច្រើនទៅតាមស្ថានភាពនៃប្រទេសនីមួយៗ។ យោងតាមលទ្ធផលសិក្សាស្រាវជ្រាវរបស់ Khattak, (2011) បានបង្ហាញថា សាវតាសេដ្ឋកិច្ចខ្សត់ខ្សោយក៏ជាកត្តាមួយដែលបង្កើតឲ្យអ្នកសិក្សាប្រឈមនឹងការប្រើប្រាស់ភាសាបរទេស។ ការសិក្សាមួយដែលត្រូវបានធ្វើឡើងដោយ Muhammad, (2007) បានបង្ហាញថា កត្តាដែលបណ្តាលឱ្យមានការព្រួយបារម្ភក្នុងការរៀនភាសាសម្រាប់អ្នកសិក្សា ESL/EFL នៅក្នុងជំនាញនិយាយ និងការជះឥទ្ធិពលលើការប្រាស្រ័យទាក់ទងគ្នា បានរកឃើញថាមានការលំបាកក្នុងការរៀនសូត្រភាសា និងប្រភពផ្សេងគ្នានៃវប្បធម៌របស់អ្នកសិក្សា។ ភាពខុសគ្នានៅក្នុងស្ថានភាពសង្គមរបស់អ្នកនិយាយ គឺជាកកត្តាដែលជះឥទ្ធិពលដល់ភាពទន់ខ្សោយនៃការសិក្សាភាសា។ លើសពីនេះទៀត ការសិក្សាអំពីបញ្ហា ដែលបានជួបប្រទះដោយអ្នកសិក្សា Arab EFL បានបង្ហាញថាអ្នកសិក្សាចូលចិត្តប្រើភាសាអារ៉ាប់ជាជាងភាសាអង់គ្លេសសម្រាប់ការទំនាក់ទំនងទាំងខាងក្រៅនិងខាងក្នុងថ្នាក់រៀន។ កង្វះខាតនៃការនិយាយភាសា ដោយអ្នកនិយាយជនជាតិដើម

កង្វះការបែងចែកលើភាពកម្សោយក្នុងបរិបទបង្រៀនភាសា និងកង្វះការលើកទឹកចិត្តផ្ទាល់ខ្លួន Laoe, (2011)។ ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Normazidah, Koo, and Hazita,(2012) & Trawicski, (2005)ក៏បានបង្ហាញពីកត្តាដែលជះឥទ្ធិពលរដល់អ្នកសិក្សា EFL មានការអនុវត្តមិនល្អនៅក្នុងការសិក្សាភាសាអង់គ្លេសដូចខាងក្រោម៖

- ភាសាអង់គ្លេសត្រូវបានគេចាត់ទុកថាជាប្រធានបទពិបាករៀន
- ការរៀនសូត្ររបស់អ្នកសិក្សាអាស្រ័យលើគ្រូភាសាអង់គ្លេសក្នុងនាមជាអាជ្ញាធរ
- ខ្វះការគាំទ្រ ក្នុងការប្រើប្រាស់ភាសាអង់គ្លេសនៅផ្ទះនិងសហគមន៍
- អ្នកសិក្សាមិនបានប្រើប្រាស់ភាសា និងឱកាសគ្រប់គ្រាន់នៅខាងក្រៅថ្នាក់រៀន
- សមត្ថភាពរបស់សិស្សមានកម្រិតលើវាក្យស័ព្ទ និងខ្វះខាតសម្ភារៈសម្រាប់អាន
- សិស្សមិនសូវមានឆន្ទៈ និងកង្វះការលើកទឹកចិត្តក្នុងការរៀនសូត្រភាសាអង់គ្លេសព្រោះពួកគេមិនបានមើលឃើញពីតម្រូវការប្រើប្រាស់ភាសាភ្លាមៗនោះទេ។
- កង្វះនៃការលើកទឹកចិត្ត និងមានអាកប្បកិរិយាអវិជ្ជមានចំពោះភាសា

តាមរយៈការសិក្សាស្រាវជ្រាវរបស់លោក Chang, (2010) បានចង្អុលបង្ហាញថាមូលហេតុដែលបណ្តាលឱ្យមានភាពទន់ខ្សោយរបស់សិស្សសម្រាប់ការសិក្សាភាសាអង់គ្លេស បានមកពីភាពខ្ជិលច្រអូសរបស់អ្នកសិក្សា។ កង្វះប្រសិទ្ធភាពសាលារៀន និងការផ្សព្វផ្សាយរបស់ឪពុកម្តាយមិនគ្រប់គ្រាន់។ លើសពីនេះទៅទៀតយោងតាមលោក Dembo, (2004) បញ្ជាក់ថាការគ្រប់គ្រងពេលវេលាគឺជាប់ទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ ឧទាហរណ៍សិស្សដែលមានជំនាញគ្រប់គ្រងពេលវេលាល្អទទួលបានមធ្យមភាគពិន្ទុខ្ពស់ជាងសិស្សដែលមិនមានជំនាញគ្រប់គ្រងពេលវេលា។ Alderman, (2004) ចែងអំពីលទ្ធផលនៃការរៀនភាសាមិនល្អរបស់សិស្សទទួលរងផលប៉ះពាល់ពីការខ្វះខាតការខិតខំប្រឹងប្រែង ខ្វះយុទ្ធសាស្ត្ររៀនសូត្រប្រកបដោយ

ប្រសិទ្ធភាព ចំណែកឯអ្នករៀនភាសាបានល្អ គឺជាសិស្សដែលមានកម្លាំងចិត្តខ្ពស់ និងជាអ្នកប្រើយុទ្ធសាស្ត្រច្រើន Trawinski,(2005) ។

### ២.៦.១ ការលើកទឹកចិត្តសម្រាប់ការរៀនភាសាអង់គ្លេស

យោងតាមលទ្ធផលសិក្សាស្រាវជ្រាវរបស់ Lei,(2012) & Thang, (2011) បានបង្ហាញថា៖ ជាទូទៅការលើកទឹកចិត្តត្រូវបានទទួលស្គាល់ថាជាកត្តាសំខាន់បំផុតមួយដែលជះឥទ្ធិពលដល់ការសិក្សាភាសាទី២។ នៅពេលបច្ចុប្បន្នចំនួនសិស្សនៃប្រទេសឡាវជាច្រើនបានបរាជ័យក្នុងការរៀនភាសាអង់គ្លេសដោយសារតែកង្វះការលើកទឹកចិត្តពីជាតុមួយចំនួនដូចជា ៖ សាវតាគ្រួសារ បរិយាកាសសង្គម បរិយាកាសរូបវន្ត វប្បធម៌ និង វិធីសាស្ត្រក្នុងការសិក្សាជាដើម នេះបើយោងតាមលោកDembo,(2004) ។ យោងតាម Zhou,(2012) បានបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវថា៖ ការលើកទឹកចិត្តអាចមានឥទ្ធិពលលើសេរីភាពរបស់សិស្ស ការយកចិត្តទុកដាក់ ការប្រឹងប្រែង ការអត់ធ្មត់ ទម្លាប់នៃការប្រើប្រាស់ភាសា និងភាពជោគជ័យលើការសិក្សារបស់គេ។ អស់រយៈពេលជាយូរមកហើយការលើកទឹកចិត្តជាទូទៅត្រូវបានចូលរួមដោយគ្រូភាសាអង់គ្លេស និងអ្នកស្រាវជ្រាវដែលបានព្យាយាមទ្រទ្រង់ការលើកទឹកចិត្តរបស់សិស្សក្នុងការរៀនសូត្រភាសាអង់គ្លេស ដោយ ដឹងពីប្រភេទនៃកត្តាជំរុញការរៀនភាសាអង់គ្លេសរបស់ពួកគេនិងកត្តាដែលជះឥទ្ធិពលដល់ការលើកទឹកចិត្តរបស់ពួកគេនៅក្នុងដំណើរការដ៏វែងនៃការរៀនសូត្រភាសាអង់គ្លេស (យោង Lei, 2012)។ ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Sakiroglu & Dikilitas,(2012)បានបង្ហាញថា៖ ប្រសិនបើសិស្សមានការលើកទឹកចិត្តខ្ពស់ពួកគេនឹងរីករាយក្នុងការរៀន ត្រូវការរៀនភាសា និងព្យាយាមរៀនភាសា។ លើសពីនេះទៅទៀតការលើកទឹកចិត្តជាធម្មតាត្រូវបានគេចាត់ ទុកថាជាគន្លឹះដ៏សំខាន់ក្នុងការសិក្សាភាសាបរទេស ពិសេសភាសាអង់គ្លេស (Kimova, 2011) ។

## ២.៧ យុទ្ធសាស្ត្ររៀនភាសាអង់គ្លេស

យុទ្ធសាស្ត្ររៀនគឺជាវិធីសាស្ត្រដែលអ្នកសិក្សាប្រើដើម្បីទទួលបានព័ត៌មាន៖ ជាធម្មតាអ្នកសិក្សា ដែលទទួលបានជោគជ័យខ្ពស់ប្រើយុទ្ធសាស្ត្រច្រើនជាងការរៀនដែលទទួលបានលទ្ធផលទាប Dembo, (2004)។ មានសិស្សដែលមិនបានទទួលជោគជ័យមួយចំនួនក្នុងការសិក្សារបស់ពួកគេព្រោះពួកគេច្រើន តែខកខានការអនុវត្តយុទ្ធសាស្ត្ររៀនសូត្រឱ្យបានសមស្របទៅនឹងកិច្ចការដែលមាននៅក្នុងដៃ។ តាមទស្សនៈអ្នកស្រាវជ្រាវជឿជាក់ថាយុទ្ធសាស្ត្រនៃការរៀនគឺមានសារៈសំខាន់នៅក្នុងការជំរុញភាសាទី២ (SLA - Second Language: Aquisition) ព្រោះវាផ្ដល់ឱ្យអ្នកសិក្សានូវគន្លឹះដើម្បីសម្រេចបាននូវគោលដៅ។ ពួកគេក៏អាចជួយសម្រួលដល់ទិដ្ឋភាពជាក់លាក់នៃសមត្ថភាពរបស់អ្នកសិក្សាដូចជាការប្រាស្រ័យទាក់ទង និងអារម្មណ៍របស់បុគ្គលដែលទាក់ទងទៅនឹងដំណើរការនៃការរៀនសូត្រ (Trawiski,2005)។ ដោយយោងតាម Margaret, (2005) វាពិតជាមានតម្លៃណាស់ក្នុងការបង្កើត និងសម្របសម្រួលដល់យុទ្ធសាស្ត្ររៀនដើម្បីបំពេញកម្រិតភាសាអង់គ្លេសរបស់អ្នកសិក្សាហើយបន្ទាប់មកលើកទឹកចិត្តឱ្យមានការចូលរួមប្រកបដោយជោគជ័យ។ យោងតាមការសិក្សារបស់Ting, (2009) សិស្សអាចយកឈ្នះភាពទន់ខ្សោយរបស់ពួកគេតាមរយៈការបណ្ដុះបណ្ដាលយុទ្ធសាស្ត្រសមស្រប ហើយយុទ្ធសាស្ត្ររៀនអាចជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សារបស់សិស្ស។ ជាងនេះទៅទៀតការផ្ដល់ជំនួយជាយុទ្ធសាស្ត្រក្នុងការរៀន ក៏ជំរុញឱ្យសិស្សក្លាយជាសិស្សពូកែផងដែរ។ ដោយយោងតាមការសិក្សារបស់ Oxford (2001) បានចាត់ថ្នាក់លក្ខណៈអ្នករៀនពូកែ គឺជាអ្នកដែល៖

- មានភាពក្លៀវក្លានិងទស្សនៈទានត្រឹមត្រូវ
- មានកម្លាំងចិត្តក្នុងការទំនាក់ទំនង
- គ្មានការគំរាមកំហែង និងត្រៀមខ្លួនធ្វើខុស
- ផ្ដោតលើទម្រង់បែបបទដោយមើលគំរូនិងការប្រើប្រាស់ការវិភាគ
- ធ្វើឱ្យប្រសើរឡើងនូវឱកាសអនុវត្តន៍ទាំងអស់
- តាមដានសម្ដីខ្លួនឯង និងអ្នកដទៃ

- យកចិត្តទុកដាក់លើអត្ថន័យ

ទោះជាយ៉ាងណាក៏ដោយ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនពិពណ៌នាអំពីភាពខុសគ្នានៃនិយមន័យនៃយុទ្ធសាស្ត្រនៃការសិក្សាដូចតទៅ៖ ដោយយោងតាម Richard & Lockhart,(2007)បង្ហាញថា៖ យុទ្ធសាស្ត្ររៀនគឺជាដំណើរការដាក់លាក់ដែលនិស្សិតប្រើជាមួយភារកិច្ចសិក្សាផ្ទាល់ខ្លួនដូចជាការអាន ជំពូកនៃសៀវភៅ ឬការរៀបចំការសង្ខេបនៃអត្ថបទមួយក៏ដូចជាសិស្សអាចជ្រើសរើសវិធីផ្សេងៗគ្នាជាច្រើន ក្នុងការបំពេញភារកិច្ចអ្នកសិក្សាអាចធ្វើឱ្យការរៀនសូត្រកាន់តែងាយស្រួល លឿន រីករាយជាងមុន និងមានប្រសិទ្ធភាពជាងមុន និងអាចផ្ទេរបានច្រើនទៅស្ថានការណ៍ថ្មីៗ។ តាមរយៈការសិក្សាស្រាវជ្រាវរបស់ លោកGrainger,(2005)& Oxford,(2002) បានគូសបញ្ជាក់ថា យុទ្ធសាស្ត្ររៀនភាសាគឺជាបច្ចេកទេស សម្រាប់ការប្រើប្រាស់របស់សិស្ស ដើម្បីជួយដល់ដំណើរការរៀនភាសាអង់គ្លេសរបស់សិស្ស។ ដោយយោងតាមAbbasi, Ahmad, & Khattak,(2010) បានកំណត់ច្បាស់ថាយុទ្ធសាស្ត្ររៀនភាសាគឺជាលក្ខណៈឬ គំនិតជាក់លាក់ដែលសិស្សប្រើដើម្បីបង្កើនការរៀនភាសារបស់ពួកគេ។

# ជំពូក៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣

# វិធីសាស្រ្តស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "ការយល់ឃើញរបស់សិស្សលើការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ" មានគោលបំណងសិក្សាស្វែងយល់ពីឥរិយាបទសិស្សលើការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ គុណភាពគ្រូបង្រៀនភាសាអង់គ្លេស និងការចូលរួមរបស់គណៈគ្រប់គ្រងសាលារៀនក្នុងការពង្រឹងលើដំណើរការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស។ វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវគឺអនុវត្តតាមបរិមាណវិស័យ និងគុណវិស័យ។

## ៣.១. គម្រោងវិភាគ ( Analysis Plan )

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ៣ប្រភេទ តាមបែបបរិមាណវិស័យដោយបន្សុីគ្នាជាមួយសំណួរស្រាវជ្រាវទាំងពីរនៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ២០២៣ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ចំនួន៩វិទ្យាល័យក្នុងរាជធានីភ្នំពេញ និងក្រុមគោលដៅបំពេញទិន្នន័យកម្រងសំណួរមាន៣ប្រភេទ គឺគណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្សថ្នាក់ទី១០ ទី១១ និងទី១២។

## ៣.២ ការប្រមូលទិន្នន័យ ( Data Collection )

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខ័ណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង រួចមកអ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីចែកកម្រងសំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបនាយកសាលានីមួយៗដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាតជួបក្រុមគោលដៅដើម្បីផ្តល់កម្រងសំណួរដល់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស ដោយមានកំណត់ពេលវេលាជាក់លាក់។ ការបំពេញទិន្នន័យក្នុងកម្រងសំណួរ មានរយៈពេលមួយសប្តាហ៍ អ្នកសិក្សាស្រាវជ្រាវ បានប្រមូលកម្រងសំណួរពីអ្នកឆ្លើយតបទៅតាមពេលកំណត់ជាក់លាក់។

ក្នុងការចុះប្រមូលទិន្នន័យបានប្រើប្រាស់ពេលវេលាសរុបចំនួន២៧ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃដែលបានទទួលកម្រងសំណួរទាំងអស់ពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ៖ កត្តាជះឥទ្ធិពលដលលទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេស សិស្សមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់កម្រងសំណួរចំនួន៣ប្រភេទក្នុងការចុះប្រមូលទិន្នន័យតាមបរិមាណវិស័យពីគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស ដោយផ្អែកលើទ្រឹស្តីពាក់ព័ន្ធនានា ដែលមានដូចជា៖ ការអនុវត្តកម្មវិធីសិក្សា ស្តង់ដានាយកសាលារៀន សៀវភៅការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ កម្មវិធីសិក្សាពលរដ្ឋពេញលេញ និងការធានាគុណភាពអប់រំជាដើម ដើម្បីសិក្សាពីកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេស និងដំណោះស្រាយនានា ដើម្បីឲ្យសិស្សសិក្សាភាសាអង់គ្លេសទទួលបានលទ្ធផលល្អប្រសើរឡើងវិញ។

### ៣.៣.១. កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ ត្រូវបានកម្រិតជាតួលេខជាក់លាក់ និងមានការពន្យល់ណែនាំច្បាស់ក្នុងកម្រងសំណួរដើម្បីមានភាពងាយស្រួលក្នុងការជ្រើសរើសចម្លើយ។ ដើម្បីមានភាពងាយស្រួល ក្នុងការផ្តល់ចម្លើយអ្នកស្រាវជ្រាវបានកំណត់ កម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត តាមបែប Likert Scale ដែលមានការនិយមចូលចិត្តប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអបរំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយ

តម្លៃទៅលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង សាលារៀន គ្រូបង្រៀន និងសិស្ស។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មានចំនួន៥កម្រិត ពីទាបបំផុត(១) ទៅខ្ពស់បំផុត (៥)។ អត្ថន័យនៃកម្រិតចង្អុលបង្ហាញមានដូចខាងក្រោម៖

១ គឺមានន័យថា ការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតនោះបាន តិចបំផុត ឬ មិនអាចអនុវត្តទាល់តែសោះ ពោលគឺក្នុងកម្រិតពី 0%ដល់១0%

២ គឺមានន័យថា ការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតនោះបាន តិច ឬអនុវត្តម្តងម្កាល ពោលគឺក្នុងកម្រិតពី ១0%ដល់៤0%

៣ គឺមានន័យថា ការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតនោះបានមធ្យម ឬអនុវត្តខ្លះមិនអនុវត្តខ្លះ ពោលគឺក្នុងកម្រិតពី ៤0%ដល់ ៦0%

៤ គឺមានន័យថា ការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតនោះបាន ច្រើន ឬស្ទើរតែគ្រប់ពេល ពោលគឺក្នុងកម្រិតពី ៦0% ដល់ ៩0%

៥ គឺមានន័យថា ការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតនោះបាន ច្រើនបំផុតឬជាប្រចាំគ្រប់ពេល ពោលគឺក្នុងកម្រិតពី ៩0% ដល់១00%

### ៣.៣.២. កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីស្ថានភាពនៃការសិក្សាមុខវិជ្ជាភាសាអង់គ្លេស សិស្សមធ្យមសិក្សាទុតិយភូមិ នៅរាជធានីភ្នំពេញ និងកម្រិតនៃការអនុវត្តរបស់គ្រូបង្រៀន គណៈគ្រប់គ្រង ដើម្បីជួយសិស្សឲ្យបានលទ្ធផលសិក្សាល្អ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅវិភាគ បកស្រាយដើម្បីចងក្រងជាសារណាបទនេះតែប៉ុណ្ណោះ។

### ៣.៣.២.១. កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង មធ្យមសិក្សាទុតិយភូមិ

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់សម្រាប់នាយក និងនាយករង ដែលចែកចេញជា២ផ្នែកគឺ៖

ផ្នែកទី១៖ ព័ត៌មានទូទៅ

មាន៨សំណួរទាក់ទងទៅនឹងតួនាទី កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស បទពិសោធន៍ការងារ និងភាសាបរទេស។

ផ្នែកទី២៖ ស្វែងយល់ពីការចូលរួមរបស់គណៈគ្រប់គ្រងលើការពង្រឹងការរៀននិងបង្រៀនភាសាអង់គ្លេស

មានសមាសភាគចំនួន៣ គឺការរៀបចំផែនការកែលម្អកម្មវិធីភាសាអង់គ្លេស(៤សំណួរ) ការកសាងសមត្ថភាពគ្រូ (៥សំណួរ) ការកសាងសមត្ថភាពសិស្ស (៥សំណួរ) ការត្រួតពិនិត្យផ្ទៃក្នុង (៦សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតនៃឥរិយាបថរបស់ថ្នាក់ដឹកនាំនិងគ្រប់គ្រងសាលារៀន ក្នុងការពង្រឹងការរៀននិងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិក្នុងរាជធានីភ្នំពេញ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែម ពីការឆ្លើយតបរបស់គណៈគ្រប់គ្រង នៅផ្នែកទី២ ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

### ៣.៣.១.២ កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរគ្រូគឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនផ្នែកមធ្យមសិក្សាទុតិយភូមិ ដែលកំពុងបង្រៀនអង់គ្លេសពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ដែលចែកចេញជា ២ផ្នែកគឺ៖

ផ្នែកទី១៖ព័ត៌មានទូទៅ

មាន៧សំណួរ ទាក់ទងទៅនឹងស្ថានភាពដែលជាគ្រូបង្រៀន កំពុងបង្រៀននៅមធ្យមសិក្សាទុតិយភូមិ កន្លែងបម្រើការងារ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស និងបង្រៀនថ្នាក់ទីប៉ុន្មាន។

ផ្នែកទី២៖ ឥរិយាបទគ្រូលើការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅវិទ្យាល័យក្នុងរាជធានីភ្នំពេញ

មានសមាសភាគចំនួន៥ គឺការអនុវត្តកម្មវិធីសិក្សា ការរៀបចំដំណើរការបង្រៀន វិធីសាស្ត្រនៃការបង្រៀន ការវាស់វែង និងការវាយតម្លៃលទ្ធផលការសិក្សា និ បរិយាកាសក្នុងថ្នាក់រៀន។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់គ្រូបង្រៀននៅផ្នែកទី២ ស្តីពី "តើលោកគ្រូអ្នកគ្រូភាសាអង់គ្លេស បានជួបប្រទះការលំបាកអ្វីខ្លះក្នុងការបង្រៀនភាសាអង់គ្លេស? និង តើលោកគ្រូ អ្នកគ្រូ ដោះស្រាយបញ្ហាទាំងនោះយ៉ាងដូចម្តេចខ្លះ? ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ ។

**៣.២.២.៣.កម្រងសំណួរសម្រាប់សិស្ស**

កម្រងសំណួរសិស្ស គឺប្រើសម្រាប់ប្រមូលទិន្នន័យពីសិស្សដែលកំពុងរៀនពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២ អំពីកម្រិតពេញចិត្តរៀនមុខវិជ្ជាភាសាអង់គ្លេសនៅវិទ្យាល័យរដ្ឋក្នុងរាជធានីភ្នំពេញ ដែលចែកចេញជា២ផ្នែកគឺ៖

ផ្នែកទី១៖ ព័ត៌មានទូទៅ

មាន៥សំណួរទាក់ទងទៅនឹងសិស្សបានសិក្សាមុខវិជ្ជាភាសាអង់គ្លេសក្នុងវិទ្យាល័យ ភេទ អាយុ រៀនថ្នាក់ទី និងឈ្មោះវិទ្យាល័យ។

ផ្នែកទី២៖ ឥរិយាបថរបស់សិស្សលើការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀនភាសាអង់គ្លេស មានសមាសភាគចំនួន៣ គឺអំពីការរៀន (៧សំណួរ) អំពីការបង្រៀន (៦សំណួរ) និងការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស(៨សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីការពេញចិត្តបំពេញការងាររបស់គ្រូបង្រៀនភាសា

អង់គ្លេស។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់សិស្សនៅផ្នែកទី២ ស្តីពីមេរៀន ការបង្រៀន និងការសិក្សាលើមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

## ៣.៤ ការជ្រើសរើសភាគសំណាក

ការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរក្នុងវិទ្យាល័យចំនួន៩ នៅរាជធានីភ្នំពេញ ដែលមានចំនួនសំណាកសរុប២២៨នាក់ លោកគ្រូ-អ្នកគ្រូ ចំនួន២៨នាក់ គណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ និងសិស្សចំនួន៥២៩នាក់។ ការវិភាគទិន្នន័យ សិក្សាលើចំនួនភាគរយ តាមអថេរនីមួយៗ និងចំនួនមធ្យមភាគនៃសូចនាករតាមផ្នែក និងកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត ដោយគណនាតាមរូបមន្តកំណត់ជាក់លាក់។

ចំនួនសំណាកក្នុងការប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរ បានជ្រើសរើសខណ្ឌចំនួន៩ ក្នុងរាជធានីភ្នំពេញគឺ ៖ ខណ្ឌជ្រោយចង្វារ ខណ្ឌដង្កោ ខណ្ឌសែនសុខ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌឫស្សីកែវ ខណ្ឌខណ្ឌកំបូល ខណ្ឌដូនពេញ ខណ្ឌទួលគោក ខណ្ឌច្បារអំពៅ។ ការចុះប្រមូលទិន្នន័យ តាមរយៈកម្រងសំណួរនៅសាលារៀនមធ្យមសិក្សាទុតិយភូមិចំនួន៩ មានសំណាកសរុបចំនួន ២២៨នាក់ដែលបែងចែកជាគណៈគ្រប់គ្រងសាលារៀនចំនួន២០នាក់ គ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន២៨នាក់ និងសិស្សចំនួន១៨០នាក់ កំពុងរៀនភាសាអង់គ្លេសថ្នាក់ទី១០ ដល់ថ្នាក់ទី១២។

តារាង៣.១ ៖ ចំនួនភាគសំណាកដែលបានទទួលទិន្នន័យពីកម្រងសំណួរ

| ល.រ | ឈ្មោះ<br>សាលារៀន | ចំនួនសំណាក<br>គណៈគ្រប់គ្រង | ចំនួនសំណាក<br>គ្រូបង្រៀន | ចំនួនសំណាក<br>សិស្ស |
|---|---|---|---|---|
| ១ | វិ ឫស្សីកែវ | ៣ | ៤ | ៦០ |
| ២ | វិ ហាស ភ្នំពេញថ្មី | ២ | ៣ | ៦០ |
| ៣ | វិ ព្រែកឯង | ២ | ៣ | ៦០ |

| | | | | |
|---|---|---|---|---|
| ៤ | វិ ហស បន អារុណវតី | ២ | ២ | ៦០ |
| ៥ | វិ បឹងប្រិយ | ២ | ៣ | ៥៩ |
| ៦ | វិ កំបូល | ២ | ៣ | ៦០ |
| ៧ | វិ ឥន្ទ្រទេវី | ៣ | ៤ | ៦០ |
| ៨ | វិ បន ហស វត្តភ្នំ | ២ | ៣ | ៦០ |
| ៩ | វិ ហស ព្រែកកំពឹស | ២ | ៣ | ៥០ |
| សរុប | | ២០ | ២៨ | ៥២៩ |

## ៣.៥ ការវិភាគទិន្នន័យ

បន្ទាប់ពីប្រមូលកម្រងសំណួរត្រឡប់វិញ អ្នកស្រាវជ្រាវបានស្រង់ចម្លើយដោយបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី Ms Excel តាមកម្រិតចង្អុលបង្ហាញដែលមានក្នុងកម្រងសំណួរ។ អ្នកស្រាវជ្រាវបានប្រើប្រាស់ស្ថិតិពណ៌នា (Descriptive Statistics) ក្នុងការរកប្រេកង់ (Frequency) និងរកតម្លៃភាគរយ(Percentage) តម្លៃមធ្យម (Mean) គម្លាតស្តង់ដា (Standard Deviation)ដើម្បីឆ្លើយសំណួរស្រាវជ្រាវទាំង២។

ការបកស្រាយទៅលើពិន្ទុមធ្យមភាគនៃសូចនាករ នីមួយៗគឺមានរូបមន្តដូចខាងក្រោម (Best, 1981)៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{5 - 1}{5} = \frac{4}{5} = 0.80$$

1.00 - 1.80 មានន័យថា ខ្សោយខ្លាំង

1.81 - 2.60 មានន័យថា ខ្សោយ

2.61 - 3.40 មានន័យថា មធ្យម

3.41 - 4.20 មានន័យថា ល្អ

4.21 - 5.00 មានន័យថា ល្អណាស់

# ជំពូក៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

# ជំពូក៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ក្នុងជំពូក៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរ លើក្រុមគោលដៅដែលពាក់ព័ន្ធ រួមមានគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ លទ្ធផលដែលទទួលបាននឹងត្រូវបានយកមកពិភាក្សាលើចំណុចសំខាន់នានា ដែលផ្តោតទៅលើបញ្ហាប្រឈម និងដំណោះស្រាយលើការរៀន និងបង្រៀនភាសាអង់គ្លេស។ ជាពិសេសជាងនោះទៀត តាមរយៈការពិភាក្សាលើលទ្ធផលដែលទទួលបាន នឹងអាចបង្ហាញពីដំណោះស្រាយដ៏មានប្រសិទ្ធភាពដើម្បីធ្វើយ៉ាងណាឱ្យលទ្ធផលសិក្សាបានល្អប្រសើរឡើងវិញ។

## ៤.១ ព័ត៌មានទូទៅរបស់អ្នកចូលរួម

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់យកវិទ្យាល័យចំនួន០៩ ក្នុងខណ្ឌចំនួន០៩ ដោយក្នុងមួយខណ្ឌយកមួយវិទ្យាល័យ។

នៅក្នុងផ្នែកនេះ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សដែលជាសំណាកស្រាវជ្រាវទាំងអស់ ដែលមានព័ត៌មានលម្អិតពី កម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ/បង្រៀន និងមុខវិជ្ជាឯកទេសដូចការបរិយាយខាងក្រោម៖

### ៤.១.១ ព័ត៌មានទូទៅពីគណៈគ្រប់គ្រង

តាមការប្រមូលទិន្នន័យពីគណៈគ្រប់គ្រងចំនួន២០នាក់ ស្រី៨នាក់ បង្ហាញថាគណៈគ្រប់គ្រងដែលមានតួនាទីជានាយកសាលាមានចំនួន០៨នាក់ និងក្រៅពីនោះគឺមានតួនាទីជានាយករងទាំងអស់។ គណៈគ្រប់គ្រងសាលាចំនួន១៨នាក់មានអាយុលើសពី៤០ឆ្នាំ និង អាយុចន្លោះពី ៣៦ ដល់ ៤០ឆ្នាំមានចំនួនតែ០២នាក់ប៉ុណ្ណោះ។ គណៈគ្រប់គ្រងមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន ១២នាក់ និង សញ្ញាបត្របរិញ្ញាបត្រជាន់

ខ្ពស់មានចំនួន០៨នាក់។ គណៈគ្រប់គ្រងសាលាទាំងអស់សុទ្ធតែមានបទពិសោធន៍ការងារយូរឆ្នាំ ក្នុងវិស័យអប់រំលើសពី១៥ឆ្នាំ ពិសេសក្នុងការងារបង្រៀន និងការគ្រប់គ្រង។ នាយក នាយករងមានតែ ០៣នាក់ប៉ុណ្ណោះ មានឯកទេសភាសាអង់គ្លេស និង១៧នាក់ទៀតមានឯកទេសផ្សេង។ គណៈគ្រប់គ្រងសាលាដែលមានចំណេះដឹងភាសាបរទេសមានចំនួន១៦នាក់ ទាំងភាសាអង់គ្លេស និងភាសាបារាំង។ ដោយឡែកគណៈគ្រប់គ្រងចំនួន០៤នាក់ ទៀតមិនចេះភាសាបរទេសទេ។

### ៤.១.២ ព័ត៌មានទូទៅពីគ្រូបង្រៀន

តាមរយៈការប្រមូលទិន្នន័យ ឃើញថាគ្រូបង្រៀនថ្នាក់ទី១២មាន០៩នាក់ស្រី០៣នាក់ គ្រូបង្រៀនថ្នាក់ទី១១ មាន១១នាក់ ស្រី០៤នាក់ និងគ្រូបង្រៀនថ្នាក់ទី១០ មានចំនួន០៨នាក់ ស្រី០៥នាក់ ។ គ្រូបង្រៀនភេទប្រុសមានចំនួន១៦នាក់ និង ភេទស្រីមានចំនួន១២នាក់។ គ្រូបង្រៀនមានអាយុចន្លោះពី៣០-៣៥ឆ្នាំមានចំនួន០៦នាក់ និងមានអាយុលើសពី៣៥ឆ្នាំ មានចំនួន២២នាក់ ។ គ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន១៨នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន១០នាក់។ គ្រូបង្រៀនមានបទពិសោធន៍បង្រៀនចន្លោះពី៦-១០ឆ្នាំ មានចំនួន០៣នាក់ បទពិសោធន៍ពី ១១-១៥ ឆ្នាំមានចំនួន ០៦នាក់ និង លើសពី១៥ឆ្នាំមានចំនួន១៩នាក់។ គ្រូបង្រៀនទាំងអស់ជាគ្រូឯកទេសភាសាអង់គ្លេសដែលមានគុណវុឌ្ឍិត្រឹមត្រូវ ចំណេះដឹងទូលំទូលាយដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សក្នុងការសិក្សារៀនសូត្រ។

### ៤.១.៣ ព័ត៌មានទូទៅពីសិស្សានុសិស្ស

តាមទិន្នន័យ ដែលទទួលបានពីក្នុងការស្រាវជ្រាវលើសិស្សានុសិស្ស បង្ហាញថា សិស្សានុសិស្សទាំងអស់សុទ្ធតែធ្លាប់រៀនភាសាអង់គ្លេស។ សិស្សបានឆ្លើយកម្រងសំណួរសរុបមានចំនួន៥២៩នាក់ ភេទស្រីមានចំនួន២៨៧នាក់។ សិស្សានុសិស្សទាំងអស់មានអាយុចន្លោះពី ១៦-១៩ឆ្នាំ និងជាសិស្សដែលកំពុងរៀនថ្នាក់ទី១០ ទី១១ និងទី១២ ក្នុងឆ្នាំសិក្សា ២០២២-២០២៣។

## ៤.២ ការយល់ឃើញរបស់សិស្សលើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស

### ៤.២.១ ទិន្នន័យពីការឆ្លើយតបរបស់សិស្ស លើការបង្រៀន និងរៀនភាសាអង់គ្លេសសិស្សមធ្យមសិក្សាទុតិយភូមិ

ក្រាបតាមលំដាប់លំដោយខាងក្រោម បង្ហាញពីយោបល់របស់សិស្សលើការយល់ឃើញអំពីការបង្រៀន និងការរៀនមុខវិជ្ជាភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យទាំង០៩ ក្នុងរាជធានីភ្នំពេញ។

**សមាសភាគ ១- ការឃើញរបស់សិស្សលើសៀវភៅសិក្សាគោលសិក្សា**

សៀវភៅសិក្សាគោលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការងារបង្រៀន និងរៀន។ គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់នៅតែបន្តដាក់ឱ្យប្រើប្រាស់នូវសៀវភៅសិក្សាគោល English for Cambodia សម្រាប់បម្រើឱ្យការបង្រៀន និងរៀន។ សៀវភៅសិក្សាគោលមានសារៈសំខាន់ដូចជា៖ បង្ហាញពីគោលបំណងនៃកម្មវិធីសិក្សាលម្អិត សម្រាប់បំពេញសេចក្តីត្រូវការរបស់អ្នកសិក្សា ជាផែនទីបង្ហាញផ្លូវសម្រាប់សិស្សដើម្បីឱ្យពួកគេដឹងពីអ្វីដែលរំពឹងទុក ផ្តល់នូវសកម្មភាពនានាដែលបានដៅ និងគ្រោងទុកសម្រាប់គ្រូ ជាឧបករណ៍តាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ជាសម្ភារឧបទេសដែលមានភាពប្រទាក់ក្រឡាគ្នាពីសកម្មភាពមួយទៅសកម្មភាពមួយទៀត (Gak, 2011)។ ក្រាបខាងក្រោមនេះ បានបង្ហាញពីការយល់ឃើញរបស់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យរដ្ឋ ចំនួន៥២៩នាក់លើសៀវភៅសិក្សាគោលភាសាអង់គ្លេស (English for Cambodia) ថ្នាក់ទី១០ ទី១១ និងទី១២។

ក្រាបទី១៖ ការឃើញរបស់សិស្សលើសៀវភៅសិក្សាគោល




តាមរយៈក្រាបខាងលើ យើងសង្កេតឃើញតម្លៃមធ្យមលើចំណុចវេយ្យាករណ៍ លំហាត់អនុវត្តន៍ ជំនាញសរសេរ និងជំនាញអានមានតម្លៃមធ្យមលើស ៣.៥០ គឺមានន័យថា សិស្សវាយតម្លៃខ្ពស់លើចំណុចទាំងអស់នេះ ខណៈពេលដែលខ្លឹមសារមេរៀន ទំហំសៀវភៅ រូបភាព គូល័រនិងហ្វុងអក្សរ វាក្យសព្ទ ជំនាញស្តាប់ និងជំនាញនិយាយនៃសៀវភៅសិក្សាគោលនេះ មានតម្លៃមធ្យមតូចជាង ៣.៥០ គឺមានន័យថាភាពពេញចិត្ត និងការយល់ឃើញរបស់សិស្ស លើចំណុចទាំងនេះមានកម្រិតមធ្យម។ ហើយតម្លៃមធ្យមសរុបរួមគឺស្មើនឹង ៣.៤២ គឺឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ពីបញ្ហាប្រឈមដែលកើតមានឡើងចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២ ដូចជា៖ ខ្វះសម្ភារស្តាប់ (កាសែត ឌីស ម៉ាញ៉េ) ហួសពីកម្រិតយល់ដឹងរបស់សិស្ស ខ្វះលំហាត់អនុវត្តន៍ ហ្វុងអក្សរមានទំហំតូចមើលមិនសូវឃើញ វាក្យសព្ទមួយចំនួនពិបាកស្មុគស្មាញ ខ្វះសកម្មភាពដែលជាលំនាំនៃសមត្ថភាពអាន និងមិនឆ្លើយតបទៅសេចក្តីត្រូវការរបស់សិស្ស និងបរិបទនៃសង្គមបច្ចុប្បន្ន។

### សមាសភាគ ២- ការយល់ឃើញរបស់សិស្សលើសកម្មភាពនានារបស់គ្រូ

គ្រូជាកម្លាំងចលករដែលជំរុញឱ្យសង្គមជាតិមានការរីកចម្រើន និងជឿនលឿនតាមរយៈការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយចំណេះដឹងផ្នែកអក្សរ លេខ នព្វន្ត កុំព្យូទ័រ និងភាសា បំណិនប្រកបដោយភាពច្នៃប្រឌិត ការគិតបែបស៊ីជម្រៅ ការមានទំនាក់ទំនងល្អក្នុងសង្គម និងឥរិយាបទបែបភាតរភាព សុចរិតភាព និងប្រកបដោយការទទួលខុសត្រូវ។ ដូចនេះគ្រូបង្រៀនត្រូវមានចំណេះដឹងទូលំទូលាយ និងមានគរុកោសល្យច្បាស់លាស់ ជាពិសេសត្រូវចេះបង្កើត និងប្រើប្រាស់សកម្មភាពច្រើនសម្បូរបែបក្នុងការពន្យល់បកស្រាយ និងផ្ទេរចំណេះដឹងឱ្យសិស្សប្រកបដោយបំណិនប្រសប់ និងភាពច្នៃប្រឌិតខ្ពស់។ ហើយសកម្មភាពទាំងនោះរួមមាន៖ សមត្ថភាពក្នុងការប្រើប្រាស់ភាសាអង់គ្លេសច្បាស់លាស់និងស្ទាត់ជំនាញ ការបង្កើតនិងប្រើប្រាស់សម្ភារបង្រៀនឱ្យបានច្រើនតាមតែអាចធ្វើទៅបាន ការប្រគល់កិច្ចការឱ្យសិស្សក្រោយពីបញ្ចប់នូវរាល់មេរៀននីមួយៗ ការត្រួតពិនិត្យឱ្យបានដិតដល់ចំពោះវត្តមានរបស់សិស្សានុសិស្ស និងការវាយតម្លៃនូវសមត្ថភាពរបស់សិស្ស ក្នុងគោលបំណងស្វែងរកចំណុចរីកចម្រើន និងចំណុចខ្វះខាតដែលត្រូវកែលម្អបន្ថែមជាដើម។

ក្រាបទី២៖ ការឃើញរបស់សិស្សលើសកម្មភាពនានារបស់គ្រូ



ក្រាបទី២ នេះបង្ហាញពីសមត្ថភាព និងសកម្មភាពប្រចាំថ្ងៃរបស់គ្រូបង្រៀន ភាសាអង់គ្លេសក្នុងដំណើរការបង្រៀន និងរៀន។ ចំណុចដែលគួរកត់សម្គាល់គឺតម្លៃមធ្យមត្រឹមតែ២.២៤តែប៉ុណ្ណោះលើការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូ នេះបង្ហាញឲ្យឃើញថា គ្រូបង្រៀនមិនសូវបានចូលរួមញឹកញាប់ក្នុងការប្រើប្រាស់សម្ភារឧបទេសបង្រៀនសិស្សឡើយ ដោយហេតុថា ខ្វះការលើកទឹកចិត្តពីគណៈគ្រប់គ្រងសាលា ការតាមដានការបង្រៀន គ្រូគិតតែបង្រៀនគួរក្រៅម៉ោងជាជាងយកចិត្តទុកដាក់ក្នុងម៉ោងរដ្ឋ។ ម្យ៉ាងវិញទៀតគាត់ខ្វះថវិកា និងការច្នៃប្រឌិតក្នុងការផលិតសម្ភារឧបទេសនេះឡើង។ ចំណែកឯការដាក់កិច្ចការផ្ទះ ការត្រួតពិនិត្យវត្តមាន និងការវាយតម្លៃគ្រូ ពោលគឺតម្លៃមធ្យមទាបជាង ៣.៥០ ឃើញថាគ្រូបង្រៀនរបស់ពួកគេ មានការធ្វេសប្រហែសក្នុងការយកចិត្តទុកដាក់ប្រគល់កិច្ចការឲ្យសិស្សធ្វើ ការត្រួតពិនិត្យលើវត្តមានរបស់សិស្ស និងធ្វើការវាយតម្លៃលើសមត្ថភាពរបស់សិស្សដើម្បីស្វែងរកពីចំណុចល្អ និងចំណុចខ្វះខាតលើមុខវិជ្ជាភាសាអង់គ្លេស។ តម្លៃមធ្យមរួមលើសកម្មភាពនានារបស់គ្រូគឺស្មើនឹង ៣.១៤តែប៉ុណ្ណោះ បង្ហាញឲ្យឃើញថាគ្រូពុំសូវបានចូលរួមពេញលេញ ក្នុងការងាររបស់ខ្លួនឡើយ ពោលគឺគាត់ជាប់រវល់ក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅបន្ថែម។

**សមាសភាគ ៣- ការយល់ឃើញរបស់សិស្សលើការគោរពពេលវេលារបស់គ្រូ**

គ្រូបង្រៀនដែលល្អ គឺជាគ្រូបង្រៀនដែលចេះគ្រប់គ្រងពេលវេលាបានល្អក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងពេលវេលាបានល្អអាចធ្វើឱ្យទទួលបានការចូលរួមយ៉ាងសកម្មរបស់សិស្ស។ ការត្រៀមខ្លួនខ្ពស់របស់គ្រូ ការធ្វើផែនការទុកជាមុន និងការបែងចែកពេលវេលាដាច់ដោយឡែករបស់គ្រូ គឺអាចធ្វើឲ្យគ្រូមានពេលវេលាផ្សេងទៀតសម្រាប់ការប្រឹក្សា និងការណែនាំដល់សិស្ស ជាពិសេសការរៀបចំរដ្ឋបាលថ្នាក់រៀន និងកិច្ចការផ្សេងទៀតដែលចាំបាច់សម្រាប់គ្រូ។ ការរៀបចំផែនការ និងការរៀបចំសកម្មភាពនិងកម្មវិធីសិក្សាសម្រាប់សិស្សអាចឱ្យពួកគេមានការអភិវឌ្ឍផ្នែករាងកាយ និងខាងបញ្ញាស្មារតី។ ការលះបង់ ការប្តេជ្ញាចិត្តរបស់គ្រូបង្រៀន និងការគាំទ្រផ្នែករដ្ឋបាលត្រឹមត្រូវសម្រាប់គ្រូបង្រៀននិងសិស្សមាន

ឥទ្ធិពលវិជ្ជមានលើជំនាញគ្រប់គ្រងពេលវេលារបស់គ្រូបង្រៀន និងឥទ្ធិពលផ្ទាល់ជាមួយការអនុវត្តរបស់សិស្ស។

ក្រាបទី៣៖ ការយល់ឃើញរបស់សិស្សលើការគោរពពេលវេលារបស់គ្រូ




នៅក្នុងក្រាបទី៣នេះ គឺពិពណ៌នាពីនិយតភាពរបស់គ្រូបង្រៀនភាសាអង់គ្លេសក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន។ តាមរយៈចម្លើយរបស់សិស្សមានរហូតដល់ ៧៦%ក្នុងចំណោម សិស្ស ៥២៩នាក់ បានឆ្លើយថាគ្រូបង្រៀនរបស់ពួកគេភាគច្រើនគោរពពេលវេលា និងបំពេញតួនាទីបានល្អក្នុងកិច្ចការបង្រៀន និងកិច្ចការផ្សេងៗទៀតនៅក្នុងសាលា។ ដោយឡែកមានតែគ្រូចំនួន ២៤% តែប៉ុណ្ណោះដែលមិនបានចូលរួមគោរពពេលវេលា និងអនុវត្តភារកិច្ចរបស់ខ្លួនបានល្អ និងទៀងទាត់ ហើយមូលហេតុដែលនាំឱ្យពួកគាត់មិនបានចូលរួមបង្រៀនបានល្អ គឺបណ្ដាល មកពីពួកគាត់ជាប់រវល់ជាមួយមុខរបរទី២ ក្នុងការស្វែងរកចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែមលើប្រាក់ខែដែលមានស្រាប់ ផ្ទះរបស់នៅឆ្ងាយពិសាលារៀន វិន័យធូររលុងរបស់ថ្នាក់ដឹកនាំសាលានិងការមើលបំណាំគ្នារវាងគ្រូគ្នាឯង ហើយកត្តាទាំងនេះ បានជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សារបស់សិស្ស។

## សមាសភាគ ៤- ការយល់ឃើញរបស់សិស្សលើសៀវភៅសិក្សាគោលធៀបនឹងសមត្ថភាពរបស់គាត់

សៀវភៅសិក្សាគោលដែលល្អ គឺជាសៀវភៅដែលបានគិតគូរជិតដល់ និងស៊ីជម្រៅលើ កម្រិតយល់ដឹង និងសមត្ថភាពរបស់អ្នកសិក្សា ហេតុដូចនេះហើយ បានជាអ្នករៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សាបានសិក្សាពីតម្រូវការចាំបាច់ ភាពពេញចិត្ត សមត្ថភាព បរិបទសង្គម និងតម្រូវការទីផ្សារការងាររបស់ប្រទេស។ ជាក់ស្តែង សៀវភៅសិក្សាគោលភាសាអង់គ្លេសគ្រប់កម្រិតថ្នាក់ក៏បានសិក្សាយ៉ាងស៊ីជម្រៅ និងអនុវត្តតាមក្របខណ្ឌរួមរបស់អឺរ៉ុបស្តីពីកម្រិតនៃភាសាបរទេស និងគោរពតាមគោលការណ៍អង់គ្លេសបែបអង់គ្លេស។ ថ្មីៗនេះ ការិយាល័យអភិវឌ្ឍកម្មវិធីសិក្សាភាសាបរទេសនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានចុះស្ទង់មតិពីសិស្សគ្រូដើម្បីដឹងពីតម្រូវការ និងសមត្ថភាពរបស់សិស្សជាក់ស្តែង។

ក្រាបទី៤៖ ការយល់ឃើញរបស់សិស្សលើសៀវភៅសិក្សាគោលធៀបនឹងសមត្ថភាពរបស់គាត់




ក្រាបខាងលើនេះ ចង្អុលបង្ហាញពីការយល់ឃើញរបស់សិស្សលើសៀវភៅសិក្សា គោលធៀបនឹងកម្រិតនៃការយល់ដឹងរបស់ពួកគេ។ ចំពោះសិស្សថ្នាក់ទី ១០ យល់ឃើញថាសៀវភៅសិក្សាគោលភាសាអង់គ្លេសនេះសមស្របទៅនឹងចំណេះដឹងរបស់ពួកគេដែលមានភាគរយរហូតដល់ ៥៨% ហើយមានតែ ៤២% ប៉ុណ្ណោះគិតថាវាមិនសមស្រប និងលើសពីកម្រិតយល់ដឹងរបស់ពួកគេ ខណៈពេលដែលសិស្សថ្នាក់ទី១១ ក៏គិតស្រ

ជៀងគ្នាដែរលើសៀវភៅសិក្សាគោលភាសាអង់គ្លេសដែលពួកគេកំពុងសិក្សា តែចំណុចដែលគួរកត់សម្គាល់គឺសៀវភៅសិក្សាគោលថ្នាក់ទី១២ គឺសិស្ស ៥៣ % គិតថាសៀវភៅសិក្សាគោលភាសាអង់គ្លេសមិនសមស្របនឹងកម្រិតនៃការយល់ដឹងរបស់ពួកគេ ហើយត្រឹមតែ៤៧%ប៉ុណ្ណោះឆ្លើយថាវាសមស្របនឹងសមត្ថភាពរបស់ពួកគេ។ បើយើងសង្កេតមើលពីការយល់ឃើញរួមរបស់សិស្សលើសៀវភៅសិក្សាគោលទាំង៣កម្រិត គឺសិស្ស ៥៩% ឯកភាពថាសៀវភៅសិក្សាគោលនេះពិតជាសមស្របនឹងកម្រិតយល់ដឹងរបស់ពួកគេ និង៤១% គិតថាវាមិនសមស្របនឹងសមត្ថភាពរបស់ពួកគេឡើយផ្អែកលើចំណេះដឹងមូលដ្ឋានគ្រឹះពីថ្នាក់ក្រោម គឺមានន័យថាពួកគេមិនមានចំណេះដឹងមូលដ្ឋានគ្រឹះពីថ្នាក់ក្រោមឡើយ ដែលធ្វើឱ្យពួកគេរៀនមិនទាន់។ ម្យ៉ាងវិញទៀត សៀវភៅសិក្សាគោលភាសាអង់គ្លេសនេះ មានលក្ខណៈស្មុគស្មាញត្រង់ផ្នែកវេយ្យាករណ៍ ខ្វះការបកស្រាយ និងស្រាយបំភ្លឺច្បាស់លាស់លើរូបមន្ត និយមន័យ និងការលើកជាឧទាហរណ៍ និងវាក្យសព្ទពិបាក ព្រមទាំងមិនបានធ្វើបច្ចុប្បន្នភាពឱ្យស្របតាមយុគសម័យថ្មី គួបផ្សំនឹងវិធីសាស្ត្របង្រៀនរបស់គ្រូក្នុងការផ្ទេរចំណេះដឹងដល់សិស្សមិនបានល្អ។

### សមាសភាគ ៥- ការយល់ឃើញរបស់សិស្សលើម៉ោងសិក្សាក្នុងមួយសប្ដាហ៍

អ្នកអភិវឌ្ឍកម្មវិធីសិក្សា តែងតែគិតទៅដល់ការកំណត់ពេលវេលា និងម៉ោងសិក្សាដើម្បីឱ្យមានភាពស៊ីគ្នារវាងសៀវភៅសិក្សាគោលនិងចំនួនម៉ោងកំណត់ និងដើម្បីឆ្លើយតបទៅនឹងចំនួនម៉ោងសិក្សាប្រចាំឆ្នាំ។ នៅក្នុងកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសថ្នាក់មធ្យមសិក្សាទុតិយភូមិបានតម្រូវឱ្យសិស្សសិក្សាភាសាអង់គ្លេស ចំនួន៤ម៉ោងនៅថ្នាក់ទី១០ និង ២ម៉ោងនៅកម្រិតថ្នាក់ទី១១ និងទី១២ ក្នុងមួយសប្ដាហ៍។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតអនុគណៈកម្មការតាមមុខវិជ្ជា ក្នុងនោះអនុគណៈកម្មការភាសាអង់គ្លេស បាននឹងកំពុងធ្វើបច្ចុប្បន្នភាពសៀវភៅសិក្សាភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២ ហើយក៏បានធ្វើការកែសម្រួលម៉ោងសិក្សាក្នុងមួយសប្ដាហ៍ផងដែរ។ ចំនួនម៉ោងសិក្សាថ្មីដែលគ្រោង នឹងដាក់ឱ្យអនុវត្តជាមួយសៀវភៅសិក្សាគោលថ្មីមានចំនួន៤ម៉ោងក្នុងមួយសប្ដាហ៍នៅគ្រប់កម្រិតថ្នាក់ដើម្បីជំរុញសកម្មភាព

បង្រៀន និងរៀនរបស់សិស្សឱ្យបានកាន់តែច្រើន ជាពិសេសសិស្សមានពេលវេលាគ្រប់គ្រាន់ក្នុងការហ្វឹកហាត់ភាសាអង់គ្លេសរបស់ពួកគេឱ្យបានកាន់តែប្រសើរឡើងជាងមុន។

ក្រាបទី៥៖ ការយល់ឃើញរបស់សិស្សលើម៉ោងសិក្សាក្នុងមួយសប្តាហ៍




ក្រាបទី៥នេះ បង្ហាញពីការយល់ឃើញរបស់សិស្សទាក់ទងនឹងម៉ោងសិក្សាភាសាអង់គ្លេសក្នុងមួយសប្តាហ៍។ ចំពោះម៉ោងសិក្សាថ្នាក់ទី១០ សិស្សចំនួន៨១% គិតថាសមស្របនិងគ្រប់គ្រាន់សម្រាប់ពួកគេចំពោះម៉ោងសិក្សាភាសាអង់គ្លេសនៅកម្រិតថ្នាក់ទី១០មានចំនួន៤ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះគ្រូអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្រៀន ចំណែកឯសិស្សក៏មានពេលវេលាសមរម្យក្នុងការអនុវត្ត និងហ្វឹកហាត់នូវខ្លឹមសារ ដែលមានក្នុងសៀវភៅនោះនៅពេលដែលពួកគេបានសិក្សារួច ហើយសិស្សមានចំនួន១៩% តែប៉ុណ្ណោះដែលមិនឯកភាពលើម៉ោងសិក្សាភាសាអង់គ្លេសថ្នាក់ទី១០ តែផ្ទុយទៅវិញសិស្សមិនសូវពេញចិត្តនូវចំនួនម៉ោងសិក្សានៅកម្រិតថ្នាក់ទី១១ និងទី១២ ខណៈពេលដែលម៉ោងសិក្សាមានចំនួនតែ២ម៉ោង ក្នុងមួយសប្តាហ៍ សិស្សភាគច្រើនសម្តែងភាពមិនពេញចិត្ត និងមិនឯកភាពលើម៉ោងសិក្សានៅកម្រិតថ្នាក់ទាំងពីរនេះ ហើយសិស្សមានចំនួនរហូតដល់ ៥៥% សម្រាប់ថ្នាក់ទី១១ និង៧០% សម្រាប់ថ្នាក់ទី១២ ដែលមិនយល់ស្របចំពោះម៉ោងសិក្សាភាសាអង់គ្លេសនេះ ពីព្រោះម៉ោងសិក្សានេះមានតែ២ម៉ោងតែប៉ុណ្ណោះក្នុងមួយសប្តាហ៍

ហើយកត្តាទាំងនេះអាចបណ្ដាលឱ្យពួកគេមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការហ្វឹកហាត់នូវចំណុចសំខាន់ៗ ដែលគ្រូបានបង្រៀនក៏ដូចជា ពិភាក្សាជាក្រុមក្នុងគោលបំណងផ្លាស់ប្ដូរនូវចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក។ ម៉្យាងវិញទៀតសិស្សមួយចំនួនបានលើកឡើងថា ភាសាអង់គ្លេសមានសារៈសំខាន់ខ្លាំងណាស់នៅពេលដែលពួកគេរៀននៅមហាវិទ្យាល័យ ដូចនេះពួកគេត្រូវការម៉ោងសិក្សាច្រើនជាងនេះ ហើយកត្តាដែលមានម៉ោងសិក្សាតិចតួចលើមុខវិជ្ជាភាសាអង់គ្លេសនេះធ្វើឲ្យពួកគេរៀនមិនបានជិតដល់ និងមិនមានមូលដ្ឋានគ្រឹះគ្រប់គ្រាន់មុននឹងឈានជើងចូលថ្នាក់ឧត្ដមសិក្សា។

### សមាសភាគ ៦- ការយល់ឃើញរបស់សិស្សលើគ្រូបង្រៀនភាសាអង់គ្លេស

គ្រូបង្រៀនគឺជាកោសិកាដ៏សំខាន់ក្នុងការរួមចំណែកជួយអភិវឌ្ឍធនធានមនុស្ស ដែលជាឆ្អឹងខ្នងរបស់សង្គមឱ្យមានការរីកចម្រើន និងជឿនលឿន។ គ្រូបង្រៀនដែលល្អត្រូវមានលក្ខណៈសម្បត្តិសំខាន់ៗដូចជាៈ មានចំណេះដឹងលើមុខវិជ្ជាឯកទេស ចំណេះដឹងលើប្រព័ន្ធបច្ចេកវិទ្យា មានការប្ដេជ្ញាចិត្តខ្ពស់លើការបង្រៀនសិស្ស ជំរុញលើកទឹកចិត្តសិស្សគ្រប់រូបភាពឱ្យចូលរួមក្នុងការសិក្សា មានទំនាក់ទំនងល្អជាមួយសិស្ស គ្រូនាយក សហគមន៍ និងអាណាព្យាបាលសិស្ស មានគម្រូល្អក្នុងភាពជាអ្នកដឹកនាំ មានការស្រាវជ្រាវ និងមានវិធីសាស្ត្រល្អក្នុងការផ្ទេរចំណេះដឹងឱ្យសិស្ស (Aze, 2005)។

ក្រាបទី៦៖ ការយល់ឃើញរបស់សិស្សលើគ្រូបង្រៀនភាសាអង់គ្លេស




លទ្ធផលល្អនៃការសិក្សារបស់សិស្ស គឺអាស្រ័យលើគ្រូបង្រៀនដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ហើយក្រាហ្វិកខាងលើ បានបង្ហាញពីការយល់ឃើញរបស់សិស្សលើការងារបង្រៀននិងសកម្មភាពគ្រប់គ្រងការងារបង្រៀនរបស់គ្រូភាសាអង់គ្លេស ដែលកំពុងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ តម្លៃមធ្យមលើការប្រើប្រាស់ភាសាអង់គ្លេសក្នុងម៉ោងសិក្សា ការគ្រប់គ្រង និងដឹកនាំសកម្មភាពសិស្សក្នុងថ្នាក់ និងគ្រប់គ្រងពេលវេលានៃការបង្រៀន ការលើកទឹកចិត្តរបស់គ្រូចំពោះសិស្ស និងឥរិយាបទក្នុងការបង្រៀនរបស់គ្រូខ្ពស់ជាង ៣.៥០ គឺមានន័យថាសិស្សសម្តែងនូវភាពពេញចិត្តខ្ពស់លើចំណុចទាំងនេះរបស់គ្រូ ខណៈពេលដែលមានតែចំណុច២ តែប៉ុណ្ណោះគឺ វិធីសាស្ត្របង្រៀនមានតម្លៃមធ្យមស្មើនឹង៣.៣៩ និងការទំនាក់ទំនងអាណាព្យាបាលរបស់គ្រូមានតម្លៃមធ្យមស្មើនឹង ២.៩៨ គឺ មានន័យថាគ្រូពុំទាន់ខិតខំអស់ពីលទ្ធភាពលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងការសហការជាមួយអាណាព្យាបាលដើម្បីលើកកម្ពស់លទ្ធផលសិក្សាភាសាអង់គ្លេស។

តាមរយៈលទ្ធផលនៃការសម្ភាសបន្ថែមបានរកឃើញថា គ្រូបង្រៀនភាគច្រើនប្រើប្រាស់តែសៀវភៅសិក្សាគោលក្នុងការបង្រៀនសិស្ស មិនបានបង្កើត និងរៀបចំសម្ភារឧបទេសបន្ថែមក្នុងការបង្រៀន ដើម្បីឱ្យសិស្សងាយយល់ និងឆាប់ចាប់បាន ជាពិសេសអាចសម្រេចនូវវត្ថុបំណងនៃមេរៀន។ ការសិក្សាមួយបានបង្ហាញថា ការប្រើប្រាស់សម្ភារឧបទេសសម្រាប់ទ្រទ្រង់ដល់ការបង្រៀន និងរៀន មានសារៈសំខាន់ខ្លាំងណាស់ដល់ការសិក្សាភាសាបរទេស និងជាពិសេសមានឥទ្ធិពលវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស។ ហើយវាមិនត្រឹមតែជួយឱ្យគ្រូសម្រេចវត្ថុបំណងនៃមេរៀននោះទេ ថែមទាំងធ្វើឱ្យសិស្សកាន់តែចាប់អារម្មណ៍ និងចូលរួមក្នុងដំណើរការបង្រៀន និងចូលរួមក្នុងសកម្មភាពផ្សេងៗដែលនាំឱ្យលទ្ធផលសិក្សារបស់ពួកគេមានភាពវិជ្ជមាន។ ទន្ទឹមនឹងនេះ គ្រូបង្រៀនមិនទាន់បានប្រើប្រាស់វិធីសាស្រ្តបង្រៀន សមស្របនៅឡើយ (គ្រូប្រើប្រាស់វិធីសាស្រ្តបង្រៀនបែបបុរាណ និងមិនធ្លាប់ទទួលបានការបណ្តុះបណ្តាលលើវិធីសាស្រ្តថ្មីៗ និងទំនើបនាសតវត្សទី២១) និងការមិនយកចិត្តទុកដាក់បង្រៀនដោយប្រើប្រាស់ និងបង្កើតសម្ភារឧបទេសក្នុងការបង្រៀនសិស្សឱ្យមានប្រសិទ្ធភាព។ ហើយតម្លៃមធ្យមរួមស្មើនឹង ៣.៦៩ គឺសិស្សបានវាយតម្លៃខ្ពស់លើសមត្ថភាព ចំណេះដឹង និងសកម្មភាពនានារបស់គ្រូបង្រៀនភាសាអង់គ្លេស។ តាមរយៈការស្រាវជ្រាវ គ្រូភាសាអង់គ្លេសភាគច្រើនសុទ្ធតែមានគុណវុឌ្ឍិ និងកម្រិតសញ្ញាបត្រខ្ពស់ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់គឺពួកគាត់ខ្វះនូវការបណ្តុះបណ្តាលបន្ថែមលើជំនាញ និងវិធីសាស្រ្តបង្រៀនថ្មីៗ។

**សមាសភាគ ៧- ការយល់ឃើញរបស់សិស្សលើការគ្រប់គ្រង និងដឹកនាំរបស់សាលា**

ការដឹកនាំគ្រប់គ្រងសាលាគឺផ្នែកមួយដ៏សំខាន់នៅក្នុងដំណឹកនាំការបង្រៀន និងរៀន ហើយវាក៏បានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការសម្រេចចក្ខុវិស័យ និងបេសកម្មអប់រំផងដែរ។

ថ្មីៗកន្លងទៅនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចតំឡើងប្រាក់បៀវត្សរ៍ជូនគណៈគ្រប់គ្រងសាលា ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងដឹកនាំសាលាឱ្យបានល្អប្រសើរជាងមុន ពីព្រោះការដឹកនាំគ្រប់គ្រងល្អ អាចធ្វើឱ្យសិស្សទទួលបានលទ្ធផលសិក្សាល្អផងដែរ។

គណៈគ្រប់គ្រងសាលាមានតួនាទីសំខាន់ៗដូចជា៖ គ្រប់គ្រងថវិកាដើម្បីគាំទ្រដល់ការអភិវឌ្ឍសាលារៀន ចូលរួមក្នុងការរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សា បណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិធីសាស្ត្របង្រៀនតាមដាននិងវាយតម្លៃបុគ្គលិកក្រោមឱវាទ មានទំនាក់ទំនងល្អជាមួយសហគមន៍អាជ្ញាធរដែនដី និងអាណាព្យាបាលសិស្សក្នុងគោលបំណងសហការ និងជំរុញប្រសិទ្ធភាពអប់រំ។

ក្រាបទី៧៖ ការយល់ឃើញរបស់សិស្សលើការគ្រប់គ្រង និងដឹកនាំរបស់សាលា




ក្រាបទី៧ពណ៌នាពីការយល់ឃើញរបស់សិស្សលើការគ្រប់គ្រងនិងដឹកនាំរបស់សាលាពាក់ព័ន្ធនឹងការបង្រៀននិងរៀនភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិ។ ការគ្រប់គ្រងនិងដឹកនាំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍសមត្ថភាពនិងចំណេះដឹងផ្នែកភាសាអង់គ្លេសរបស់សិស្ស និងរក្សានូវនិរន្តរភាពនៃការបង្រៀននិងរៀនរបស់គ្រូ និងសិស្ស។ ម្យ៉ាងវិញទៀតអ្នកដឹកនាំ និងគ្រប់គ្រងសាលាក៏មានតួនាទីសម្រេចនូវចក្ខុវិស័យស្នូលរបស់ក្រសួងអប់រំ ហើយដើម្បីសម្រេចនូវចក្ខុវិស័យនេះពួកគាត់ត្រូវបំពេញតួនាទីដូចជា៖ ការកសាងស្មារតីក្រុមនៅក្នុងអង្គភាពរបស់ខ្លួន ការជួយអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់បុគ្គលិកការចូលរួមក្នុងការរៀបចំ និងអភិវឌ្ឍកម្មវិធីសិក្សា ការរៀបចំ និងបង្កើតចក្ខុវិស័យ និងបេសកកម្មរបស់សាលា ការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា សហគមន៍ដើម្បីគាំទ្រដល់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងចីរភាព។

ការដឹកនាំ និងគ្រប់គ្រងមានគោលបំណងដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង ស្វែងរកវិធីសាស្រ្តល្អៗដែលបម្រើឱ្យការអប់រំមានការអភិវឌ្ឍនិងរីកចម្រើន និងគ្រប់គ្រង តាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស( Nomnian, 2018 )។

យោងតាមក្រាបខាងលើ បានបង្ហាញថា តម្លៃមធ្យមនៃការរៀបចំទុកដាក់ និងបំពេញបន្ថែមឯកសារផ្សេងៗក្នុងបណ្ណាល័យ ផលធៀបសិស្ស/ថ្នាក់ ការត្រួតពិនិត្យ និងការវាយតម្លៃការបង្រៀនរបស់គ្រូទាបជាង ៣.៥០ នេះបញ្ជាក់ឱ្យឃើញពីភាពមិនសូវពេញចិត្តរបស់សិស្សលើចំណុចទាំងនេះ ហើយក៏បង្ហាញពីភាពទន់ខ្សោយ និងភាពខ្វះខាតរបស់សាលាក្នុងភាពជាអ្នកដឹកនាំ រៀបចំ និងគាំទ្រដល់ការបង្រៀន និងរៀនភាសាអង់គ្លេសប្រកបដោយប្រសិទ្ធភាព។ ដោយឡែកតម្លៃមធ្យមខ្ពស់ជាង ៣.៥០ បានបង្ហាញពីភាពពេញចិត្តខ្ពស់របស់សិស្សលើអគារសិក្សា និងថ្នាក់រៀន ដែលជាផ្នែកមួយជួយពង្រឹងគុណភាពអប់រំនៃការសិក្សាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិឱ្យបានកាន់តែល្អប្រសើរ។

### ៤.២.២ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន លើការរៀន និងបង្រៀនភាសាអង់គ្លេសសិស្សមធ្យមសិក្សាទុតិយភូមិ

នៅក្នុងតារាងទិន្នន័យខាងក្រោម មានបង្ហាញពីមធ្យមភាគការឆ្លើយតបរបស់គ្រូបង្រៀន លើការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ តាមបទពិសោធន៍ នៃការបង្រៀន របស់លោកគ្រូ-អ្នកគ្រូ នៅកម្រិតមធ្យមសិក្សាទុតិយភូមិនាពេលកន្លងមក។

តារាង4.1៖ ក.ការអនុវត្តកម្មវិធីសិក្សា

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មុខវិជ្ជាភាសាអង់គ្លេសបានបង្រៀនចប់ តាមកម្មវិធីសិក្សា | 3.14 | មធ្យម |
| ២ | មានបំណែងចែកកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេស | 4.20 | ល្អ |

| | | | |
|---|---|---|---|
| ៣ | កែសម្រួលមេរៀនផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស | 4.06 | ល្អ |
| ៤ | មានភាពច្បាស់លាស់ លើរបាយម៉ោងមុខវិជ្ជាភាសាអង់គ្លេស | 4.18 | ល្អ |
| ៥ | សៀវភៅពុម្ពសិក្សា សមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស | 2.94 | មធ្យម |
| សរុប | | 3.70 | ល្អ |

តារាងខាងលើ បានបង្ហាញថា សមាសភាគទាំង៥ នៃការអនុវត្តកម្មវិធីសិក្សារបស់លោកគ្រូ អ្នកគ្រូ នៅតាមវិទ្យាល័យសំណាកមានតម្លៃមធ្យមភាគខុសៗគ្នា។ មានសមាសភាគចំនួន៣ មានកម្រិតល្អ និង២សមាសភាគទទួលបានកម្រិតមធ្យម។ ផ្នែកដែលមានលំដាប់មធ្យមភាគខ្ពស់ជាច់គេ គឺមានបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដែលមានមធ្យមភាគ=4.20 ទទួលបានកម្រិតល្អ។ សមាសភាគ ដែលមានលំដាប់ពិន្ទុមធ្យមភាគទាបជាងគេបង្អស់ ដែលមានមធ្យមភាគ =2.94 ស្ថិតនៅកម្រិតមធ្យម គឺ សៀវភៅពុម្ពសិក្សាសមស្របជាមួយកម្រិតយល់ដឹងរបស់សិស្ស ។

តារាង 4.2 ៖ ខ. ដំណើរការបង្រៀន

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានរៀបចំកិច្ចតែងការតាមបំណែងចែកកម្មវិធីសិក្សា | 2.64 | មធ្យម |
| ២ | បានអនុវត្តតាមគ្រប់ជំហានទាំង៥ នៃកិច្ចតែងការបង្រៀន | 3.52 | ល្អ |
| ៣ | បានចែងចែកក្រុមកិច្ចការ ដល់សិស្សសម្រាប់សកម្មភាពក្នុងថ្នាក់ | 3.52 | ល្អ |
| ៤ | មានចំណេះដឹង និងជំនាញវិជ្ជាជីវៈ ទាក់ទងទៅនឹងវិធីសាស្ត្របង្រៀនភាសាអង់គ្លេស | 3.68 | ល្អ |
| ៥ | យល់ច្បាស់ពីតួនាទីរបស់ខ្លួន ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនភាសាអង់គ្លេស | 3.52 | ល្អ |
| ៦ | មានឧទាហរណ៍ក្នុងការពន្យល់ និងបំណកស្រាយដោយអនុវត្តទៅតាមជំហាននៃកិច្ចតែងការ | 3.76 | ល្អ |
| ៧ | ផ្តល់កិច្ចការផ្ទះដល់សិស្សជាប្រចាំ | 2.72 | មធ្យម |
| ៨ | មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន | 4.24 | ល្អណាស់ |
| សរុប | | 3.45 | ល្អ |

តាមតារាងខាងលើបានបង្ហាញថា សូចនាករទាំង៨ នៃដំណើការបង្រៀន របស់លោកគ្រូអ្នកគ្រូ នៅតាមវិទ្យាល័យ មានកម្រិតមធ្យមភាគខុសៗគ្នា។ ផ្នែកដែលមានកម្រិតមធ្យមភាគខ្ពស់ដាច់គេក្នុងលំដាប់ទី១ គឺ មានសមត្ថភាពសមស្របតាមកម្រិតវិជ្ជាជីវៈបង្រៀន ដែលមានមធ្យមភាគ =4.24 ទទួលបានកម្រិតល្អណាស់ ហើយមានសមាសភាគ៥ទៀតដែលស្ថិតនៅ កម្រិតមធ្យមភាគប្រហាក់ប្រហែលគ្នាពីចន្លោះមធ្យមភាគ =3.52 ដល់មធ្យមភាគ =3.76 ក្នុងកម្រិតល្អ។ ជារួមដោយផ្អែកលើការសរុបពិន្ទុមធ្យមភាគសមាសភាគទី២នេះ ទទួលបានមធ្យមភាគ =3.45 ស្ថិតក្នុងកម្រិតល្អ អាចចាត់ទុកថា សមាសភាគ នេះមិនមែនជាកត្តាជះឥទ្ធិពលខ្លាំងដល់លទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសដែរ។

តារាង 4.3 ៖ គ. ទំនាក់ទំនង គ្រូ-សិស្ស

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានសម្របសម្រួល ដល់ដំណើរការសិក្សារបស់សិស្ស | 3.52 | ល្អ |
| ២ | បង្កបរិយាកាសឱ្យសិស្សរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុម | 2.80 | មធ្យម |
| ៣ | បានជំរុញការអភិវឌ្ឍនៃការគិតត្រិះរិះពិចារណារបស់សិស្ស | 3.76 | ល្អ |
| ៤ | បានជំរុញ និងលើកទឹកចិត្តសិស្សានុសិស្សក្នុងការសិក្សា | 3.72 | ល្អ |
| ៥ | ជំរុញការចូលរួមរបស់សិស្ស ក្នុងសកម្មភាពសិក្សា | 4.16 | ល្អ |
| ៦ | បានបង្កើនភាពសហការក្នុងដំណើរការបង្រៀន និងរៀន | 3.52 | ល្អ |
| ៧ | បានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា | 4.21 | ល្អណាស់ |
| ៨ | សិស្សានុសិស្សរៀនមុខវិជ្ជាភាសាអង់គ្លេសដោយភាពរីករាយ | 3.60 | ល្អ |
| សរុប | | 3.66 | ល្អ |

តារាងខាងលើបានបង្ហាញពី សូចនាករទាំង៨ នៃការទំនាក់ទំនងគ្រូ-សិស្ស នៅតាមវិទ្យាល័យសំណាក។ សូចនាករស្ទើរតែទាំងអស់ស្ថិតក្នុងកម្រិតល្អ។ សូចនាករដែលមានលំដាប់មធ្យមភាគខ្ពស់ដាច់គេគឺ ការបានផ្តល់តម្លាភាពក្នុងការបង្រៀន និងលទ្ធផលសិក្សា ដែលមានមធ្យមភាគ =4.21 ទទួលបានកម្រិតល្អណាស់។

សូចនាករដែលមានមធ្យមភាគទាបជាងគេគឺ បង្កបរិយាកាសឱ្យសិស្សរៀនតាមបែបសហការគ្នា រិះរក និងដោះស្រាយបញ្ហាជាក្រុមមានមធ្យមភាគ =2.80 ស្ថិតនៅក្នុងកម្រិតមធ្យម។

តារាង 4.4 ៖ ឃ. ការប្រើប្រាស់សម្ភារៈឧបទ្ទេស

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្រ | 2.96 | មធ្យម |
| ២ | បានប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស | 2.92 | មធ្យម |
| ៣ | បានប្រើប្រាស់សម្ភារៈឧបទ្ទេស ក្នុងការបង្រៀន ញឹកញាប់ | 3.20 | មធ្យម |
| ៤ | បានប្រើប្រាស់រូបភាពទាក់ទងទៅនឹងសកម្មភាពនៃខ្លឹមសារមេរៀនជាប្រចាំ | 3.28 | មធ្យម |
| សរុប | | 3.09 | មធ្យម |

តារាងខាងលើ បង្ហាញសូចនាករអំពីការប្រើប្រាស់សម្ភារៈឧបទ្ទេស។ ក្នុងចំណោមសូចនាករទាំង៤ បង្ហាញថា ការប្រើប្រាស់សម្ភារៈឧបទ្ទេស សម្រាប់ការបង្រៀន អាចជាកត្តាចម្បងទី១ ដែលធ្វើឲ្យប៉ះពាល់ដល់លទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេស។ ក្នុងនោះដែរ បើយើងក្រឡេកមើលពិន្ទុមធ្យមភាគ ដែលទាបជាងគេមាន២សមាសភាគគឺ (១) មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ ឆ្លើយតបនឹងខ្លឹមសារមេរៀនក្នុងការបង្រៀនតាមវិធីសាស្ត្រ(២)បានប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស។ សរុបរួមការប្រើប្រាស់សម្ភារៈឧបទ្ទេសស្ថិតក្នុងកម្រិតមធ្យម។

តារាង 4.5 ៖ ទិន្នន័យសរុបរបស់គ្រូបង្រៀន

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | ការអនុវត្តកម្មវិធីសិក្សា | 3.70 | ល្អ |

| | | | |
|---|---|---|---|
| ខ | ដំណើរការបង្រៀន | 3.45 | ល្អ |
| គ | ទំនាក់ទំនងគ្រូ-សិស្ស | 3.66 | ល្អ |
| ឃ | ការប្រើប្រាស់សម្ភារៈឧបទ្ទេស | 3.09 | មធ្យម |
| សរុប | | 3.48 | ល្អ |

តាមតារាងទិន្នន័យខាងលើបង្ហាញថា មធ្យមភាគរួមលើការយល់ឃើញរបស់គ្រូបង្រៀន លើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេសគឺមានមធ្យមភាគ=3.48 ទទួលបានកម្រិតល្អ។ ផងដែរនោះ ក្នុងចំណោមសមាសធាតុធំៗទាំង៤ ក្នុងតារាងសមាសធាតុដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេលំដាប់ទី១គឺការអនុវត្តកម្មវិធីសិក្សា ដែលមានតម្លៃមធ្យមភាគ=3.70 លំដាប់ទី២គឺទំនាក់ទំនងគ្រូ-សិស្ស(មធ្យមភាគ=3.66) និងសមាសធាតុ ដែលមានតម្លៃមធ្យមភាគទាប (មធ្យមភាគ =3.09) ជាងគេបំផុតនោះគឺ ការប្រើប្រាស់សម្ភារៈឧបទ្ទេស ។

### ៤.២.៣ ទិន្នន័យពីការឆ្លើយតបរបស់គណៈគ្រប់គ្រង លើការពង្រឹងលើការបង្រៀន និងរៀន មុខវិជ្ជាភាសាអង់គ្លេស

ក្នុងតារាងទិន្នន័យនេះ មានបង្ហាញពីមធ្យមភាគសរុបកត្តាចម្បងៗមួយចំនួន ក្នុងការពង្រឹងដល់ការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស តាមបទពិសោធន៍របស់គណៈគ្រប់គ្រងទាំង០៩វិទ្យាល័យ។

តារាង4.6៖ ក. ការរៀបចំផែនការកែលម្អកម្មវិធីភាសាអង់គ្លេស

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ផែនការអភិវឌ្ឍផ្នែកភាសាអង់គ្លេស | 3.45 | ល្អ |
| ២ | មានកញ្ចប់ថវិកាគ្រប់គ្រាន់ សម្រាប់អភិវឌ្ឍមុខវិជ្ជាភាសាអង់គ្លេស | 3.15 | មធ្យម |
| ៣ | ផែនការបំពាក់ធនធានរូបវន្ត សម្ភារៈបរិក្ខារ បន្ទប់អនុវត្ត ភាសាអង់គ្លេស | 3.75 | ល្អ |
| ៤ | បានអភិវឌ្ឍកម្មវិធីសិក្សាផ្នែកភាសាអង់គ្លេស | 4.20 | ល្អ |

| | | |
|---|---|---|
| សរុប | 3.64 | ល្អ |

តារាងខាងលើបានបង្ហាញពី សមាសភាគទាំង៤ នៃការរៀបចំផែនការកែលម្អលើការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេស។ នាយកសាលាមានផែនការអភិវឌ្ឍកម្មវិធីសិក្សាផ្នែកភាសាអង់គ្លេស និងមានផែនការបំពាក់ធនធានរូបវន្ត សម្ភារៈបរិក្ខារ បន្ទប់អនុវត្តភាសាស្ថិតក្នុងកម្រិតល្អ។ តាមរយៈការគណនា លើសូចនាករទាំងអស់ សរបញ្ជាក់ឱ្យឃើញថាគណៈគ្រប់គ្រងមានផែនការពង្រឹង និងកែលម្អកម្មវិធីភាសាអង់គ្លេស ឆ្លើយតបទៅនឹងការរៀន និងបង្រៀនភាសាអង់គ្លេសបានល្អ។

តារាង4.7 ៖ ខ. ការកសាងសមត្ថភាពគ្រូ

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានផែនការអភិវឌ្ឍសមត្ថភាពដល់គ្រូភាសាអង់គ្លេស | 3.95 | ល្អ |
| ២ | មានការវាយតម្លៃការបំពេញការងារច្បាស់លាស់ | 3.76 | មធ្យម |
| ៣ | គ្រូបង្រៀន មានគុណវុឌ្ឍិសមស្របតាមនិយាម | 4.30 | ល្អណាស់ |
| ៤ | គ្រូបង្រៀន បានប្រើប្រាស់វិធីសាស្ត្របង្រៀនដោយច្នៃប្រឌិត | 3.85 | ល្អ |
| ៥ | ការប្រជុំបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ធ្វើជាទៀងទាត់ ដោយមានកំណត់ហេតុប្រជុំច្បាស់លាស់ | 4.05 | ល្អ |
| សរុប | | 3.99 | ល្អ |

តាមតារាងខាងលើបង្ហាញថា សូចនាករទាំងអស់ ដែលបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែង កសាងសមត្ថភាពគ្រូបង្រៀនរបស់គណៈគ្រប់គ្រងនៅតាមវិទ្យាល័យសំណាក។ សូចនាករទាំង៥មានពិន្ទុមធ្យមភាគចាប់ពីចន្លោះមធ្យមភាគ =3.76 ដល់មធ្យមភាគ=4.30 ដែលស្ថិតក្នុងចន្លោះពីកម្រិតមធ្យម ដល់កម្រិតល្អណាស់។ សូចនាករដែលមានលំដាប់ពិន្ទុខ្ពស់ជាងគេក្នុងលំដាប់ទី១គឺគ្រូបង្រៀន មានគុណវុឌ្ឍិសមស្របតាមនិយាម ដែលមានមធ្យមភាគ=4.30 ទទួលបានកម្រិតល្អណាស់ និងលំដាប់ទី២ គឺគ្រូការប្រជុំបច្ចេកទេសមុខវិជ្ជាភាសាអង់គ្លេស ធ្វើជាទៀងទាត់ ដោយមានកំណត់ហេតុប្រជុំច្បាស់លាស់ ដែលមានមធ្យមភាគ=4.00ក៏ស្ថិតនៅក្នុងកម្រិតល្អ។ ជារួមក្នុងសមាសភាគនេះ ការសរុបពិន្ទុមធ្យមភាគ ឃើញថាមធ្យមភាគ=3.99 ស្ថិតក្នុង

កម្រិតល្អផងដែរ ដែលសបញ្ជាក់ពីភាពវិជ្ជមានចំពោះ គណៈគ្រប់គ្រងលើការជួយដល់ការកសាងសមត្ថភាពគ្រូភាសាអង់គ្លេស។

តារាង4.8 ៖ គ. ការកសាងសមត្ថភាពសិស្ស

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | បានផ្តល់ចំណេះដឹង ជំនាញរឹង និងការត្រិះរិះពិចារណាដល់សិស្ស | 3.30 | មធ្យម |
| ២ | បានផ្តល់សេវាប្រឹក្សាការសិក្សាដល់សិស្ស | 2.65 | មធ្យម |
| ៣ | ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 4.05 | ល្អ |
| ៤ | មានប្រព័ន្ធលើកទឹកចិត្តសិស្ស | 3.90 | ល្អ |
| ៥ | ពិនិត្យតាមដានលើឥរិយាបថសិក្សារបស់សិស្សានុសិស្សជាប្រចាំ | 3.05 | មធ្យម |
| សរុប | | 3.39 | មធ្យម |

តាមតារាងខាងលើបង្ហាញថា សមាសភាគទាំង៥មានពិន្ទុមធ្យមភាគខុសៗគ្នា លើការកសាងសមត្ថភាពសិស្សរបស់គណៈគ្រប់គ្រងនៅក្នុងវិទ្យាល័យទាំង៩។ ក្នុងចំណោមសមាសភាគទាំងអស់នោះ ផ្នែកដែលទទួលបានពិន្ទុខ្ពស់គេមាន២គឺ (១) ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សមធ្យមភាគ =4.05 (២) មានប្រព័ន្ធលើកទឹកចិត្តសិស្ស មធ្យមភាគ=3.90 ស្ថិតនៅក្នុងលំដាប់ល្អដូចគ្នា ។ ជារួមការជួយពង្រឹងលើការរៀន និងបង្រៀនភាសាអង់គ្លេស លើសូចនាករ ការកសាងសមត្ថភាពសិស្ស គណៈគ្រប់គ្រងមានការយល់ស្របកម្រិតមធ្យម(M=3.39)។

តារាង4.9 ៖ ឃ. ការត្រួតពិនិត្យផ្ទៃក្នុង

| ល.រ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | មានគ្រូបង្រៀនភាសាអង់គ្លេសគ្រប់គ្រាន់ | 4.05 | ល្អ |
| ២ | បានពង្រឹងការអនុវត្តគោលការណ៍សិក្សាធិការ | 4.00 | ល្អ |
| ៣ | មានការវាយតម្លៃការបង្រៀនគ្រូភាសាអង់គ្លេស | 3.47 | ល្អ |

| | | | |
|---|---|---|---|
| ៤ | ដំណើរការក្រុមបច្ចេកទេសភាសាអង់គ្លេស | 3.79 | ល្អ |
| ៥ | បានរៀបចំការវាស់ស្ទង់សមត្ថភាពសិស្សភាសាអង់គ្លេស | 3.95 | ល្អ |
| ៦ | ត្រួតពិនិត្យជាប្រចាំលើការរៀន និងបង្រៀនភាសាអង់គ្លេស | 3.58 | ល្អ |
| សរុប | | 3.80 | ល្អ |

តារាងខាងលើបង្ហាញពីកម្រិតនៃការអនុវត្តក្នុងការត្រួតពិនិត្យលើការរៀន និងបង្រៀនភាសាអង់គ្លេស។ សូចនាករនីមួយៗមានការអនុវត្តល្អ ដែលមានមធ្យមពិន្ទុចន្លោះពី 3.47 ដល់ 4.05 ។ មធ្យមពិន្ទុសមាសភាគលើការត្រួតពិនិត្យលើការរៀន និងបង្រៀនភាសាអង់គ្លេសស្ថិតក្នុងកម្រិតល្អ (M=3.80) ។

តារាង4.10 ៖ ទិន្នន័យសរុបរបស់គណៈគ្រប់គ្រង

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ក | ការរៀបចំផែនការកែលម្អកម្មវិធីភាសាអង់គ្លេស | 3.64 | ល្អ |
| ខ | ការកសាងសមត្ថភាពគ្រូ | 3.99 | ល្អ |
| គ | ការកសាងសមត្ថភាពសិស្ស | 3.39 | ល្អ |
| ឃ | ការត្រួតពិនិត្យផ្ទៃក្នុង | 3.80 | ល្អ |
| សុប | | 3.70 | ល្អ |

តារាងខាងលើបង្ហាញពី មធ្យមភាគរួមរបស់គណៈគ្រប់គ្រងសាលារៀន លើការពង្រឹងការរៀន និងបង្រៀនភាសាអង់គ្លេស មានពិន្ទុមធ្យមភាគ = 3.70 ស្ថិតក្នុងកម្រិតល្អ។ សមាសភាគ ដែលមានពិន្ទុមធ្យមភាគខ្ពស់ជាងគេគឺ ការកសាងសមត្ថភាពគ្រូ មានមធ្យមភាគ =3.99 និងសមាសធាតុដែលមានតម្លៃមធ្យមភាគទាបជាងគេបំផុតគឺ ការកសាងសមត្ថភាពសិស្សមានពិន្ទុមធ្យមភាគត្រឹមតែ = 3.39 ក្នុងចំណោមសូចនាករទាំងអស់។

## ៤.៣ លទ្ធផលសរុបនៃការឆ្លើយតបរបស់សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រង លើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស

តារាងខាងក្រោមបង្ហាញពីមធ្យមភាគសរុបរួមលើចម្លើយដែលទទួលបានពីគ្រូបង្រៀន គណៈគ្រប់គ្រងសាលា និងសិស្សានុសិស្សនៅក្នុងវិទ្យាល័យគោលដៅទាំងប្រាំបួន អ្នកសិក្សាស្រាវជ្រាវទទួលបានលទ្ធផលដូចខាងក្រោម៖

**តារាង 4.11៖ មធ្យមភាគរួមរបស់សិស្ស គ្រូបង្រៀន និងគណៈគ្រប់គ្រង**

| លរ | បរិយាយ | មធ្យមភាគ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|
| ១ | ទិន្នន័យសរុបពីការឆ្លើយតបរបស់សិស្ស លើការរៀន និងបង្រៀនភាសាអង់គ្លេស | 3.42 | ល្អ |
| ២ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គ្រូបង្រៀន លើការរៀន និងបង្រៀនភាសាអង់គ្លេស | 3.44 | ល្អ |
| ៣ | ទិន្នន័យសរុបពីការឆ្លើយតបរបស់គណៈគ្រប់គ្រង លើការរៀន និងបង្រៀនភាសាអង់គ្លេស | 3.70 | ល្អ |

តារាងខាងលើជាការដកស្រង់មធ្យមភាគសរុបរួមពីការយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្ស លើការរៀន និងបង្រៀនភាសាអង់គ្លេស ។ មធ្យមភាគសរុបរួមរបស់តួអង្គទាំងបីមានតម្លៃប្រហាក់ប្រហែលគ្នា (ចន្លោះM=3.42 ដល់M=3.70)។ នៅក្នុងផ្នែកនីមួយៗសមាសភាគភាគច្រើនមានមធ្យមពិន្ទុល្អ ដែលបញ្ជាក់ថាភាគីទាំងបីមានការអនុវត្តល្អ។ តែទោះយ៉ាងណាក៏ដោយ ក៏នៅមានចំណុចមួយចំនួនដែលពុំទាន់អនុវត្តបានល្អ ដូចជាបញ្ហាទាក់ទងសាលាកង្វះធនធានរូបវ័ន្ត បន្ទប់អនុវត្តភាសា ជាបញ្ហាដែលត្រូវបានដោះស្រាយដោយគណៈគ្រប់គ្រង ការប្រើប្រាស់សម្ភារៈឧបទ្ទេស និងការប្រើប្រាស់វិធីសាស្ត្រប្រកបដោយការច្នៃប្រឌិត ដែលត្រូវការកែលម្អដោយកត្តាគ្រូបង្រៀន។ ចំណែកសិស្សក៏ដូចគ្នាដែរ មានកត្តាមួយចំនួនដែលជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សាជាអាទិ៍ កត្តាឥរិយាបទក្នុងការសិក្សាភាសាអង់គ្លេសមានដូចជាការយកចិត្តទុកដាក់រៀនមុខវិជ្ជាភាសាអង់គ្លេស ការបែងចែកពេលវេលាស្វ័យសិក្សា និងការរៀនបែបសហកាក្រុម។ល។

## ៤.៤ ការពិភាក្សា

### ៤.៤.១ លើស្ថានភាពនៃការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស

ដូចដែលយើងបានដឹងហើយថាការសិក្សាគឺតែងតែជួបប្រទះនូវបញ្ហាប្រឈមដែលតែងតែកើតមានឡើងក្នុងការគ្រប់គ្រង ការបង្រៀន ពិសេសគឺការរៀនតែម្តង។ បញ្ហាប្រឈមនោះទៀតសោត តែងតែកើតឡើងចំពោះរាល់មុខវិជ្ជាឯកទេស និងគ្រប់កម្រិតភូមិសិក្សា។ សិស្សភាគច្រើននៅកម្រិតវិទ្យាល័យ បើតាមការសង្កេតមើលលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឃើញថាមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាដែលមានចំនួនសិស្សជាប់តិចជាងគេក្នុងចំណោមមុខវិជ្ជាដទៃទៀត ទាំងនៅថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។

តាមរយៈការយកសូចនាករដែលពាក់ព័ន្ធជាច្រើនមកវិភាគយ៉ាងហ្មត់ចត់ យើងទទួលបានលទ្ធផលដូចតទៅ៖ តាមតារាង៤.៦ខាងលើបង្ហាញថាតាមទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងក្នុងការពង្រឹងលើការរៀន និងបង្រៀនគឺកត្តាធនធានរូបវន្ត(កញ្ចប់ថវិកាសម្រាប់ដំណើរការមុខវិជ្ជាភាសាអង់គ្លេស និងការបំពាក់សម្ភារៈបរិក្ខារ និងបន្ទប់អនុវត្តមុខវិជ្ជាភាសាអង់គ្លេស) មានឥទ្ធិពលជាវិជ្ជមានទៅលើលទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេស ខណៈកត្តាមួយចំនួនទៀតស្ថិតក្នុងស្ថានភាពនៃការអនុវត្តក្នុងកម្រិតល្អ។ លទ្ធផលនេះស្រដៀង ទៅនឹងការសិក្សាស្រាវរបស់លោក Supvitz, Sirinides, and May,(2014) បានបង្ហាញថា ការជួយគាំទ្រ និងភាពជាអ្នកដឹកនាំរបស់គណៈគ្រប់គ្រងគឺពិតជាទាក់ទងនឹងការអនុវត្តការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្ស។

ផែនការផ្តត់ផ្គង់នូវសម្ភារៈទ្រទ្រង់ដល់ដំណើរការរៀន និងបង្រៀន មានភាពចាំបាច់ពិតមែន តែដើម្បីជំរុញលទ្ធផលសិក្សារបស់សិស្សត្រូវតែមានការចូលរួមពីកត្តាផ្សេងទៀត។ តាមការសិក្សាស្រាវជ្រាវរបស់ Phothongsunan,(2014)ក្នុងប្រទេសថៃបានបង្ហាញថាកត្តាដែលរាំងស្ទះដល់លទ្ធផលសិក្សារបស់សិស្ស

មាន គ្រូបង្រៀនដែលខ្វះការជំរុញទឹកចិត្ត និងបរិស្ថានសិក្សា ដែលរួមទាំងទំនាក់ទំនងប្រកបដោយវិជ្ជមានរវាងគ្រូនិងសិស្ស។ បើតាមទិន្នន័យពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀន ក្នុងតារាង៤.៤ ការប្រើប្រាស់សម្ភារៈឧបទ្ទេសជាកត្តាដែលមានឥទ្ធិពលជាវិជ្ជមានដល់លទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសដែលមានន័យថាគ្រូបង្រៀនអាចនឹងខ្វះខាតសម្ភារៈឧបទ្ទេសសម្រាប់បង្រៀន ឬមិនបានប្រើសម្ភារៈឧបទ្ទេសដែលជាហេតុធ្វើឱ្យសិស្សពិបាកយល់លើខ្លឹមសារមេរៀន និងពាក្យថ្មីជាដើម។ ក្រៅពីនេះ បើតាមទស្សនៈយល់ឃើញរបស់គ្រូបង្រៀនបង្ហាញថា ការអនុវត្តកម្មវិធីសិក្សា ដំណើរការបង្រៀន និងទំនាក់ទំនងគ្រូសិស្ស មានឥទ្ធិពលតិចតួចតែប៉ុណ្ណោះដល់លទ្ធផលសិក្សារបស់សិស្សដែលមានន័យថាការអនុវត្តការងាររបស់គ្រូបង្រៀនស្ថិតក្នុងស្ថានភាពមួយល្អ ដែលអាចទទួលយកបាន។ លទ្ធផលនេះដូចគ្នាទៅនឹងការសិក្សាស្រាវជ្រាវរបស់Mosha,(2014) បានបង្ហាញថាការសិក្សារៀនសូត្ររបស់សិស្សត្រូវបានជះឥទ្ធិពលដោយសារតែគ្មានសម្ភារៈសម្រាប់បង្រៀន និងរៀន។

តាមទស្សនៈយល់ឃើញរបស់សិស្សបានបង្ហាញថា កត្តាដែលជះឥទ្ធិពលជាវិជ្ជមានដល់ការរៀន និងបង្រៀនផងដែរ នោះគឺទំហំសៀវភៅ រូបភាព កូល័រ (ក្រាបទី១) ការប្រើប្រាស់សម្ភារឧបទេស(ក្រាបទី២) ការយល់ឃើញរបស់សិស្សលើម៉ោងសិក្សានៅកម្រិតថ្នាក់ទី១១ និងទី១២ក្នុងមួយសប្តាហ៍ (ក្រាបទី៥)។ មិនតែប៉ណ្ណោះតាមការដកស្រង់ចម្លើយលើការបញ្ចេញយោបល់បន្ថែមរបស់គ្រូបង្រៀន ក៏ដូចជាគណៈគ្រប់គ្រងកត្តាជះឥទ្ធិពលផ្សេងទៀតមានដូចជាការបែងចែកពេលវេលាក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅផ្ទះ ការកំណត់គោលដៅច្បាស់លាស់លើសិក្សាមុខវិជ្ជាភាសាអង់គ្លេស។ ទាំងនេះយើងអាចវាយតម្លៃបាន សិស្សមានការជំរុញទឹកចិត្តទាប បានជាមិនបានផ្តោតការយកចិត្តទុកដាក់ខិតខំរៀនសូត្របន្ថែម។ បន្ថែមលើនេះទៅទៀតសិស្សានុសិស្សបានលើកឡើងថាស្របគ្នា៖ ការរៀនមុខវិជ្ជាភាសាអង់គ្លេសនៅតាមសាលារដ្ឋ មានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យលទ្ធផលសិក្សារបស់សិស្សមិនបានល្អ បញ្ហាទាំងនោះរួមមាន៖ សាលាខ្វះថវិកាក្នុងការរៀបចំបន្ទប់អនុវត្តភាសា ការប្រើប្រាស់សម្ភារៈឧបទ្ទេសជំនួយដល់ការបង្រៀន និងរៀនភាសា

អង់គ្លេស (ខ្វះ ឧបករណ៍ចាក់សម្លេង វីដេអូ និងឯកសារចាំបាច់មួយចំនួនទៀត) គ្រូមិនសូវទទួលបានការបណ្តុះបណ្តាលបំប៉នសមត្ថភាពលើវិធីសាស្រ្តថ្មីៗ មេរៀនក្នុងសៀវភៅសិក្សាមិនផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃក្នុងបរិបទកម្ពុជា និងកត្តាដែលជះឥទ្ធិពលសំខាន់ជាងគេបំផុតគឺដោយសារមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាបន្ថែម ដែលធ្វើឱ្យសិស្សស្ទើរតែទាំងអស់បង្កើតផ្នត់គំនិតបោះបង់ការខិតខំប្រឹងប្រែងជាពិសេសកម្រិតថ្នាក់ទី១២តែម្តង។

សរុបសេចក្តីមក ឆ្លងតាមការពិភាក្សាខាងលើបង្ហាញឱ្យឃើញថាមិនមែនតែកត្តាសិស្សទេ ដែលជាដើមចមនៃការធ្វើឱ្យលទ្ធផលសិក្សាភាសាអង់គ្លេស មិនមានការរីកចម្រើន សូម្បីតែគ្រូបង្រៀន ពិសេសគណៈគ្រប់គ្រងសាលារៀន ក៏បានរួមចំណែកក្នុងការធ្វើឱ្យមានការជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សផងដែរ។ ដូចអ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា អថេរទាំង៣ ដែលមាន(គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្សានុសិស្ស) គឺពិតជាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងការសម្រេចលើជោគវាសនារបស់សិស្សគ្រប់រូប (លទ្ធផលសិក្សា) ឆ្ពោះទៅរកវឌ្ឍនភាពរួមមួយសម្រាប់អនាគតរបស់សិស្សគ្រប់រូប និងគ្រប់ជំនាន់ ក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព លើការសិក្សាមុខវិជ្ជាភាសាអង់គ្លេសនេះឡើងវិញ។

### ៥.៤.២ ការពិភាក្សាលើការពង្រឹងលើការរៀន និងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស

ថ្វីបើមុខវិជ្ជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលក្នុង កម្មវិធីប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិជាច្រើនឆ្នាំហើយក្តី មុខវិជ្ជានេះនៅតែជាការលំបាកចំពោះសិស្សនៅពេលប្រឡងម្តងៗ ហើយលទ្ធផលសិក្សាលើមុខវិជ្ជាមួយនេះក៏នៅតែមិនទាន់បានល្អនៅឡើយ។ តាមរយៈការវិភាគទិន្នន័យពីកម្រងសំណួររបស់គណៈគ្រប់គ្រងសាលា អ្នកសិក្សាស្រាវជ្រាវបានកំណត់លើកត្តាជាអាទិភាពមួយចំនួនដូចជា កត្តាការរៀបចំផែនការកែលម្អកម្មវិធីសិក្សា ការអភិវឌ្ឍសមត្ថភាពគ្រូ សិស្ស និងការត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង (ស្វ័យវាយតម្លៃ)។

លទ្ធផលក្នុងតារាងទី៤.១០ បង្ហាញថាមធ្យមភាគសរុបរួមលើគ្រប់សមាសភាគស្ថិតនៅក្នុងកម្រិតល្អនៅឡើយ (M=3.70)។

តាមការបញ្ចេញយោបល់បន្ថែមរបស់គ្រូបង្រៀន និងគណៈគ្រប់គ្រង បានបង្ហាញស្របគ្នាថា គណៈគ្រប់គ្រងសាលាបានអនុវត្តការដឹកនាំការបង្រៀន និងរៀនបានល្អក្នុងកម្រិតដែលអាចទទួលយកបានក្នុងការជានាឱ្យលទ្ធផលរបស់សិស្សបានល្អ។ គណៈគ្រប់គ្រងក៏បានប្រើប្រាស់ប្រព័ន្ធលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានបំណងអភិវឌ្ឍសមត្ថភាពឱ្យបន្តការសិក្សា និងចូលរួមក្នុងសិក្ខាសាលានានាដែលពាក់ព័ន្ធនឹងឯកទេសបង្រៀនរបស់គ្រូផងដែរ។ ដោយយោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ Supvitz, Sirinides, and May,(2014) បានលើកឡើងថាការអនុវត្តការងាររបស់គណៈគ្រប់គ្រងមានសារៈសំខាន់ណាស់ចំពោះការសិក្សារបស់សិស្សដែលមានន័យថា គណៈគ្រប់គ្រងត្រូវការការបំពេញបន្ថែមតែបន្តិចបន្តួចប៉ុណ្ណោះនោះលទ្ធផលសិក្សារបស់សិស្សនិងបានល្អប្រសើរឡើងវិញ។ តែទោះជាយ៉ាងណាក៏ដោយ តាមការឆ្លើយតបលើដំណោះស្រាយជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អ គឺគ្រូបង្រៀន ដែលសំដៅដល់គ្រូបង្រៀនមានសមត្ថភាព មានគំនិតច្នៃប្រឌិតលើវិធីសាស្ត្របង្រៀន មានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ក្នុងការបង្រៀន។ ក្នុងន័យនេះ បើគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយ ក្នុងឆ្នាំសិក្សានីមួយៗ គោរពពេលវេលាក្នុងការបង្រៀន និងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន នោះលទ្ធផលសិក្សារបស់សិស្សពិតជាបានល្អប្រសើរជាក់ជាមិនខាន។ ដូចគ្នានោះដែរយោងតាមលទ្ធផលនៃការស្រាវជ្រាវរបស់Phothongsunan, (2014) បង្ហាញថាដើម្បីឱ្យសិស្សទទួលបានជោគជ័យលើការសិក្សារៀនសូត្រ គ្រូបង្រៀនជាអ្នកដើរតួយ៉ាងសំខាន់ក្នុងជំរុញការលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ ហើយសិស្សខ្លួនឯងក៏ត្រូវប្រឹងប្រែងបន្ថែមទ្វេរដងផងដែរ។ តាមលទ្ធផលនៃការស្រាវជ្រាវរបស់ Bouchaib, Ahmadou, & Abdelkader, (2018) នៅសាកលវិទ្យាល័យ Chouaib Doukkali University នៅប្រទេសម៉ូរ៉ូកូ បានបង្ហាញថា និស្សិតដែលទទួលបានជោគជ័យក្នុងការសិក្សាភាសាបរទេសភាគច្រើនគឺ ដោយសារកត្តាខាងក្រៅដែលមានដូចជា៖ បរិយាកាសថ្នាក់រៀន និងវិធី

សាស្ត្របង្រៀនជាដើម។ តាមរយៈការសិក្សាស្រាវជ្រាវរបស់Bell&Bogan,(2013) បានបង្ហាញដំណោះស្រាយចំនួន៣គឺដំណោះស្រាយលើកម្មវិធីសិក្សា គ្រូបង្រៀន និងថ្នាក់រៀន។ ក្នុងចំណោមដំណោះស្រាយទាំងអស់នេះ អ្នកសិក្សាស្រាវជ្រាវបានបញ្ជាក់ពីធាតុផ្សំតូចៗជាច្រើនដែលជួយជំរុញឱ្យសិស្សចូលចិត្តរៀនភាសាអង់គ្លេសដូចជា ការរៀបចំបរិយាកាសគាំទ្រដល់ការសិក្សា ការបង្ហាញពីអាកប្បកិរិយាវិជ្ជមានរវាងគ្រូ និងសិស្ស ការផ្តល់ឱកាសឱ្យគ្នាទៅវិញទៅមក ការបង្រៀនតាមក្រុមតូចៗ.. ជាដើម -ល-។ ដោយការអនុវត្តតាមដំណោះស្រាយទាំងនេះ សិស្សពិតជាពេញចិត្តក្នុងការរៀនសូត្រដែលធានាដល់ការលើកកម្ពស់លទ្ធផលសិក្សារបស់ពួកគេបាន។

មិនតែប៉ុណ្ណោះបើតាមទស្សនៈយោបល់បន្ថែមរបស់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាបានសង្កត់ធ្ងន់ថា ដំណោះស្រាយដែលជួយជំរុញឱ្យសិស្សខិតខំរៀនភាសាអង់គ្លេស គួរផ្តោតសំខាន់លើចំណុចដៅជាអាទិភាពមួយចំនួនដូចជា៖ ការកែលម្អកម្មវិធីសិក្សាភាសាអង់គ្លេសឱ្យផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់គ្រូ និងសិស្ស បន្ថែមម៉ោងបង្រៀនក្នុងមួយសប្តាហ៍ ការបើកវគ្គបំប៉នសមត្ថភាពដល់គ្រូឯកទេសភាសាអង់គ្លេសលើវិធីសាស្ត្របង្រៀនថ្មីៗ បង្កើនសម្ភារៈឧបទ្ទេសក្នុងការបង្រៀន និងរៀន និងពិសេសជាងគេបំផុត គឺការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាប្រឡងមានពិន្ទុពេញដូចមុខវិជ្ជាដទៃទៀត ដែលមានន័យថាគ្មានការកាត់ពិន្ទុពាក់កណ្តាលចោល។ ជាងនេះទៅទៀត គណៈគ្រប់គ្រងគួរតែបន្ត និងពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំលើលទ្ធផលការសិក្សារបស់សិស្ស និងការអនុវត្តការងាររបស់លោកគ្រូ-អ្នកគ្រូ ព្រោះគណៈគ្រប់គ្រងសាលាជាអធិការអប់រំអចិន្ត្រៃយ៍ នៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសគឺសាលារៀនតែម្តង។ ទន្ទឹមនឹងនេះផងដែរ គ្រូបង្រៀនក៏ត្រូវតែមានសមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សក្នុងកិច្ចដំណើរការរៀនសូត្ររបស់ពួកគេ។

សរុបសេចក្តីមក តាមរយៈការពិភាក្សាខាងលើបង្ហាញថាភាពជោគជ័យរបស់សិស្សលើការសិក្សា រៀនសូត្រត្រូវការជាចាំបាច់នូវការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធ ដែលរួមមានគណៈគ្រប់គ្រង គ្រូបង្រៀន និង

សិស្សានុសិស្សខ្លួនឯង។ យ៉ាងណាមិញ ក្នុងចំណោមតួអង្គទាំង៣ តួអង្គដែលសំខាន់ជាងគេគឺគ្រូបង្រៀន ព្រោះគ្រូបង្រៀនជាអ្នកនៅជាមួយសិស្សផ្ទាល់ស្ទើរតែរៀងរាល់ថ្ងៃ។ មានតែគ្រូបង្រៀនទេ ដែលដឹងថាកម្រិតចំណេះដឹងសិស្សរបស់គាត់កម្រិតណា។ ក្នុងនោះដែរយើងក៏បានកំណត់ដំណោះស្រាយសំខាន់ៗមួយចំនួនទៀតដែលជំរុញឱ្យលទ្ធផលលើការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតវិទ្យាល័យបានល្អរួមមាន ការអភិវឌ្ឍសម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀននិងរៀន។ អ្នកស្រាវជ្រាវជឿជាក់ថាបើដំណើរការបង្រៀន និងរៀនមានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់ នោះលទ្ធផលនៃការសិក្សារបស់សិស្សប្រាកដជាបានប្រសើរជាងគ្មានសម្ភារៈ ។ គេក៏មានការរំពឹងខ្ពស់ផងដែរ បើទោះបីមានសម្ភារៈគ្រប់គ្រាន់ហើយ តែសិស្សមិនចូលរួមសហការរៀន សូត្រនោះលទ្ធផលសិក្សាក៏មិនអាចកើតឡើងបានដែរ។ ពេលវេលាក៏ជាកត្តាសំខាន់ផងដែរ ដែលឈានដល់ការធ្វើឱ្យមានប្រសិទ្ធភាពក្នុងការសិក្សារៀនសូត្រ។ ការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំរបស់គណៈគ្រប់គ្រងសាលា ការខិតខំបំពេញការងាររបស់គ្រូបង្រៀនក៏ជាកត្តាដែលរួមចំណែកផងដែរ។ ហេតុនេះហើយ ដោយឈរលើមូលដ្ឋានជាក់លាក់ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវពិតជាកំណត់បានដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញឱ្យលទ្ធផលលើការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិបានប្រសើរឡើងប្រាកដមែន ។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និង

# សំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីការធ្វើការវិភាគទិន្នន័យ និងពិភាក្សាយ៉ាងល្អិតល្អន់ លើស្ថានភាពរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ ពិសេសគឺការជួយពង្រឹងលើលទ្ធផលសិក្សាភាសាអង់គ្លេសពីសំណាក់គណៈគ្រប់គ្រង អ្នកសិក្សាស្រាវជ្រាវធ្វើការសន្និដ្ឋានលើលទ្ធផលនៃការស្រាវជ្រាវដូចតទៅ៖

ក្នុងចំណោមសូចនាករដែលបានកំណត់ និងការផ្តល់ចម្លើយបន្ថែមរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស សូចនាករដែលនាំឱ្យសិស្សមិនសូវទទួលបានលទ្ធផលល្អក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសរួមមាន កត្តាធនធានរូបវន្ត ការប្រើប្រាស់សម្ភារៈឧបទ្ទេសបង្រៀននិងរៀន កត្តាមេរៀនក្នុងសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស និងឥរិយាបទផ្ទាល់ខ្លួនក្នុងការសិក្សាមុខវិជ្ជាភាសាអង់គ្លេសរបស់សិស្ស ជាបញ្ហាប្រឈមក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិ។ ដោយយោងតាមការវិភាគទិន្នន័យ ដែលប្រមូលបានពីក្រុមគោលដៅតម្លៃមធ្យមភាគលើកត្តាទាំងបីនេះមានត្រឹមតែ (មធ្យមភាគ= 3.42 ដល់ មធ្យមភាគ=3.70) តែប៉ុណ្ណោះ។ លទ្ធផលនេះពិតជាបានបង្ហាញពីភាពចាំបាច់ក្នុងការប្រើប្រាស់ធនធានរូបវន្ត សម្ភារៈឧបទ្ទេសក្នុងកិច្ចដំណើរការបង្រៀន និងរៀនដែលជួយឱ្យសិស្សធាប់ចាប់បាននូវខ្លឹមសារមេរៀនដែលឆ្លើយតបទៅនឹងទ្រឹស្តីរបស់ Bloom's Taxonomy ទាំងប្រាំមួយគឺ ចងចាំ យល់ អនុវត្ត វិភាគ វាយតម្លៃ និងបង្កើតថ្មី។ បន្ថែមពីនេះទៅទៀត មេរៀនក្នុងសៀវភៅសិក្សាគោល ក៏គួរតែមានការកែលម្អដើម្បីឱ្យសមស្របទៅនឹងជីវភាពរស់នៅតាមបរិបទ របស់ប្រទេសជាតិ ដើម្បីឱ្យសិស្សធាប់យល់បាននូវខ្លឹមសារមេរៀន ជៀសវាងការយកខ្លឹមសារដែលធ្វើឱ្យសិស្សពិបាកយល់ និងសាំញ៉ាំ។ យ៉ាងណាមិញ ការកំណត់គោលដៅមិនច្បាស់លាស់របស់សិស្សក្នុងការសិក្សាភាសាអង់គ្លេស ក៏ជាកត្តាមួយដែលប្រឈមខ្លាំងផងដែរទោះបីជាមានធនធានរូបវន្ត សម្ភារៈឧបទ្ទេសម្រាប់ការបង្រៀនកម្រិតណា មេរៀនផ្សារភ្ជាប់នឹងជីវភាព

រស់នៅកម្រិតណាក៏ដោយ ក៏មិនអាចជួយជ្រោមជ្រែងឲ្យសិស្សទទួលបានលទ្ធផលល្អ និងជោគជ័យក្នុងការសិក្សាដែរ។ ដូចសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរម្នាក់បានលើកឡើងថា "បើប្អូនៗមិនខិតខំហ្វឹកហាត់បន្ថែមដោយខ្លួនឯងទេ ទោះគ្រូបង្រៀនមកពីឋានព្រះឥន្ទ្រក៏បង្រៀនប្អូនមិនចេះដែរ"។

ក្រៅអំពីផលជះជាវិជ្ជមាននេះក៏នៅមានការលើកឡើងពីចំណុចគួរកែលម្អមួយចំនួនទៀត ដែលគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ គួរយកចិត្តទុកដាក់រួមមាន៖ ពង្រឹងយន្តការនៃការលើកទឹកចិត្ត បង្កើនការយកចិត្តទុកដាក់លើការបង្រៀនឱ្យគ្រប់ជ្រុងជ្រោយ ពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និតជាមួយគ្រប់ភាគីពាក់ព័ន្ធ លើកកម្ពស់ដល់ទំនាក់ទំនងគ្រូ-សិស្ស បន្តការជម្រុញឱ្យសិស្សខិតខំប្រឹងប្រែងរៀនភាសាអង់គ្លេសឡើងវិញឱ្យកាន់តែខ្លាំងក្លា និងផ្តល់ការប្រឹក្សាដល់សិស្សក្នុងការចាត់ទុកមុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាសំខាន់ដូចគ្នាទៅនឹង មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ភាសាខ្មែរ ជីវវិទ្យា ។ល។

ថ្វីបើមានឥទ្ធិពលជាវិជ្ជមានមួយចំនួនលើលទ្ធផលសិក្សាមុខវិជ្ជាភាសាអង់គ្លេសក្តីក៏នៅមានដំណោះស្រាយ ដែលអាចជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានល្អប្រសើរឡើងវិញផងដែរ។ ក្នុងចំណោមអថេរដែលអ្នកសិក្សាបានកំណត់ អថេរដែលជាដំណោះស្រាយដែលអាចជួយជំរុញឱ្យលទ្ធផលសិក្សាភាសាអង់គ្លេសរបស់សិស្សបានល្អប្រសើរឡើងវិញចាំបាច់ជាងគេបំផុត គឺគ្រូបង្រៀន ដែលសំដៅដល់ការអនុវត្តកម្មវិធីសិក្សាបានគ្រប់ជ្រុងជ្រោយ មានវិធីសាស្ត្របង្រៀនល្អ មានគំនិតច្នៃប្រឌិតខ្ពស់តាមស្តង់ដាគ្រូបង្រៀនសតវត្សទី២១ បង្រៀនបានគ្រប់ម៉ោង និងស្របតាមបំណែងចែកកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេស ផ្តល់ការប្រឹក្សាពីសារៈសំខាន់ នៃការប្រើប្រាស់ភាសាអង់គ្លេស មានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ធ្វើបច្ចុប្បន្នភាពលើវិធីសាស្ត្របង្រៀនភាសាអង់គ្លេសជាប្រចាំ មានផែនការអភិវឌ្ឍមុខវិជ្ជាភាសាអង់គ្លេស កែលម្អបន្ទប់អនុវត្តន៍ភាសាអង់គ្លេសស្របតាមស្តង់ដាភាសាវិទ្យា ផ្តល់ការលើកទឹកចិត្តបន្ថែមតាមកម្រិតសមត្ថភាពចំណេះដឹងលើលទ្ធផលនិទ្ទេសប្រឡងមុខវិជ្ជាភាសាអង់គ្លេស ការពង្រឹងដំណើរការស្វ័យសិក្សា និងត្រៀមលក្ខណៈសម្រាប់ប្រឡង និងចំណុចចុងក្រោយ ការសាកល្បងធ្វើលំហាត់តាមតេស្តស្តង់ដារភាសាអង់គ្លេសលើសន្លឹកកិច្ចការ។

ផ្អែកលើទឡ្ហីករណ៍ដែលបានលើកឡើងខាងលើនេះ សបញ្ជាក់ឱ្យឃើញថាការអនុវត្តតាមដំណោះស្រាយដែលបានរកឃើញ គឺពិតជាអាចជួយឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សាពិសេសនៅពេលប្រឡងបញ្ចប់ ថ្នាក់ទី១២ជាក់ជាមិនខាន។ តាមរយៈដំណោះស្រាយទាំងអស់ដែលបានរកឃើញខាងលើ ពិតជាបានឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវក្នុងការស្វែងរកដំណោះស្រាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញសិស្សបន្តខិតខំរៀនសូត្រភាសាអង់គ្លេសឡើងវិញ ពិសេសគឺការធ្វើឱ្យលទ្ធផលរបស់ពួកគេបានល្អក្នុងពេលប្រឡង។ ដូចគ្នានេះដែរ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូបានបន្ថែមទៀតថា បើក្រសួងអប់រំ យុវជន និង កីឡា ពិចារណាលើការមិនកាត់ពិន្ទុពាក់កណ្ដាលលើមុខវិជ្ជានេះ សិស្សនឹងងាកមករកការខិតខំសិក្សារៀនសូត្រលើមុខវិជ្ជាភាសាអង់គ្លេសឡើងវិញជាក់ជាមិនខាន។

សរុបសេចក្ដីមក ការសិក្សារៀនសូត្រគ្រប់ជំណាក់កាល គ្រប់កម្រិត និងគ្រប់មុខវិជ្ជាតែងតែមានផលវិបាកមិនអាចជៀសផុតបានឡើយ។ ដោយមើលឃើញពីការលំបាកនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តជ្រើសយកប្រធានបទខាងលើមកសិក្សា ដោយហេតុថាក្រោយពីការសិក្សាស្រាវជ្រាវនេះ នឹងរកឃើញនូវរបកគំហើញថ្មីដើម្បីជាប្រយោជន៍សម្រាប់អ្នកសិក្សាជំនាន់ក្រោយ ពិសេសជាងនោះទៅទៀតគឺការធ្វើលទ្ធផលប្រឡងសិស្សថ្នាក់ទី១២មុខវិជ្ជាភាសាអង់គ្លេសបានល្អប្រសើរឡើងវិញក្រោយពីការសិក្សាស្រាវជ្រាវបានបញ្ចប់ទៅ។ ដូចការរំពឹងទុក អ្នកសិក្សាស្រាវជ្រាវពិតជាកំណត់បាននូវកត្តាចម្បងៗ និងដំណោះស្រាយជាក់លាក់ដែលឆ្លើយតបនឹងវត្ថុបំណងដែលបានកំណត់តាមរយៈសំណួរស្រាវជ្រាវប្រាកដមែន។ ដោយក្ដីសង្ឃឹមយ៉ាងមុតមាំលើលទ្ធផលដែលរកឃើញ អ្នកសិក្សាស្រាវជ្រាវមានជំនឿជឿជាក់ថា បើថ្នាក់ដឹកនាំក្រសួង និងអ្នកពាក់ព័ន្ធដាក់ចេញនូវគោលការណ៍ចាំបាច់ទាំងនោះលើការសិក្សាមុខវិជ្ជាភាសាអង់គ្លេស នោះលទ្ធផលសិក្សារបស់សិស្សពិតជាបានល្អប្រសើរឡើងវិញយ៉ាងពិតប្រាកដ។

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវយល់ឃើញថាការសិក្សាភាសាអង់គ្លេស របស់សិស្សនៅកម្រិតមធ្យមសិក្សាកំពុងជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវការដោះស្រាយជាចាំបាច់ ក្នុងការជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានប្រសើរឡើង។ ដោយហេតុថា ការសិក្សានេះមានវិសាលភាពមិនទាន់ទូលំទូលាយដែលត្រូវការជាចាំបាច់នូវអ្នកសិក្សាបន្តបន្ថែមទៀត ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវកាន់តែមានសង្គតិភាព។ ផ្អែកលើគោលជំហរទាំងអស់នេះ អ្នកសិក្សាស្រាវជ្រាវ គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស សូមសំណូមពរដូចតទៅៈ

ក.ក្រសួងអប់រំ យុវជន និងកីឡា

- បង្កើនការបោះពុម្ពសៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស និងផ្តល់ការគាំទ្រការផលិតសម្ភារៈឧបទ្ទេសដល់សាលារៀន ។
- ពង្រឹងការដឹកនាំគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលា លើដំណើរការគ្រប់គ្រងដឹកនាំប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ស្របតាមសាលារៀនគំរូ។

ខ. មន្ទីរអប់រំ យុវជន និងកីឡា

- ពង្រឹងការអនុវត្តការបែងចែកភារៈកិច្ចការចុះពិនិត្យ តាមដាន និងវាយតម្លៃ លើការប្រើប្រាស់សៀវភៅសិក្សាគោល និងសម្ភារៈឧបទ្ទេស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និង សិស្ស
- សូមមន្ទីរពង្រឹងការបែងចែកភារៈកិច្ចការចុះពិនិត្យ តាមដាន និងវាយតម្លៃឱ្យបានជាប្រចាំលើការអនុវត្តការងាររបស់គណៈគ្រប់គ្រងសាលា និង លោកគ្រូអ្នកគ្រូក្នុងប្រើប្រាស់សម្ភារៈបង្រៀន និងធនធានផ្សេងៗទៀត
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទាក់ទងនឹងការរៀន និងបង្រៀន មុខវិជ្ជាភាសាអង់គ្លេស។

- សូមមន្ទីរជំរុញការលើកទឹកចិត្តគ្រូបង្រៀនឱ្យផលិតសម្ភារៈឧបទ្ទេសដែលងាយស្រួលផលិតបានដោយខ្លួនឯង។

គ. គណៈគ្រប់គ្រងសាលា

- ណែនាំ និងបែងចែកសៀវភៅសិក្សាគោល សម្ភារៈឧបទ្ទេសសម្រាប់ការអនុវត្តការបង្រៀននិងរៀន ។
- សូមគណៈគ្រប់គ្រងសាលាផ្សព្វផ្សាយពីការណែនាំ និង បច្ចេកទេសថ្មីៗ ដល់លោកគ្រូអ្នកគ្រូ
- សូមផ្ដល់ការលើកទឹកចិត្តបន្ថែមជូនលោកគ្រូ-អ្នកគ្រូបង្រៀនភាសាងង់គ្លេស និងសិស្សដែលមានលទ្ធផលសិក្សាភាសាអង់គ្លេសល្អ។
- សូមពង្រឹងការប្រើប្រាស់យន្តការអធិការកិច្ចផ្ទៃក្នុងដើម្បីពង្រឹងដល់ការអនុវត្តការងាររបស់ គ្រូបង្រៀនភាសាអង់គ្លេស។
- សូមពង្រឹងការពិនិត្យតាមដានឱ្យបានជាប្រចាំលើវត្តមានរបស់សិស្ស។

ឃ. អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

- សូមអ្នកសិក្សាជំនាន់ក្រោយពង្រីកសំណាក និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានទូលំទូលាយជាងនេះ
- សូមអ្នកសិក្សាជំនាន់ក្រោយពង្រីកសំណាក និងវិសាលភាពនៃការស្រាវជ្រាវឱ្យបានទូលំទូលាយលើការរៀននិងបង្រៀនភាសាបរទេសផ្សេងៗទៀត ដូចជា បារាំង ចិន ជប៉ុន -ល- និងសិក្សាស៊ីជម្រៅបន្ថែមលើប្រធានបទដែលបានសិក្សានេះ ដោយពង្រីកវិសាលភាពនៃការស្រាវជ្រាវ និងផ្អែកលើការសិក្សាស្រាវជ្រាវបែបចម្រុះ។

# ឯកសារយោង


វិទ្យាស្ថានជាតិអប់រំ (២០២០) ការបង្រៀន និងរៀនតាមបែបរិះរក

គោលការណ៍កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ (នាយកដ្ឋានបុគ្គលិក ឆ្នាំ២០១៩)

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩ក) ក្របខណ្ឌ និងផែនការសកម្មភាព ស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា ភ្នំពេញ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩ខ) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា(២០១៩គ) ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា (ខែធ្នូ ២០១៨) ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសាលា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧ក) ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧ខ) ស្តង់ដានាយកសាលារៀន

ក្រសួងអប់រំ យុវជននិងកីឡា (២០១៦) ការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំសម្រាប់បំប៉ននាយក

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា (២០១៦) ក្របខណ្ឌកម្មវិធី សិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡា ២០១៦, សេចក្តីណែនាំស្តីពីការអនុវត្តសៀវភៅសិក្សាគោល ភាសាអង់គ្លេស English Grade 7-9. ភ្នំពេញ

ក្រសួងអប់រំ យុវជន និង កីឡា (២០១៥) ចក្ខុវិស័យកំណែទម្រង់វិស័យអប់រំនៅកម្ពុជា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥ក) ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ភ្នំពេញ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥ខ) គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាព ភ្នំពេញ

ក្រសួងអប់រំ  យុវជន និងកីឡា (២០១២) គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា (២០១១) ឯកសារណែនាំការអនុវត្តកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី ១១ និង ថ្នាក់ទី ១២

នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ (២០១១) ការរៀនតាមបែបរិះរក

អនុក្រិត្យស្តីពី ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន (២០០៨)

យូនីសេហ្វ. (2008). របាយការថ្នាក់ជាតិស្តីពីការវាយតម្លៃការអប់រំសម្រាប់ទាំងអស់គ្នា. ភ្នំពេញៈ យូនី សេហ្វ និងស៊ីដា

Adam S (2010) An introduction to learning outcomes.

Suh et al (2010). Effectiveness of MMORPG-based instruction in elementary English education in Korea.

Beatriz, P., Deborah, N., & Hunter, M. (2008). Improving School Leadership Activity (Vol. 1). OECD: Policy and Practice.

Tanzania (2007). Barriers to Spectacle Use in Tanzanian Secondary School Students.

Leithwood, Harris & Hopkins (2008). School leadership and management.

Institute of Education, Phnom Penh: IDP. Koji Ikawa. (2008). English Language and Its

Education in Cambodia, A Country in Transition. Shitennoji University Bulletin, 343-369.

Ornstein and Hurkins, Curriculum: Foundations, Principles, and Issues, seventh edition

J. Galen Saylor, William M. Alexander, Arthur J. Lewis, Curriculum planning for better teaching and learning, 4th edition.

MacNeil, Prater, & Busch (2009) The effects of school culture and climate on student achievement.

Vuzo (2010). English language teachers´ classroom assessment practices of oral language skills in secondary schools in Tanzania.

Mosha (2014). Factors affecting students' performance in English language in Zanzibar rural and urban secondary schools.

Bouchaib, B., Ahmadou, B., & Abdelkader, S. (2018). High School Students' Attributions of Success in English Language Learning. International Journal of Instruction, 11(2), 89-102.

MoEYS. (2017), Syllabus of English: Grade 4-6, DCD, Syllabus of English: Grade 4-6. Phnom Penh.

Ministry of Education, Youth and Sport (January 2015). Teacher Policy Action Plan. Phnom Penh: Teacher Training Department.

Hafsha Jan (2017). Teacher of 21st Century: Characteristics and Development.

Lydia M. Musau & Migosi Joash Abere. (2015). Teacher qualification and students' academic performance in science mathematics and technology subjects in Kenya. Intenational Journal of Educational Administration and Policy Studies, 83-89.

MoEYS. (2015). Curriculum Framework. Phnom Penh: MOEYS, Cambodia.

Hallinger, P., & Wang, W. (2015). Assessing Instructional Leadership with the Principal Insructional Management Rating Scale. Switzerland: Springer International Publishing.

Bell, D., & Bogan, B. L. (2013). English language learners: Problems and solutions found in the research of general practitioners of early childhood. The Journal of Balanced Literacy

Seashore Louis, Dretzke, & Wahlstrom, (2010). The Relationship Between Instructional Leadership and Organizational Commitment of Teachers.

Seashore Louis, K., Detzke, B., & Wahlstrom, K. (2010). How does leadership affect student achievement? Results from a national US survey. School Effectiveness and School Improvement, 21(3), 315-336.

Reimers, F. M., & Schleicher, A. (2020). A Framework to Guide an Education Response to the COVID-19 Pandemic of 2020. Organisation for Economic Co-Operation and Development.

Mary Thurmon Skelton (2019). The Relationship Between Instructional Leadership and Organizational Commitment of Teachers.

Vira Neau. (2003). The Teaching of Foreign Languages in Cambodia: A Historical Perspective, Language, Culture and Curriculum, 253

Lee S. Shulman. (1999). Taking Learning Seriously. Carnegie Foundation for the Advancement of Teaching, 10-17.

J. Galen Saylor, William M. Alexander, Arthur J. Lewis: Curriculum planning for better teaching and learning.

Allen, E, and Valette, R. (1997). Classroom Technique: Foreign Languages and English as a second Languages and English as a second Language. San Diego, Harecourt Brace Jovanovich.

Krashen, S. (2002- First internet edition, December-2002). Second Language Acquisition and Second Language Learning. University of Southern California.

National curriculum and Textbook Board (2006). Compulsory curriculum (Primary education). Retrieved January 25, (2012).

## ឧបសម្ព័ន្ធ ក

## កម្រងសំណួរសម្រាប់សិស្សានុសិស្សតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីសិក្សាស្វែងយល់ពីការយល់ឃើញរបស់សិស្សក្នុងការរៀន និងបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅរាជធានីភ្នំពេញ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះ មានគោលបំណងយកទៅប្រើប្រាស់ដើម្បីចងក្រងជាសារណាបទតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមសិស្សានុសិស្ស ជួយផ្ដល់ព័ត៌មានពិតជាក់ស្តែងតាមការសង្កេតក្នុងពេលសិក្សាមុខវិជ្ជាភាសាអង់គ្លេស ដើម្បីឲ្យខ្ញុំអាចទទួលបានទិន្នន័យពិតប្រាកដ យកមកសិក្សាវិភាគ ព្រមទាំងអាចឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមប្អូនៗគ្រប់គ្នា។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

ការណែនាំ៖ សូមគូសសញ្ញា √ នៅក្នុងប្រអប់□ ដែលបំពេញត្រូវនឹងស្ថានភាពទូទៅប្អូនៗ

១. បានសិក្សាមុខវិជ្ជាភាសាអង់គ្លេសក្នុងវិទ្យាល័យ □ធ្លាប់ □មិនធ្លាប់

២. ភេទ៖ □ប្រុស □ស្រី

៣. អាយុ៖ □១៤-១៦ឆ្នាំ □១៧-១៩ឆ្នាំ □លើស ១៩ឆ្នាំ

៤.រៀនថ្នាក់ទី៖ □១០ □១១ □១២

៥. រៀននៅវិទ្យាល័យ៖.................................................................................

### ផ្នែកទី២៖ ភាពពេញចិត្តបំពេញចំពោះការរៀនភាសាអង់គ្លេស

ការណែនាំ៖ ក្រោយពីទទួលបានការសិក្សា មុខវិជ្ជាភាសាអង់គ្លេសនៅតាមវិទ្យាល័យ ក្នុងឆ្នាំសិក្សា ២០២២-២០២៣ រួមមក តើប្អូនៗយល់ឃើញយ៉ាងដូចម្តេចអំពីការរៀន និងបង្រៀនភាសាអង់គ្លេស? សូមអានចំណុចនីមួយៗ ឲ្យបានច្បាស់លាស់បន្ទាប់មកសូមគូសសញ្ញា √ ទៅតាមកម្រិតពេញចិត្ត ដែលត្រូវនឹងការយល់ឃើញរបស់ប្អូនៗ

កម្រិតចង្អុលបង្ហាញ៖

១.មិនពេញចិត្តទាល់តែសោះ

២.មិនពេញចិត្ត

៣.ពេញចិត្តតិចតួច

៤.ពេញចិត្ត

៥.ពេញចិត្តខ្លាំង

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| **ក. អំពីម៉ោងសិក្សា និងសៀវភៅសិក្សាគោល** | | | | | | |
| ១ | ចំនួនម៉ោងសិក្សាភាសាអង់គ្លេសក្នុង១សប្តាហ៍ | | | | | |
| ២ | ខ្លឹមសារនៃមេរៀននីមួយៗ | | | | | |
| ៣ | ទំហំសៀវភៅ រូបភាព កូល័រ និងហ្វុងអក្សរ | | | | | |
| ៤ | វាក្យសព្ទក្នុងមេរៀននីមួយៗ | | | | | |
| ៥ | កម្រិតនៃវេយ្យាករណ៍ | | | | | |
| ៦ | លំហាត់ និងសំណួរសម្រាប់អនុវត្តនៃមេរៀននីមួយៗ | | | | | |
| ៧ | ជំនាញក្នុងការស្តាប់ | | | | | |
| ៨ | ជំនាញក្នុងការនិយាយ | | | | | |
| ៩ | ជំនាញក្នុងការសរសេរ | | | | | |
| ១០ | ជំនាញក្នុងការអាន | | | | | |
